អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

# ព្រឹត្តិបត្រពន្ធដារ

ត្រីមាសទី១ ឆ្នាំ២០២៤







មករា - មីនា ២០២៤

លេខ៖ ០៩

# អារម្ភកថា



រាជរដ្ឋាភិបាលថ្មីអាណត្តិទី៧ ដែលមានសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីដំបូង នីតិកាលទី៧ នៃរដ្ឋសភា នៅថ្ងៃព្រហស្បតិ៍ ទី២៤ ខែសីហា ឆ្នាំ២០២៣ និងបានប្រកាសដាក់ចេញ "**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១**" ដើម្បីជំរុញកំណើនសេដ្ឋកិច្ច បង្កើតការងារ ធានាសមធម៌ បង្កើនប្រសិទ្ធភាព និងរក្សាចីរភាព សំដៅឆ្លើយតបនឹងបំណងប្រាថ្នាប្រជាជន ឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងឆ្នាំ២០៥០ ជាប្រទេសមានចំណូលខ្ពស់។

ភាគីពាក់ព័ន្ធទាំងស្ថាប័នរដ្ឋ និងវិស័យឯកជននៃរាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងគាំទ្រនិងចូលរួមយ៉ាងសកម្មក្នុងការចូលរួមអនុវត្តកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលថ្មីអាណត្តិទី៧ ដើម្បីសម្រេចបាននូវបំណងប្រាថ្នាទាំងពីរខាងលើ។ ស្របជាមួយគ្នានេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានអគ្គនាយកដ្ឋានពន្ធដារជាសេនាធិការ និងមានតួនាទីប្រមូលនិងគ្រប់គ្រងចំណូលពន្ធផ្ទៃក្នុងដែលជាផ្នែកមួយដ៏សំខាន់នៃថវិកាសម្រាប់អភិវឌ្ឍជាតិ ក៏បាននិងកំពុងបន្តប្តេជ្ញាយកចិត្តទុកដាក់លើការកែទម្រង់ទាំងគោលនយោបាយនិងរដ្ឋបាលសារពើពន្ធ ពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ប្រកបដោយភាពសុចរិត និងស្មើភាពចំពោះអ្នកជាប់ពន្ធ ដើម្បីជំរុញអនុលោមភាពដោយស្ម័គ្រចិត្តឈានទៅសម្រេចបាននូវការប្រមូលចំណូលពន្ធប្រកបដោយចីរភាព ក្នុងគោលដៅលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។ ជាមួយគ្នានេះ ក្នុងទិសដៅផ្តល់សេវាគ្រប់មធ្យោបាយជូនអ្នកជាប់ពន្ធឱ្យកាន់តែប្រសើរ និងទទួលបានព័ត៌មាន ត្រឹមត្រូវនិងទាន់ពេលវេលា អគ្គនាយកដ្ឋានពន្ធដារបានរៀបចំបោះពុម្ពព្រឹត្តិបត្រពន្ធដារប្រចាំត្រីមាសចំនួន ៨ លេខ តាំងពីដើមឆ្នាំ ២០២២ និងបន្តចងក្រងបោះពុម្ព សម្រាប់ត្រីមាសទី១ ឆ្នាំ២០២៤ ទៀត ជាមួយនឹងមាតិកា រួមមាន ព្រឹត្តិការណ៍សំខាន់ៗ, ស្ថានភាពនៃការគ្រប់គ្រងប្រមូលចំណូលពន្ធ, វឌ្ឍនភាពការងារនៃមុខងារប្រតិបត្តិការស្នូលនិងមុខងារគាំទ្រ, បច្ចុប្បន្នភាពច្បាប់លិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ និងគោលនយោបាយសារពើពន្ធ, កិច្ចសហប្រតិបត្តិការក្របខ័ណ្ឌជាតិ-អន្តរជាតិ និងការផ្សព្វផ្សាយនិងបញ្ជ្រាបវប្បធម៌បង់ពន្ធ។

ក្នុងនាមជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ខ្ញុំមានជំនឿថាលោក លោកស្រី សាធារណជន និងស្ថាប័នជាតិ-អន្តរជាតិ នឹងជ្រាបកាន់តែច្បាស់អំពីស្ថានភាពគ្រប់គ្រងការប្រមូលចំណូលពន្ធនិងវឌ្ឍនភាពថ្មីៗ ជាពិសេសកិច្ចខិតខំប្រឹងប្រែងរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងការធ្វើបច្ចុប្បន្នកម្មបទប្បញ្ញត្តិនិងទំនើបកម្មរដ្ឋបាលសារពើពន្ធនិងប្រព័ន្ធបច្ចេកវិទ្យាស្របតាមគោលនយោបាយ ទស្សនវិស័យ និងទិសដៅរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានដាក់ចេញតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ៕

ថ្ងៃសុក្រ ១១ កើត ខែចេត្រ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**



**គង់ វិបុល**

# ព្រឹត្តិបត្រពន្ធដារ

## ត្រីមាសទី១ ឆ្នាំ២០២៤

**សមាសភាពទទួលបន្ទុកតាក់តែង និពន្ធ និងបោះពុម្ពព្រឹត្តិបត្រពន្ធដារ**

| | | |
|---|---|---|
| និពន្ធនាយក | ៖ | ឯកឧត្តម **គង់ វិបុល** |
| គណៈដឹកនាំ | ៖ | លោក **វៀម រដ្ឋា** និងលោក **កែ ឈុំបញ្ញា** |
| អ្នករៀបរៀងអត្ថបទ | ៖ | លោកស្រី **សេង ច័ន្ទមុន្នី** លោកស្រី **ដេត ពុទ្ធាទី** និងលោក **រិន ណារ៉ូ** |
| អ្នករចនា | ៖ | លោក **លីម សិទ្ធិ** កញ្ញា **ឈៀង សុខឡេង** និងលោក **សារិន ម៉េងហៀង** |
| អ្នកផ្តល់រូបភាព | ៖ | លោក **ទិត្យ ចំរើនបញ្ញា** លោក **សុន្ទរៈ ត្រដឹម** និងលោក **ឥន្ទ វាសនា** |
| អ្នកស្រាវជ្រាវ | ៖ | លោក **ជុំ សូលីវណ្ណា** លោក **សំរិទ្ធ មករា** លោក **រិទ្ធ តីណា** កញ្ញា **សុធីរ វឌ្ឍនា** លោកស្រី **សាវិន វីនីហ្សា** និងលោក **អាន ចាន់ថាណារិទ្ធ** |
| អ្នកកែសម្រួលអក្ខរាវិរុទ្ធ | ៖ | លោក **អ៊ិន សំបុក** និងលោក **ជា ពិសិដ្ឋ** |
| អ្នកបោះពុម្ព | ៖ | លោក **ស៊ុនលី ជីនី** |
| អ្នកផ្សព្វផ្សាយព័ត៌មាន និងចែកចាយ | ៖ | លោកស្រី **ឌីពៅ ទិត្យធីយ៉ា** លោកស្រី **ថុង ស្រីពៅ** លោក **មូ សុភ័ក្ត្រ** និងលោក **ឡាង តក្រា** |

# មាតិកា


**ព្រឹត្តិការណ៍សំខាន់ៗ.......................................................................................៩**

**ផ្នែកទី១៖ ស្ថានភាពនៃការគ្រប់គ្រងការប្រមូលចំណូលពន្ធ**

១. លទ្ធផលការងារប្រមូលចំណូលពន្ធ..........................................................................២៧

២. ស្ថានភាពចំណូលពន្ធតាមប្រភេទអ្នកជាប់ពន្ធ............................................................២៧

៣. ស្ថានភាពចំណូលពន្ធតាមប្រភេទពន្ធសំខាន់ៗ...........................................................២៨

៤. ស្ថានភាពចំណូលពន្ធតាមសកម្មភាពអាជីវកម្មសំខាន់ៗ..................................................២៩

**ផ្នែកទី២៖ វឌ្ឍនភាពការងារនៃមុខងារប្រតិបត្តិការស្នូល និងមុខងារគាំទ្រ**

១. ការចុះបញ្ជីពន្ធដារ........................................................................................ ៣៣

២. ការផ្តល់សេវាអ្នកជាប់ពន្ធ.................................................................................. ៣៣

៣. ការចាត់ចែងលិខិតប្រកាសពន្ធ.............................................................................៣៨

៤. ការធ្វើសវនកម្មពន្ធដារ.......................................................................................៣៩

៥. ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា.......................................................................៣៩

៦. បច្ចេកវិទ្យាព័ត៌មាន ...........................................................................................៤០

**ផ្នែកទី៣៖ បច្ចុប្បន្នភាពច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសារពើពន្ធ**

១. អនុក្រឹត្យ........................................................................................................ ៤៥

២. ប្រកាស...........................................................................................................៤៦

៣. សេចក្តីណែនាំ...................................................................................................៤៩

៤. សេចក្តីជូនដំណឹង............................................................................................... ៥០

**ផ្នែកទី៤៖ កិច្ចសហប្រតិបត្តិការក្របខ័ណ្ឌជាតិ-អន្តរជាតិ**

១. សកម្មភាពផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ.........................................................៥៥

២. កិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន .............................................................៥៩

៣. កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន អង្គការ សមាគម និងស្ថាប័នអន្តរជាតិ...... ................ ៦២

**ផ្នែកទី៥៖ ការផ្សព្វផ្សាយ និងបញ្ជ្រាបវប្បធម៌បង់ពន្ធ**

១. កិច្ចការបណ្តុះបណ្តាល និងសិក្ខាសាលារបស់សាលាជាតិពន្ធដារ.........................................៧៥

២. ការស្រាវជ្រាវ អភិវឌ្ឍន៍កម្មវិធី និងបណ្ណាល័យ...........................................................៧៧

៣. សិក្ខាសាលាសំខាន់ៗ........................................................................................ ៨០

**សំណួរ និងចម្លើយ...........................................................................................៨៨**

# ទស្សនវិស័យ

អគ្គនាយកដ្ឋានពន្ធដារ ជាស្ថាប័នសាធារណៈ
ដែលត្រូវបានជឿជាក់ គោរព និងទទួលស្គាល់លើ
គុណភាពនិងជំនាញ ក្នុងការប្រមូលចំណូលពន្ធក្នុងស្រុក
ដើម្បីចូលរួមអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព

# បេសកកម្ម

អគ្គនាយកដ្ឋានពន្ធដារ ពង្រឹងការអនុវត្តច្បាប់
និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ និងផ្តល់សេវាប្រកបដោយ
ស័ក្តិសិទ្ធិភាព តម្លាភាព គណនេយ្យភាព និងសុចរិតភាព ដើម្បីធានាបាននូវប្រសិទ្ធភាព
នៃការប្រមូលចំណូលពន្ធ និងលើកកម្ពស់អនុលោមភាពដោយស្ម័គ្រចិត្ត

# គុណតម្លៃ

អគ្គនាយកដ្ឋានពន្ធដារបំពេញបេសកកម្ម និង
ធ្វើប្រតិបត្តិការរបស់ខ្លួន ដោយប្រកាន់ខ្ជាប់នូវគុណតម្លៃ ដូចខាងក្រោម ៖

| ការអនុវត្ត | វិជ្ជាជីវៈ | ស័ក្តិសិទ្ធិភាព | សុចរិតភាព | ភាពបត់បែន |
| --- | --- | --- | --- | --- |
| អនុវត្តច្បាប់ គាំទ្រ អ្នកជាប់ពន្ធដែលមាន អនុលោមភាព តែម៉ឺងម៉ាត់ ចំពោះអ្នកជាប់ពន្ធដែល មិនមានអនុលោមភាព | ប្រើប្រាស់ក្រមសីលធម៌ វិជ្ជាជីវៈ និងជំនាញ ដើម្បី ផ្តល់នូវសេវាដែលមាន ភាពសាមញ្ញ ងាយស្រួល ឆ្លាតវៃ និងនវានុវត្តន៍ | ប្រើប្រាស់ធនធាន ដោយសន្សំសំចៃ ទាន់ពេលវេលា និងចំគោលដៅ | ផ្តល់សេវាអ្នកជាប់ពន្ធ ដោយស្មើភាព តម្លាភាព និងស្អាតស្អំ | ឆ្លើយតបយ៉ាងសកម្ម ទៅនឹងបញ្ហាប្រឈម និងទាញយកប្រយោជន៍ ពីគ្រប់ឱកាសដែលមាន |

# គោលបំណង

អគ្គនាយកដ្ឋានពន្ធដារបានកំណត់ចេញនូវគោលបំណងជាយុទ្ធសាស្ត្រសំខាន់ៗ
ចំនួន៣ សម្រាប់ជាត្រីវិស័យក្នុងការតម្រង់ទិសនៃកំណែទម្រង់រដ្ឋបាលសារពើពន្ធ

| គោលបំណងទី១ | គោលបំណងទី២ | គោលបំណងទី៣ |
| --- | --- | --- |
| បង្កើនអនុលោមភាពសារពើពន្ធ តាមរយៈការលើកកម្ពស់គុណភាព ភាពច្បាស់លាស់ តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវា និង ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ | បន្តធ្វើបរិវត្តកម្មឌីជីថលរដ្ឋបាលសារពើពន្ធ ដើម្បីក្លាយជារដ្ឋបាលសារពើពន្ធ ២.០ បូក | បន្តអភិវឌ្ឍមូលធនមនុស្ស និងពង្រឹងប្រសិទ្ធភាពការងារ |

# “យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១”

## ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព
## កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០

### បាវចនា ៥៖

កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព និងចីរភាព

### អាទិភាពគន្លឹះ ៥៖

មនុស្ស, ផ្លូវ, ទឹក, ភ្លើង និងបច្ចេកវិទ្យាឌីជីថល

### គោលដៅយុទ្ធសាស្ត្រ ៥៖

១.កំណើនសេដ្ឋកិច្ច ៧% ប្រចាំឆ្នាំ ២.បង្កើនការងារ (បរិមាណ និងគុណភាព) ៣.កាត់បន្ថយភាពក្រីក្រ ៤.ពង្រឹងប្រសិទ្ធភាពការងារ និង៥.ចីរភាពនៃការអភិវឌ្ឍសង្គមជាតិនិងការកសាងភាពធន់

### ស្នូលនៃយុទ្ធសាស្ត្រ ៥៖ អភិបាលកិច្ច

១. ការកែទម្រង់ស្ថាប័ន
២. ការពង្រឹងប្រសិទ្ធភាពការងារ
៣. ការពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ
៤. ការពង្រឹងប្រសិទ្ធភាពច្បាប់ និងប្រព័ន្ធយុត្តិធម៌ និង
៥. អភិបាលកិច្ចវិស័យឯកជន

### បរិស្ថានគ្របដណ្តប់ ៥៖

១.ការបន្តពង្រឹងសន្តិភាព ស្ថិរភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ
២.ការប្រកាន់ខ្ជាប់នូវនយោបាយការបរទេសឯករាជ្យផ្អែកច្បាប់និងឈ្លាសវៃ
៣.ការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច
៤.ការកសាងភាពជាដៃគូ និង
៥.ការបន្តធ្វើសមាហរណកម្មស៊ីជម្រៅក្នុងតំបន់ និងសកលលោក

### បញ្ចកោណយុទ្ធសាស្ត្រ ៥៖

**បញ្ចកោណទី១៖** ការអភិវឌ្ឍមូលធនមនុស្ស
**បញ្ចកោណទី២៖** ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង
**បញ្ចកោណទី៣៖** ការអភិវឌ្ឍវិស័យឯកជន និងការងារ
**បញ្ចកោណទី៤៖** ការអភិវឌ្ឍប្រកបដោយភាពធន់, ចីរភាព និងបរិយាបន្ន
**បញ្ចកោណទី៥៖** ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល

### កម្មវិធីគោលនយោបាយអាទិភាព ៦ សម្រាប់ចាប់ផ្តើមអនុវត្តភ្លាមក្នុងឆ្នាំ២០២៣៖

១.ការពង្រីកសេវាថែទាំសុខភាព ឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល ២.ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេកទេស ជូនដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស ៣.ការធ្វើស្ថាបនូបនីយកម្មកម្មវិធីជាតិជំនួយសង្គម សម្រាប់គ្រួសារក្រីក្រ ក្រុមជនងាយរងគ្រោះនៅក្នុងគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យនៅក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ច និងគ្រាមានអាសន្ន ៤.ការដាក់ចេញយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ (ចូលរួមក្នុងប្រព័ន្ធនិងអាចទទួលបានផលប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមផ្លូវការ) ៥.ការដាក់ចេញនូវយន្តការសម្របសម្រួល និងកម្មវិធីហិរញ្ញប្បទាន សំដៅលើកស្ទួយផលិតកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផលសំខាន់ៗ ក្នុងកម្រិតសមរម្យ និង៦.ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ-សង្កាត់ ដែលមានសកម្មភាពកសិកម្មនៅទូទាំងប្រទេស។

### វិធានការគន្លឹះ ៥៖

១.ការពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ (ពង្រឹងគុណភាព ប្រសិទ្ធភាពនិងសមិទ្ធកម្មរបស់មន្ត្រី និងស្ថាប័ន) ២.ការលើកកម្ពស់គុណភាពអប់រំ (ពង្រឹងគុណភាពសាលារដ្ឋពីថ្នាក់មត្តេយ្យដល់មធ្យមសិក្សា-K12) ៣.ការលើកកម្ពស់គុណភាពសេវាសុខាភិបាល (ពង្រឹងសមត្ថភាពផ្តល់សេវាសុខភាពបឋមនៅមូលដ្ឋាន) ៤.ការពង្រឹងការអនុវត្តគោលនយោបាយ ”ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព (កាត់បន្ថយ និងឈានទៅដល់ការលុបបំបាត់ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀននៅក្នុងសហគមន៍) និង៥.ការពង្រឹងនិងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌។

# បរិការណ៍និងគោលការណ៍នៃការរៀបចំ
# ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

## ១. បរិការណ៍រួមនៃការរៀបចំច្បាប់ថវិកាឆ្នាំ២០២៤

ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ត្រូវបានរៀបចំឡើងក្នុងបរិការណ៍ដែលរាជរដ្ឋាភិបាលដឹកនាំដោយ **សម្ដេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**ដើម្បីបំពេញបេសកកម្មដឹកនាំប្រទេសជាតិសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា។ ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ក៏ត្រូវបានរៀបចំឡើងក្នុងគោលដៅគាំទ្រដល់ការអនុវត្តកម្មវិធីគោលនយោបាយអាទិភាពចំនួន ៦ របស់រាជរដ្ឋាភិបាលចាប់ពីដើមនីតិកាលទី៧ នេះ ព្រមទាំងវិធានការគន្លឹះសម្រាប់ដោះស្រាយបញ្ហាប្រឈមជាអាទិភាពចំនួន ៥ ទៀត ដែលត្រូវបានដាក់ចេញដោយ **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** ក្នុងកិច្ចប្រជុំពេញអង្គលើកដំបូងនៃគណៈរដ្ឋមន្ត្រីនីតិកាលទី៧ នៃរដ្ឋសភា កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ កន្លងទៅ។ បន្ថែមពីនេះ ថវិកាឆ្នាំ២០២៤ មានគោលដៅគាំទ្រការអនុវត្តកម្មវិធីនយោបាយនិងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ជាពិសេសអនុវត្តអាទិភាពគោលនយោបាយសំខាន់ៗ និងវិធានការកែទម្រង់ជាក់ស្ដែងនានា ដែលត្រូវបានដាក់ឱ្យអនុវត្តជាបន្តបន្ទាប់ចាប់ពីដើមនីតិកាលទី៧ នៃរដ្ឋសភា ឱ្យសម្រេចបាននូវលទ្ធផលផ្លែផ្កាជាអតិបរមាដើម្បីឆ្លើយតបទៅនឹងសំណូមពរ សេចក្ដីត្រូវការនិងការរំពឹងទុករបស់ប្រជាជនកម្ពុជា។

ទោះជាយ៉ាងនេះក្ដី នៅក្នុងបរិការណ៍ដែលកម្ពុជាកំពុងទទួលផលពីសុខសន្តិភាព និងស្ថិរភាពនយោបាយក្នុងប្រទេស ហើយសេដ្ឋកិច្ចក៏កំពុងងើបឡើងវិញ និងត្រឡប់ទៅរកភាពប្រក្រតីក្រោយវិបត្តិនៃជំងឺកូវីដ-១៩ កម្ពុជាក៏នៅមានបញ្ហាប្រឈមជារចនាសម្ព័ន្ធខាងក្នុងមួយចំនួន ដែលធ្វើឱ្យដំណើរការពិពិធកម្មសេដ្ឋកិច្ចមិនទាន់អាចសម្រេចបានក្នុងល្បឿនខ្ពស់តាមការរំពឹងទុក ហើយភាពប្រកួតប្រជែងក៏នៅមានកម្រិត។ ម្យ៉ាងទៀត កម្ពុជាក៏ដូចជាបណ្ដាប្រទេសដទៃទៀតលើសកលលោកកំពុងមានភាពមិនប្រាកដប្រជាខ្ពស់ពីកត្តាខាងក្រៅមានជាអាទិ៍៖ ភាពតានតឹងនៃភូមិសាស្ត្រនយោបាយ, កំណើនទាបនៃសេដ្ឋកិច្ចសកលដែលបណ្ដាលមកពីសង្គ្រាមពាណិជ្ជកម្ម,ការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់ប្រទេសអភិវឌ្ឍន៍ក្នុងការឆ្លើយតបទៅនឹងសម្ពាធអតិផរណា, ការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន, បញ្ហាសង្គ្រាមអ៊ីស្រាអែល-ហាម៉ាសក៏ដូចជាបញ្ហាកំណើនទាបនៃសេដ្ឋកិច្ចចិន។ ជារួម ហានិភ័យនិងបញ្ហាប្រឈមទាំងនេះ បាននិងកំពុងបង្កផលប៉ះពាល់លើពាណិជ្ជកម្មអន្តរជាតិ និងលំហូរនៃការវិនិយោគមកកម្ពុជា ដែលអាចយាយីដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការស្ដារសេដ្ឋកិច្ចឡើងវិញ ក៏ដូចជាអាចប៉ះទង្គិចដល់គន្លងនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជាឆ្ពោះទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

ក្នុងបរិការណ៍នេះ ថវិកាឆ្នាំ២០២៤ ត្រូវបានគិតគូរ និងរៀបចំឡើងដើម្បីទ្រទ្រង់ដល់ការថែរក្សានូវសមិទ្ធផលនានា ដែលសម្រេចបានមកដោយលំបាកក៏ដូចជាការអនុវត្តអាទិភាពគោលនយោបាយសំខាន់ៗ និងវិធានការកែទម្រង់ ជាក់ស្ដែងនានា ដែលនឹងត្រូវអនុវត្តចាប់ពីដើមនីតិកាលទី៧ នៃរដ្ឋសភា និងក្នុងឆ្នាំ២០២៤ ដើម្បីឆ្លើយតបទៅនឹងបរិការណ៍ថ្មីរបស់កម្ពុជា ទាំងក្នុងក្របខ័ណ្ឌផ្ទៃក្នុងប្រទេស និងក្នុងក្របខ័ណ្ឌតំបន់និងពិភពលោក ជាពិសេសដើម្បីសម្រេចឱ្យបាន

ជាអតិបរមានូវគោលដៅជាយុទ្ធសាស្ត្រទាំង ៥ ដូចមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដើម្បីកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ដែលជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។

ជាមួយគ្នានេះដែរ ថវិកាឆ្នាំ២០២៤ ក៏បានផ្តោតការយកចិត្តទុកដាក់លើអាទិភាពគន្លឹះចំនួន ៥ នៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដោយក្នុងនោះ មនុស្សត្រូវបានបន្តកំណត់យកជាអាទិភាពគន្លឹះទី១ ហើយ ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា ជាអាទិភាពគន្លឹះបន្តបន្ទាប់តាមលំដាប់ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នាដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងទិសដៅនៃការអភិវឌ្ឍកម្ពុជាក្នុងដំណាក់កាលថ្មីខាងមុខ ដែលរួមមាន៖ ១.ការអភិវឌ្ឍមូលធនមនុស្ស ២.ការធ្វើពិពិធកម្មសេដ្ឋកិច្ចនិងការបង្កើនភាពប្រកួតប្រជែង ៣.ការអភិវឌ្ឍវិស័យឯកជននិងការងារ ៤.ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន និង ៥.ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល។

## ២. គោលការណ៍សំខាន់ៗនៃការរៀបចំច្បាប់ថវិកាឆ្នាំ២០២៤

**ថវិកាឆ្នាំ២០២៤ ត្រូវបានរៀបចំឡើងដោយផ្អែកលើគោលការណ៍គ្រឹះជាយុទ្ធសាស្ត្រសំខាន់ៗ ដូចខាងក្រោម៖**

១. គោរពឱ្យបាននូវក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចដែលត្រូវបានកំណត់ ជាពិសេសគាំទ្រដល់ការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់នូវវិធានការគោលនយោបាយគន្លឹះដែលត្រូវបានដាក់ចេញ ដើម្បីសម្រេចគោលដៅនៃកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៦,៦% ដែលជាមូលដ្ឋានមិនអាចខ្វះបាន ដើម្បីបង្កើតការងារថ្មីកាន់តែច្រើនជូនប្រជាជន, ជាពិសេសសម្រាប់យុវជន, និងផ្តល់លទ្ធភាពកាន់តែច្រើនឱ្យប្រជាជនទទួលបានប្រាក់ចំណូលកាន់តែខ្ពស់ផង ក៏ដូចជាដើម្បីបង្កើនចំណូលថវិកាជាតិផងដែរ។

២. រក្សាតុល្យភាព និងចីរភាពថវិកា ពោលគឺរក្សាតុល្យភាពនៃតម្រូវការចំណាយ ដោយផ្អែកលើលទ្ធភាពចំណូលថវិកា ដែលមានប្រភពពីការប្រមូលចំណូលក្នុងប្រទេស ដោយចៀសវាងការដកប្រាក់សន្សំរបស់រាជរដ្ឋាភិបាលយកមកប្រើ ទន្ទឹមនឹងការពង្រឹងការគ្រប់គ្រង ការខ្ចីក្នុងនិងក្រៅប្រទេស ដោយប្រកាន់ខ្ជាប់នូវគោលការណ៍វិន័យគន្លឹះទាំង ៥ ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ។

៣. ធានាចីរភាព និងសមិទ្ធកម្មនៃចំណូលដើម្បីសម្រេចបាននូវគោលដៅនៃការប្រមូលចំណូលតាមការកំណត់ក៏ដូចជាដើម្បីឆ្លើយតបនឹងតម្រូវការចំណាយថវិកាជាតិនៅក្នុងឆ្នាំ២០២៤ ក្រសួង-ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលដែលទទួលបន្ទុកកៀរគរចំណូលមិនមែនសារពើពន្ធ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលទទួលបន្ទុកកៀរគរចំណូលសារពើពន្ធ ចាំបាច់ត្រូវបន្តរក្សាចលនការនៃកិច្ចប្រឹងប្រែងក្នុងការកៀរគរចំណូលថវិកាឱ្យអស់សក្តានុពល, ទន្ទឹមនឹងការបន្តរក្សានូវភាពប្រយ័ត្នប្រយែង ដោយចៀសវាងនូវការបង្កផលប៉ះពាល់ជាអវិជ្ជមានដល់ការរស់នៅរបស់ប្រជាជន ការធ្វើធុរកិច្ច ព្រមជាមួយនឹងការបន្តខិតខំពង្រឹងអភិបាលកិច្ច និងយុត្តិធម៌ក្នុងការផ្តល់សេវា និងការប្រមូលពន្ធដារ។

៤. តម្កល់"មនុស្ស"ជាអាទិភាពទី១ ដោយផ្តោតលើ៖ ១.ការបន្តដំឡើងបៀវត្សជូនមន្ត្រីរាជការក្នុងគោលដៅលើកកម្ពស់ជីវភាពរស់នៅ និងបង្កើនផលិតភាពការងារ ២.ការពង្រឹងគុណភាព ប្រសិទ្ធភាព និងសមិទ្ធកម្មរបស់មន្ត្រី

និងស្ថាប័ន ដោយដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម ជាពិសេសផ្តល់ការលើកទឹកចិត្តចំពោះមន្ត្រីដែលមានគុណវុឌ្ឍិ ៣.ការលើកកម្ពស់គុណភាពអប់រំ និងគុណភាពសេវាសុខាភិបាល តាមរយៈការដាក់ឱ្យអនុវត្តនូវវិធានការគន្លឹះជាក់ស្តែងនានា ៤.ការដំឡើងប្រាក់សោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ជាពិសេសការកាត់បន្ថយគម្លាតប្រាក់សោធនរវាងអ្នកចូលនិវត្តចាស់និងថ្មី និង ៥.ការពង្រឹងនិងការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ គាំពារសង្គម សំដៅកសាងភាពធន់រឹងមាំប្រកបដោយចីរភាពនៃវិស័យមូលធនមនុស្សនិងសង្គម។

៥. ធ្វើវិចារណកម្មលំដាប់អាទិភាពតាមរយៈ ១.ការបន្តប្រកាន់ខ្ជាប់នូវការលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជថវិកាដោយផ្តោតការយកចិត្តទុកដាក់ទៅលើវិស័យអាទិភាព ជាពិសេសតម្រង់លើកម្មវិធី/សកម្មភាពចាំបាច់ជាអាទិភាពរបស់ក្រសួង-ស្ថាប័ន ស្របតាមកម្មវិធីគោលនយោបាយអាទិភាពដែលបានដាក់ចេញដើម្បីអនុវត្តភ្លាមពីដើមនីតិកាលនិងវិធានការគន្លឹះរបស់រាជរដ្ឋាភិបាល ដែលត្រូវដោះស្រាយនៅក្នុងនីតិកាលទី៧ នៃរដ្ឋសភា និង២.ការជំរុញអនុវត្តវិធានការបច្ចេកទេសលម្អិតចំនួន ៤ រួមមាន៖ (ក).តម្រង់ការបែងចែកថវិកាឱ្យបានត្រឹមត្រូវនិងចំគោលដៅ ដោយមិនផ្តល់ថវិកាសម្រាប់មុខចំណាយមិនចាំបាច់ និងចំណាយលែងចាំបាច់ (ខ).រឹតបន្តឹងខ្លាំងក្នុងការផ្តល់ថវិកាសម្រាប់មុខចំណាយមិនសូវចាំបាច់ (គ).បន្តផ្តល់ថវិកាចំពោះមុខ ចំណាយដែលចាំបាច់សម្រាប់ការអនុវត្តសកម្មភាពអាទិភាព និង (ឃ).ហ៊ានចាយបន្ថែមលើមុខចំណាយដែលចាំបាច់ខ្លាំង។

៦. កែលម្អការរៀបចំកម្មវិធី/សកម្មភាព ដោយបន្តគិតគូរឱ្យកាន់តែម៉ត់ចត់លើភាពសមស្របនៃថ្លៃបរិមាណ និងគុណភាពក្នុងការអនុវត្តកម្មវិធីសកម្មភាពក្នុងគោលដៅបន្តលើកកម្ពស់បន្ថែមនូវប្រសិទ្ធភាពនៃការវិភាជថវិកាក៏ដូចជាគុណភាពនៃសូចនាករគន្លឹះ។

៧. ផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្ត ពោលគឺជំរុញនិងបង្កើនការផ្ទេរថវិកាឱ្យទៅដល់អង្គភាពថវិកា ជាពិសេសតាមសាលារៀន មន្ទីរពេទ្យ និងមណ្ឌលសុខភាព ទន្ទឹមនឹងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការទទួលខុសត្រូវ នៅនឹងកន្លែង។

៨. ផ្សារភ្ជាប់រវាងការប្រមូលចំណូល និងការវិភាជថវិកា ដោយផ្សារភ្ជាប់ការវិភាជថវិកាទៅនឹងលទ្ធផលនៃការអនុវត្តចំណូល ជាពិសេសផ្តល់អាទិភាពចំណាយមិនមែនបុគ្គលិកដល់ក្រសួង-ស្ថាប័ន ដែលកៀរគរចំណូលដោយការខិតខំធ្វើសកម្មភាពរបស់ខ្លួនផ្ទាល់។ ទន្ទឹមនឹងនេះ ក៏លើកទឹកចិត្តឱ្យក្រសួង-ស្ថាប័នដែលទទួលបានរង្វាន់ពីការផ្តល់សេវាសាធារណៈ ប្រើប្រាស់ប្រាក់រង្វាន់ប្រកបដោយតម្លាភាព ដោយបែងចែកប្រាក់រង្វាន់ក្នុងទំហំសមស្របសម្រាប់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន៕

**(ដកស្រង់និងកែសម្រួល ពីខ្លឹមសារសង្ខេបប្រតិបត្តិស្តីពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ និងថវិកាសង្ខេប ឆ្នាំ២០២៤ របស់នាយកដ្ឋានថវិកានីយកម្ម នៃអគ្គនាយកដ្ឋានថវិកា)**

# ព្រឹត្តិការណ៍សំខាន់ៗ



អគ្គនាយកដ្ឋានពន្ធដារបានបង្ហាញពីសមិទ្ធផលសំខាន់ៗនៃកិច្ចអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មានក្នុងពិព័រណ៍រដ្ឋាភិបាលឌីជីថលនិងបច្ចេកវិទ្យាឌីជីថលកម្ពុជា-អន្តរជាតិ នៃវេទិការដ្ឋាភិបាលឌីជីថល

សូមអានពិស្តារនៅទំព័រទី ១១




អ្នកជាប់ពន្ធប្រមាណ ៩០% ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ

សូមអានពិស្តារនៅទំព័រទី ១៣



កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រមូលចំណូលពន្ធប្រចាំខែធ្នូ និងប្រចាំឆ្នាំ២០២៣ ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្តរបស់អគ្គនាយកដ្ឋានពន្ធដារ

សូមអានពិស្តារនៅទំព័រទី ១៥



ជំនួបពិភាក្សាការងារជាមួយក្រុមបេសកកម្មនៃមូលនិធិរូបិយវត្ថុអន្តរជាតិ

សូមអានពិស្តារនៅទំព័រទី ១៧




សិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំនិងកម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ ( GDT e-Administration )"

សូមអានពិស្តារនៅទំព័រទី ២០



ពិធីចុះសួរសុខទុក្ខនាយទាហាន ពលទាហាន គ្រួសារទ័ពនិងសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវសមិទ្ធផលនានានៅបញ្ជាការដ្ឋានរថក្រោះកងទ័ពជើងគោក និងកងការពារព្រំដែន៥០១

សូមអានពិស្តារនៅទំព័រទី ២៣

# អគ្គនាយកដ្ឋានពន្ធដារបានបង្ហាញពីសមិទ្ធផលសំខាន់ៗ នៃកិច្ចអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មានក្នុងពិព័រណ៍រដ្ឋាភិបាលឌីជីថល និងបច្ចេកវិទ្យាឌីជីថលកម្ពុជា-អន្តរជាតិ នៃវេទិការដ្ឋាភិបាលឌីជីថល



*សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

នាថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចូលរួមតាំងបង្ហាញពីសមិទ្ធផលសំខាន់ៗនៃកិច្ចអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន ក្នុងពិព័រណ៍រដ្ឋាភិបាលឌីជីថល និងបច្ចេកវិទ្យាឌីជីថលកម្ពុជា-អន្តរជាតិ នៃវេទិការដ្ឋាភិបាលឌីជីថល (Digital Government Forum "DGF") ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

ដោយមើលឃើញពីសារសំខាន់នៃបច្ចេកវិទ្យាឌីជីថលក្នុងយុគសម័យបរិវត្តកម្មឌីជីថលរាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលកន្លងមក ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានដាក់ចេញនូវគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលដើម្បីជំរុញដល់កិច្ចអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកម្ពុជាឱ្យរីកចម្រើនជឿនលឿនជាលំដាប់។ រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧ នៃរដ្ឋសភា ដែលមាន**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ជាប្រមុខដឹកនាំ បានសម្រួចមុំការងាររបស់រាជរដ្ឋាភិបាលលើឌីជីថលកាន់តែច្បាស់លាស់ក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ក្នុងនោះបញ្ចកោណទី៥ បានផ្តោតលើការអភិវឌ្ឍសេដ្ឋកិច្ចនិងវិស័យឌីជីថល។ ស្របជាមួយនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ បាននិងកំពុងជំរុញនិងបង្កើនល្បឿននៃការធ្វើបរិវត្តកម្មរដ្ឋបាលសារពើពន្ធ (Transformation of Tax Administration) និងធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានប្រកបដោយស្មារតីបុរេសកម្ម តាមរយៈការអភិវឌ្ឍនិងធ្វើបច្ចុប្បន្នភាព ព្រមទាំងបន្តវិនិយោគនិងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងពង្រឹងសមត្ថភាពមុខងារវិភាគទិន្នន័យបន្ថែមទៀត ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងប្រមូលចំណូលពន្ធ ជាពិសេសប្រើប្រាស់បច្ចេកវិទ្យាទំនើបក្នុងការផ្តល់សេវាអ្នកជាប់ពន្ធឱ្យកាន់តែមានភាពគ្រប់ជ្រុងជ្រោយ និងងាយស្រួលក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ៕


HIEVEMENTS


General Department of Customs and Excise of Cambodia
អគ្គនាយកដ្ឋានពន្ធដារ
General Department of Taxation


វិក្កយបត្រ
នាំសំណាង

# អ្នកជាប់ពន្ធប្រមាណ ៩០% ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន របស់អគ្គនាយកដ្ឋានពន្ធដារក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ




នាថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ ក្នុងកិច្ចពិភាក្សាលើប្រធានបទ "**ការចាប់យកសេវាសាធារណៈឌីជីថល**" នៃវេទិការដ្ឋាភិបាលឌីជីថល ឯកឧត្តម **គន់ និមល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានបញ្ជាក់ឱ្យដឹងថា ក្នុងអាណត្តិនៃការដឹកនាំរបស់ឯកឧត្តម ដោយគិតចាប់ពីអំឡុងឆ្នាំ២០១៣ រហូតមកដល់បច្ចុប្បន្ន អគ្គនាយកដ្ឋានពន្ធដារ បាននិងកំពុងខិតខំកែទម្រង់មុតស្រួច ជាមួយនឹងការដកស្រង់ពិសោធន៍និងការរៀនសូត្របច្ចេកទេសថ្មីៗពីរដ្ឋបាលសារពើពន្ធនៃប្រទេសមួយចំនួន ដើម្បីធ្វើបរិវត្តកម្មរដ្ឋបាលសារពើពន្ធឱ្យក្លាយជារដ្ឋបាលសារពើពន្ធទំនើបដើរទាន់យុគសម័យឌីជីថល និងប្រកបដោយសមត្ថភាពកម្រិតវិជ្ជាជីវៈខ្ពស់ ដែលផ្តល់លទ្ធភាពនិងមធ្យោបាយល្អប្រសើរសម្រាប់អ្នកជាប់ពន្ធក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ។

ជាលទ្ធផល បច្ចុប្បន្នមានអ្នកជាប់ពន្ធប្រមាណ ៩០% ហើយដែលកំពុងប្រើប្រាស់ប្រព័ន្ធ-កម្មវិធីអេឡិចត្រូនិករបស់អគ្គនាយកដ្ឋានពន្ធដារក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធរបស់ខ្លួនប្រកបដោយភាពត្រឹមត្រូវ ងាយស្រួល និងចំណេញពេលវេលា។ ជាមួយគ្នានេះ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ ក៏បានលើកឡើងផងដែរថា ការចាប់យកប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ជាមធ្យោបាយក្នុងការផ្តល់សេវាអ្នកជាប់ពន្ធនេះ មិនត្រឹមតែសម្រួលដល់ការបំពេញកាតព្វកិច្ចសារពើពន្ធរបស់អ្នកជាប់ពន្ធប៉ុណ្ណោះទេ ថែមទាំងជួយបញ្ចៀសហានិភ័យកើតឡើងដោយឥតព្រាងទុកមួយចំនួនទៀត ជាក់ស្តែង ស្ថិតក្នុងដំណាក់កាលនៃវិបត្តិជំងឺកូវីដ-១៩ ទោះបីជាមានការបិទខ្ទប់និងបម្រាមក្នុងការធ្វើដំណើរយ៉ាងណាក្តី ការប្រមូលចំណូលពន្ធនៅតែរក្សាបានស្ថិរភាពគួរឱ្យកត់សម្គាល់៕






DIGITAL PUBLIC SERVICE ADOPTIONS
Advisor to the Ministry of Planing and
Deputy Director General of General
Department of Identification,
Ministry of Interior
PANELIST
H.E. Kith Chankrisna
Under Secretary of State, Ministry of
Land Management, Urban Planning
and Construction
PANELIST
H.E Kong Vibol
PANELIST
H.E. Heang Sotheayuth
PANELIST
Mr. Ouk Sarat
Deputy Director General of Banking
Operation Directorate and Director of
Payment System Department,
National Bank of Cambodia.
PANELIST


វេទិការដ្ឋាភិបាលឌីជីថល
DIGITAL GOVERNMENT FORUM

# កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រមូលចំណូលពន្ធ ប្រចាំខែធ្នូ និងប្រចាំឆ្នាំ២០២៣ ព្រមទាំងទិសដៅសម្រាប់ អនុវត្តបន្តរបស់អគ្គនាយកដ្ឋានពន្ធដារ




*ឯកឧត្តម **អ៊ុង លុយណា**, ឯកឧត្តម **គុណ ញឹម**, ឯកឧត្តម **គង់ វិបុល**, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**, ឯកឧត្តមបណ្ឌិតសភាចារ្យ **ជូ វិជិត្ត**, ឯកឧត្តម **ជា វុធណា** (រូបពីឆ្វេងទៅស្តាំ)*

នាព្រឹកថ្ងៃអង្គារ ទី២៣ ខែមករា ឆ្នាំ២០២៤ នៅសាលប្រជុំសាលាជាតិពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារគ្រប់គ្រងប្រមូលចំណូលពន្ធប្រចាំខែធ្នូ និងប្រចាំឆ្នាំ២០២៣ ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្តរបស់អគ្គ-នាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការចូលរួមពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងមានការចូលរួមដោយផ្ទាល់និងតាមប្រព័ន្ធអនឡាញ (Zoom Meeting) ពីថ្នាក់ដឹកនាំនិងមន្ត្រីរាជការពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ នៅទូទាំងប្រទេស។

ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានធ្វើសេចក្តីរាយការណ៍ជូនអង្គប្រជុំថាស្របតាមយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ព្រមទាំងប្រកាន់ខ្ជាប់នូវអភិក្រមការងារទាំង៥ របស់ **សម្តេចតេជោ ហ៊ុន សែន "ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់"** និងអភិក្រមការងារទាំង៤ របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី ក្នុងនោះ ទី១.អនុវត្តការងារប្រកបដោយវិជ្ជាជីវៈ និងគោរពក្រមសីលធម៌វិជ្ជាជីវៈ ទី២.អនុវត្តការងារជាក្រុម ទី៣.អនុវត្តការងារដោយប្រកាន់ខ្ជាប់ស្មារតីបុរេសកម្មនិងគោលការណ៍ ប្រសិទ្ធភាពថវិកា និងទី៤.មិនត្រូវមើលរំលងកំហុសខ្លួនឯងជាត្រីវិស័យក្នុងការតម្រង់ទិស អគ្គនាយកដ្ឋានពន្ធដារ បាននិងកំពុងរៀបចំ និងអនុវត្តនូវផែនការយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានពន្ធដារ ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រធនធានមនុស្ស ២០១៩-២០២៣ ព្រមទាំងខិតខំអនុវត្តប្រកបដោយការយកចិត្តទុកដាក់និងប្រយ័ត្នប្រយែងខ្ពស់ ដើម្បីធានាបាននូវប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងប្រមូលចំណូលពន្ធសម្រាប់ដាក់ចូលថវិកាជាតិ។ ជាក់ស្តែង លទ្ធផលនៃការប្រមូលចំណូលពន្ធសម្រេចបានក្នុងរយៈពេល ៥ឆ្នាំ នៃយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ គឺឆ្នាំ២០១៩ ទទួលបាន **១១ ២៧៧,៣២ ប៊ីលានរៀល** ស្មើនឹង **១២៣,២០%** ឆ្នាំ២០២០ ទទួលបាន **១១ ៧០០,៥២ ប៊ីលានរៀល** ស្មើនឹង **១០១,៣៦%** ឆ្នាំ២០២១ ទទួលបាន **១១ ២៦៦,៧៩ ប៊ីលានរៀល** ស្មើនឹង **១២៤,០២%** ឆ្នាំ២០២២ ទទួលបាន **១៣ ៩៩៣,២០ ប៊ីលានរៀល** ស្មើនឹង **១២២,៥៤%** និងឆ្នាំ២០២៣ ទទួលបាន **១៤ ៦២៩,១០ ប៊ីលានរៀល**

ស្មើនឹង **១០១,១៣%**។ ចំពោះលទ្ធផលប្រមូលចំណូលពន្ធក្នុងខែធ្នូ ឆ្នាំ២០២៣ អគ្គនាយកដ្ឋានពន្ធដារ ប្រមូលចំណូលពន្ធអាករបានចំនួន **១ ០៧២,៣១ ប៊ីលានរៀល (ប្រមាណជា ២៦៤,៧៧ លានដុល្លារ)** ស្មើនឹង **៧,៤១%** នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។ សរុបរយៈពេល ១២ខែ ឆ្នាំ២០២៣ ចំណូលពន្ធអាករ ដែលប្រមូលបានមានចំនួន **១៤ ៦២៩,១០ ប៊ីលានរៀល (ប្រមាណជា ៣ ៦១២,១២ លានដុល្លារ)** ស្មើនឹង **១០១,១៣%** នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ២០២២ កើនឡើងចំនួន **៦២៨,២៨ ប៊ីលានរៀល (ប្រមាណជា ១៥៥,១៣ លានដុល្លារ)** ស្មើនឹង **៤,៤៩%**។ លទ្ធផលដ៏ជោគជ័យនិងជាទីមោទនៈ នេះ គឺជាការចូលរួមចំណែកដ៏សំខាន់ក្នុងការបន្តអភិវឌ្ឍប្រទេសជាតិ។

បន្ទាប់ពីបានស្តាប់របាយការណ៍លម្អិតគ្រប់ជ្រុងជ្រោយរួចមក ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានវាយតម្លៃខ្ពស់ ចំពោះអគ្គនាយកដ្ឋានពន្ធដារដែលជាស្ថាប័នប្រមូលចំណូលដ៏សំខាន់បំផុតសម្រាប់ជាតិ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងមន្ត្រីរាជការពន្ធដារទាំងអស់ដែលចូលរួមចំណែកបំពេញភារកិច្ចអស់ពីកម្លាំងកាយចិត្ត សម្រេចបានលទ្ធផលនៃការធ្វើទំនើបភាវូបនីយកម្មស្ថាប័ន និងការគ្រប់គ្រងប្រមូលចំណូលពន្ធយ៉ាងល្អប្រសើរឱ្យសម្រេចបានលើសផែនការ ទោះបីជាស្ថិតក្នុងសភាពការណ៍លំបាកប្រឈមនឹងហានិភ័យ ភាពមិនប្រាកដប្រជានៃស្ថានភាពសេដ្ឋកិច្ច និងនយោបាយសកលយ៉ាងណាក៏ដោយ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ បានដាក់ចេញនូវអនុសាសន៍សំខាន់ៗលើទិដ្ឋភាព ២ ផ្នែក រួមមាន ផ្នែកទី១.កិច្ចការចំពោះមុខ (រយៈពេលខ្លី ឆ្នាំ២០២៤) ផ្អែកលើសភាពការណ៍សេដ្ឋកិច្ច-សង្គម ទោះបីការរំពឹងទុកកំណើនសេដ្ឋកិច្ចជាវិជ្ជមាន យ៉ាងណាក្តី ភាពមិនប្រាកដប្រជានៅមានច្រើន គឺស្តែងចេញជាបញ្ហាប្រឈមនិងសម្ពាធ ដែលតម្រូវឱ្យយើងត្រៀមខ្លួនអនុវត្តដោយយកចិត្តទុកដាក់ជាមួយអ្នកជាប់ពន្ធ និងត្រូវប្រឹងប្រែងឱ្យកាន់តែខ្លាំងក្លាជាងមុន ទាំងផ្នែកគោលនយោបាយ ភាពទន់ភ្លន់ និងផែនការសកម្មភាព។ ផ្នែកទី២. កិច្ចការរយៈពេលវែង (គោលដៅឆ្នាំ២០២៨) ជំរុញនិងគាំទ្រអគ្គនាយកដ្ឋានពន្ធដារឱ្យក្លាយទៅជា Tax Administration 2.5 ដែលក្នុងបរិការណ៍នេះ ការបង្កើនល្បឿននៃកិច្ចការកែទម្រង់ គឺជាអភិក្រមនៃការដោះស្រាយបញ្ហានានា។ បន្ថែមពីលើនេះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ បានផ្តល់នូវធាតុចូលប្រកបដោយខ្លឹមសារនិងចក្ខុវិស័យគ្រប់ជ្រុងជ្រោយបន្ថែមទៀតសម្រាប់យុទ្ធសាស្ត្រកៀរគរចំណូល ២០២៤-២០២៨៕




*ឯកឧត្តម **ជាប ដារុធ**, ឯកឧត្តម **កែន សម្បត្តិ**, លោកជំទាវ **ប៊ុន នារី**, លោក **លីម ដឹលុច** (រូបពីឆ្វេងទៅស្តាំ)*

# ជំនួបពិភាក្សាការងារ
# ជាមួយក្រុមបេសកកម្ម នៃមូលនិធិរូបិយវត្ថុអន្តរជាតិ




*ជំនួបពិភាក្សាការងារជាមួយក្រុមបេសកកម្មនៃមូលនិធិ រូបិយវត្ថុ អន្តរជាតិ ក្រោមអធិបតីភាពឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ*

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី១៤ ខែមីនា ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អមដោយលោកជំទាវ **ម៉ុន នារី** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ បានទទួលជួបពិភាក្សាការងារជាមួយក្រុមបេសកកម្មនៃមូលនិធិរូបិយវត្ថុ អន្តរជាតិ (International Monetary Fund – IMF) ដឹកនាំដោយ លោក Davide Furceri ប្រធានក្រុមបេសកកម្មទទួលបន្ទុកប្រទេសកម្ពុជា និងសេដ្ឋវិទូជាន់ខ្ពស់នៃមូលនិធិរូបិយវត្ថុអន្តរជាតិ IMF ព្រមទាំងមានវត្តមានចូលរួមពីលោក **សេង ជាសិទ្ធ** ប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ (ន.នគសអ) លោក **តែ ហ៊្សីឌី** ប្រធាននាយកដ្ឋានសវនកម្មសហគ្រាស តំណាងនាយកដ្ឋានថ្នាក់កណ្តាល និងមន្ត្រីជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ បានលើកឡើងអំពីកិច្ចសហប្រតិបត្តិការដ៏ល្អនាពេលកន្លងមក រវាងអគ្គនាយក-ដ្ឋានពន្ធដារ និងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដែលតែងតែជួបប្រជុំជាប្រចាំ ដើម្បីពិភាក្សាអំពីការវិវត្តនៃទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច ស្ថានភាពនៃការប្រមូលចំណូលពន្ធ និងគោលនយោបាយនានាពាក់ព័ន្ធ នឹងពន្ធដារដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា។

ជាកិច្ចឆ្លើយតប លោកប្រធានក្រុមបេសកកម្ម បានសាទរចំពោះលទ្ធផលល្អប្រសើរនៃការប្រមូលចំណូលពន្ធដែលអគ្គនាយកដ្ឋានពន្ធដារសម្រេចបាន ជាមួយនឹងការរក្សាបាននូវកំណើនជារៀងរាល់ឆ្នាំសម្រាប់រយៈពេលជាងមួយទសវត្សរ៍ចុងក្រោយនេះ ក៏ដូចជាកិច្ចខិតខំបន្តធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ចនៅកម្ពុជា។

ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ បានអនុញ្ញាតឱ្យលោក **ម៉ុខ ឡាមី** ប្រធានការិយាល័យនៃ ន.នគសអ ធ្វើបទបង្ហាញជូនដល់អង្គប្រជុំដោយផ្តោតលើប្រធានបទសំខាន់ៗ ដូចខាងក្រោម៖

- ការគ្រប់គ្រងប្រមូលចំណូលពន្ធសម្រាប់ឆ្នាំ២០២៣ និងទស្សនវិស័យសម្រាប់ឆ្នាំ២០២៤៖ ១.ការប្រមូលចំណូលពន្ធដែលមានកំណើនរៀងរាល់ឆ្នាំ ពោលគឺចាប់ពីឆ្នាំ២០១៣ រហូតដល់ឆ្នាំ២០២៣ ហើយក្នុងឆ្នាំ២០២៣ កន្លងទៅ អគ្គនាយកដ្ឋានពន្ធដារសម្រេចបានចំនួន **១៤ ៦២៨,៩ ប៊ីលានរៀល (ប្រមាណជា ៣ ៦១២,១ លានដុល្លារ)**

ពេលគឺស្មើនឹង **១០១,១៣%** នៃផែនការច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២៣ ២.លទ្ធផលនៃការប្រមូលចំណូលពន្ធសម្រាប់រយៈពេល ២ខែដើមឆ្នាំ២០២៤ និង៣.ទស្សនវិស័យ នៃការប្រមូលចំណូលពន្ធសម្រាប់ឆ្នាំ២០២៤ និងបញ្ហាប្រឈមនានានៃសកម្មភាពសេដ្ឋកិច្ច

- វិធានការ និងគោលនយោបាយសារពើពន្ធថ្មីៗសម្រាប់រយៈពេលមធ្យម៖ វិធានការលើកទឹកចិត្តផ្នែកពន្ធដារដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល-វិស័យឯកជន លើកទី១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដោយបន្តលើកលែងពន្ធ ការអនុគ្រោះពន្ធបន្ថែមទៀត ការពន្យារ និងពន្យារការអនុវត្តប្រភេទពន្ធមួយចំនួន ដើម្បីដោះស្រាយនូវក្ដីកង្វល់របស់ប្រជាពលរដ្ឋ និងសម្រួលដល់ការធ្វើធុរកិច្ច រួមមាន៖ ១.ការបន្ធូរបន្ថយ និងអនុគ្រោះចំពោះពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ការពន្យារពេលអនុវត្តពន្ធលើចំណេញមូលធន និងការលើកលែងទណ្ឌកម្មរដ្ឋបាលសម្រាប់ពន្ធលើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់ ២.ការពន្យារជាបណ្ដោះអាសន្ននូវការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែសម្រាប់សហគ្រាស ស្ថិតក្រោមគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ៣.ការលើកលែងទណ្ឌកម្មរដ្ឋបាលចំពោះការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត និង៤.ការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់វិស័យកសិកម្ម និងវិស័យទេសចរណ៍ជាដើម
- ការធ្វើសវនកម្មពន្ធដារលើសហគ្រាសធុនមធ្យមនិងធំ ព្រមទាំងវិធានការពង្រឹងអនុលោមភាពសារពើពន្ធ៖ ១.លទ្ធផលនៃការធ្វើសវនកម្មក្នុងឆ្នាំ២០២២ និងឆ្នាំ២០២៣ ២.វិធានការចាំបាច់ក្នុងការពង្រឹងអនុលោមភាពសារពើពន្ធ ដោយផ្ដោតទៅលើការធ្វើសវនកម្មលើអ្នកជាប់ពន្ធដែលមានហានិភ័យខ្ពស់ ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការធ្វើសវនកម្ម កិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងការចែករំលែកព័ត៌មាន ការពង្រឹងសវនកម្មពេញលេញលើក្រុមហ៊ុនស្នើសុំបិទដើម្បីចៀសវាងការគេចវេះពន្ធ ការពង្រឹងសមត្ថភាពសវនករក្នុងការធ្វើសវនកម្មលើប្រតិបត្តិការឆ្លងព្រំដែននិងការផ្ទេរថ្លៃ ការពង្រឹងអនុលោមភាពសារពើពន្ធដោយស្ម័គ្រចិត្ត ការពង្រឹងកិច្ចការប្រមូលបំណុលពន្ធ និងការពង្រឹងសេវាអ្នកជាប់ពន្ធនិងផ្សព្វផ្សាយបទប្បញ្ញត្តិថ្មីៗពាក់ព័ន្ធនឹងពន្ធដារ និង៣.ការពង្រឹងយន្តការធ្វើសវនកម្ម ដោយបានរៀបចំនូវសៀវភៅណែនាំស្ដីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ សម្រាប់មន្ត្រីរាជការពន្ធដារ និងអ្នកជាប់ពន្ធ ដោយបានកំណត់នូវនិយាមនីតិវិធីប្រតិបត្តិការងារ (Standard Operating Procedure – SOP) ដើម្បីឱ្យមានសង្គតិភាព ភាពច្បាស់លាស់អំពីនីតិវិធី ពេលវេលា និងការផ្ដល់ឯកសារសម្រាប់ធ្វើសវនកម្ម ព្រមទាំងនីតិវិធីនៃការស្នើសុំតវ៉ាលើការកំណត់ពន្ធឡើងវិញ
- ការលើកទឹកចិត្តផ្នែកពន្ធដារដែលមានស្រាប់៖ ការលើកទឹកចិត្តផ្នែកពន្ធដារក្រោមច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ការលើកទឹកចិត្តក្នុងតំបន់សេដ្ឋកិច្ចពិសេស កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ការលើកទឹកចិត្តដល់សហគ្រាសធុនតូចនិងមធ្យម និងការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យអប់រំ វាយនភណ្ឌកាត់ដេរ មូលបត្រ កសិកម្ម និងទេសចរណ៍ជាដើម ក្នុងគោលដៅជំរុញនិងបង្កើនបរិយាកាសវិនិយោគ និងការធ្វើធុរកិច្ចនៅកម្ពុជាឱ្យកាន់តែមានភាពទាក់ទាញ
- យុទ្ធសាស្ត្រ និងវិធានការទាក់ទិននឹងពន្ធដារសម្រាប់រយៈពេលមធ្យម៖ ការបន្តពង្រឹងនិងអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលសារពើពន្ធ តាមរយៈការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ ការរៀបចំផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ និងការចូលរួមរៀបចំយុទ្ធសាស្ត្រកៀរគរចំណូល ២០២៤-២០២៨ ស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដើម្បីបន្តធ្វើកំណែទម្រង់គោលនយោបាយសារពើពន្ធ និងរដ្ឋបាលសារពើពន្ធ សំដៅដល់ការបំពេញបេសកកម្មរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងការផ្ដល់នូវសេវាដែលមានគុណភាព និងពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារ ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងសុចរិតភាព ដើម្បីជំរុញអនុលោមភាពដោយស្ម័គ្រចិត្ត។

ក្នុងអំឡុងពេល និងក្រោយការធ្វើបទបង្ហាញ ក្រុមបេសកកម្ម IMF បានស្នើសុំបញ្ជាក់បន្ថែមលើចំណុចមួយចំនួន ដូចជាតួលេខនៃការប្រមូលចំណូលពន្ធសម្រាប់ឆ្នាំ២០២៣និងទិសដៅសម្រាប់ឆ្នាំ២០២៤ផលប៉ះពាល់នៃការថមថយសកម្មភាពសេដ្ឋកិច្ចលើការប្រមូលចំណូលពន្ធសម្រាប់ឆ្នាំ២០២៤ ទិន្នន័យនៃការបាត់បង់ចំណូលពន្ធដោយសារការលើកលែងពន្ធ ការធ្វើសវនកម្មពន្ធដារ និងវិធានការពង្រឹងអនុលោមភាពសារពើពន្ធ និងស្ថានភាពនៃការលើកទឹកចិត្តផ្នែកពន្ធដារក្នុងពេលថ្មីៗនេះ។ ជាកិច្ចឆ្លើយតប ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ បានជម្រាបជូនយ៉ាងក្បោះក្បាយលើចំណុចដែលបានស្នើសុំការបញ្ជាក់នេះ ហើយបន្ថែមពីលើនេះ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ បានបន្តលើកឡើងអំពីកិច្ចខិតខំប្រឹងប្រែងរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងការពង្រឹងអនុលោមភាពសារពើពន្ធ ដើម្បីបង្កើតឱ្យមាននូវការប្រកួតប្រជែងស្មើភាពសម្រាប់សហគ្រាសទាំងអស់ ក៏ដូចជាបង្កើនការទាក់ទាញនូវការវិនិយោគបន្ថែមទៀតមកកាន់កម្ពុជា។ ក្នុងន័យនេះ អគ្គនាយកដ្ឋានពន្ធដារបានត្រៀមខ្លួនរួចជាស្រេចក្នុងការបន្តធ្វើកំណែទម្រង់ និងពង្រឹងរដ្ឋបាលសារពើពន្ធ ស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា ដែលបានកំណត់ការធ្វើកំណែទម្រង់ និងពង្រឹងអភិបាលកិច្ចគឺជាស្នូលសំខាន់៕



*ឯកឧត្តម **គង់ វិបុល** អមដោយលោកជំទាវ **ប៊ុន នារី** អគ្គនាយករង នាយកដ្ឋានថ្នាក់កណ្តាល និងមន្ត្រីជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ*




*លោក **Davide Furceri** ប្រធានក្រុមបេសកកម្មទទួលបន្ទុកប្រទេសកម្ពុជា និងសេដ្ឋវិទូជាន់ខ្ពស់នៃមូលនិធិរូបិយវត្ថុអន្តរជាតិ **IMF***

# សិក្ខាសាលាផ្សព្វផ្សាយស្ដីពី "កាតព្វកិច្ចពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ និងកម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDT e-Administration)"



នាព្រឹកថ្ងៃពុធ ទី២០ ខែមីនា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "កាតព្វកិច្ចពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំនិងកម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ ( GDT e-Administration )" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានវត្តមានចូលរួមពីឧកញ៉ា **សុខ ពិសិដ្ឋ** សហប្រធានក្រុមការងារ អគ្គនាយកដ្ឋានពន្ធដារ-វិស័យឯកជន លោក Arnaud Darc សហប្រធានក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និង អភិបាលកិច្ច ក្រុម "យ" ឯកឧត្តម លោកជំទាវ លោកអគ្គនាយករង ថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធ នៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងមានវត្តមានចូលរួមរបស់ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី នាងកញ្ញា ដែលជាអភិបាល បណ្ណាធិការ និងអ្នកតំណាងសហគ្រាស ចូលរួមដោយផ្ទាល់និងទស្សនាការផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុក ( Facebook Page ) ផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ។

ឯកឧត្តម **គង់ វិបុល** បានលើកឡើងអំពីសារៈសំខាន់នៃការរៀបចំសិក្ខាសាលានេះ ដោយផ្ដោតសំខាន់លើប្រធានបទចំនួន ២ គឺ ១.ការបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០២៣ និង២.កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ ( GDT e-Administration ) ដែលនឹងក្លាយជាជម្រើសថ្មីមួយទៀតសម្រាប់សាធារណជននិងអ្នកជាប់ពន្ធ ដើម្បីដាក់លិខិតរដ្ឋបាលនានាមកអគ្គនាយកដ្ឋានពន្ធដារនិងអង្គភាពក្រោមចំណុះ ជាអាទិ៍មានលិខិតរដ្ឋបាលទូទៅ ស្នើសុំធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ស្នើសុំបង់ពន្ធប្រថាប់ត្រា ស្នើសុំវិញ្ញាបនបត្រផ្សេងៗ និងការស្នើសុំបង់ពន្ធជាដំណាក់កាល ជាដើម ដោយមិនចាំបាច់ចំណាយពេលវេលាមករដ្ឋបាលសារពើពន្ធផ្ទាល់នោះឡើយ។ ដោយឡែក ឧកញ៉ា **សុខ ពិសិដ្ឋ** ក៏បានលើកឡើងថា ពន្ធគឺជាការចែករំលែកការវិនិយោគ ( Share of Investments ) ដែលបានចូលរួមចំណែកធ្វើឱ្យរាជរដ្ឋាភិបាលមានថវិកាគ្រប់គ្រាន់សម្រាប់ប្រើប្រាស់លើវិស័យអាទិភាពនានារបស់ប្រទេសជាតិ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ជាពិសេសការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ សាងសង់មន្ទីរពេទ្យ ស្ពាន សាលារៀន ផ្លូវថ្នល់ ការពារព្រំដែន ចំណាយទូទៅ សង្គមកិច្ច សេដ្ឋកិច្ច និងការអភិវឌ្ឍនានា។

**ខ្លឹមសារសំខាន់ៗនៃសុន្ទរកថាគន្លឹះរបស់ឯកឧត្តម គង់ វិបុល ៖**

- អគ្គនាយកដ្ឋានពន្ធដារ បាននិងកំពុងរៀបចំពង្រឹងនូវអភិបាលកិច្ចល្អ ដោយធ្វើកំណែទម្រង់នូវប្រព័ន្ធគ្រប់គ្រង និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពការងារ ហើយសហគ្រាសក៏ត្រូវពង្រឹងនូវអភិបាលកិច្ចសាជីវកម្មរបស់ខ្លួនដែរ
- អគ្គនាយកដ្ឋានពន្ធដារគាំទ្រទាំងស្រុងនូវការដាក់ចេញវិធានការលើកទឹកចិត្តនិងអនុគ្រោះផ្នែកពន្ធដាររបស់រាជរដ្ឋាភិបាលដល់វិស័យឯកជន និងសាធារណជនទូទៅ
- អគ្គនាយកដ្ឋានពន្ធដារ នឹងដាក់ចេញនូវនិយាមនីតិវិធីប្រតិបត្តិការងារ (SOP) ថ្មីមួយទៀត ដើម្បីពង្រឹងក្រមសីលធម៌លើការធ្វើសវនកម្មរបស់មន្ត្រីរាជការពន្ធដារ ក៏ដូចជាសម្រាប់ការស៊ើបអង្កេតបទល្មើសពន្ធដារ និងបទល្មើសសម្អាតប្រាក់
- ស្នើសុំគ្រប់ក្រសួងស្ថាប័ន និងភាគីពាក់ព័ន្ធចូលរួមសហការគ្នា ដើម្បីលុបបំបាត់នូវការចុះបញ្ជីបើកក្រុមហ៊ុនក្លែងក្លាយដែលជះផលមិនល្អ ដល់ទិដ្ឋភាពអាជីវកម្មនៅកម្ពុជា
- សូមភ្នាក់ងារសេវាកម្មពន្ធដារទាំងអស់ពង្រឹងការផ្តល់សេវារបស់ខ្លួន ចៀសវាងការប្រកាសបង់ពន្ធជូនអ្នកជាប់ពន្ធខុស ឬយឺតយ៉ាវ ឬមានភាពខ្វះចន្លោះដោយថាហេតុ និងជាច់ខាតត្រូវចៀសឱ្យផុតពីការពាក់ព័ន្ធនឹងអំពើគេចវេះពន្ធ
- សូមសហគ្រាសទាំងអស់ ធ្វើបច្ចុប្បន្នភាពព័ត៌មានរាល់មានការផ្លាស់ប្តូរ ដើម្បីបង្កភាពងាយស្រួលក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អគ្គនាយកដ្ឋានពន្ធដារ
- អគ្គនាយកដ្ឋានពន្ធដារនៅតែបន្តប្រកាន់ខ្ជាប់នូវគោលជំហរផ្តល់សេវាអ្នកជាប់ពន្ធប្រកបដោយគុណភាពខ្ពស់ ក្នុងនោះពង្រឹងការអនុវត្តតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងតាមអនឡាញ ដោយមានការគាំទ្រពីក្រុមការងារ e-Tax Service និង Call Center-1277 ក្នុងការដោះស្រាយរាល់ចម្ងល់ និងបញ្ហាប្រឈមនានា
- សូមចូលរួមប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីបច្ចេកវិទ្យាព័ត៌មាន និងសេវា e-Tax Service និង Call Center-1277 របស់អគ្គនាយកដ្ឋានពន្ធដារ និងផ្តល់ជាមតិត្រលប់ (User Feedback) ដើម្បីឱ្យអគ្គនាយកដ្ឋានពន្ធដារបន្តផ្តល់សេវាឱ្យកាន់តែល្អប្រសើរ។

**សិក្ខាសាលាផ្សព្វផ្សាយនេះ បានផ្តោតលើប្រធានបទសំខាន់ៗចំនួន ៤ រួមមាន៖**

- ទី១.កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDT e-Administration) ដោយលោក **លីម ជីលុច** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ៖ បានលើកឡើងអំពីរបៀបប្រើប្រាស់និងអត្ថប្រយោជន៍នៃប្រព័ន្ធដែលផ្តល់នូវភាពងាយស្រួល ចំណេញពេលវេលាជូនអ្នកជាប់ពន្ធក្នុងការបញ្ជូននិងស្នើសុំលិខិតរដ្ឋបាលនានាចូលមកអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារតាមអនឡាញ ដោយមិនចាំបាច់អញ្ជើញមករដ្ឋបាលសារពើពន្ធផ្ទាល់
- ទី២.កាតព្វកិច្ចពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ និងសវនកម្មពន្ធដារ ដោយលោក **តែ ហ្សឺឌី** ប្រធាននាយកដ្ឋានសវនកម្មសហគ្រាស៖ បានលើកឡើងពីពន្ធលើប្រាក់ចំណូល ដោយផ្តោតលើចំណុចសំខាន់ៗលើផ្នែកចំណូលចំណាយ ការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត ទិដ្ឋភាពច្បាប់និងយន្តការធ្វើសវនកម្មពន្ធដារ ប្រភេទសវនកម្មពន្ធដារ បែបបទនិងនីតិវិធីនៃការអនុវត្តសវនកម្មពន្ធដារ ការរៀបចំកែលម្អយន្តការនៃការធ្វើសវនកម្មពន្ធដារ គុណប្រយោជន៍នៃការធ្វើសវនកម្មពន្ធដារនិងបញ្ហាប្រឈមនានា
- ទី៣.ការបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ដោយលោក **ឆាយ ជាហេង** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ៖ បានផ្តោតលើចំណុចសំខាន់ៗដូចជា ការបំពេញព័ត៌មានទូទៅរបស់សហគ្រាស ព័ត៌មានគណនេយ្យ (តារាងតុល្យការ របាយការណ៍លទ្ធផល ថ្លៃដើម) ព័ត៌មានត្រូវបំពេញក្នុងតារាងកែតម្រូវក្រៅគណនេយ្យ និងព័ត៌មានត្រូវបំពេញក្នុងតារាងឧបសម្ព័ន្ធ

- ទី៤.ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ( ToI e-filing ) ដោយលោក **បាន ឌី រិទ្ធ** ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន៖ បានផ្តោតលើគោលបំណងនិងវិសាលភាពរំហូរសង្ខេបនៃការប្រើប្រាស់ប្រព័ន្ធការបញ្ចូលទិន្នន័យប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ បញ្ហាប្រឈម និងដំណោះស្រាយនានា៕








# ពិធីចុះសួរសុខទុក្ខនាយទាហាន ពលទាហាន គ្រួសារទ័ពនិង សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវសមិទ្ធផលនានានៅ បញ្ជាការដ្ឋានរថក្រោះកងទ័ពជើងគោក និងកងការពារព្រំដែន៥០១



នាព្រឹកថ្ងៃពុធ ទី១៣ ខែមីនា ឆ្នាំ២០២៤ ក្នុងពិធីចុះសួរសុខទុក្ខនាយទាហាន ពលទាហាន គ្រួសារទ័ពនិងសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវសមិទ្ធផលនានានៅបញ្ជាការដ្ឋានរថក្រោះកងទ័ពជើងគោក និងកងការពារព្រំដែន៥០១ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានមានប្រសាសន៍ថា "**សន្តិភាព**" បានមកពីការលះបង់យ៉ាងធំធេងដោយការយកជីវិតធ្វើជាដើមទុនរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជូនប្រទេសជាតិនិងប្រជាជនកម្ពុជា គឺជាកត្តាសំខាន់ទី១ ដែលផ្តល់លទ្ធភាពឱ្យអគ្គនាយកដ្ឋានពន្ធដារបំពេញភារកិច្ចបានដោយជោគជ័យក្នុងការប្រមូលចំណូលពន្ធដើម្បីអភិវឌ្ឍប្រទេសជាតិរហូតមានការរីកចម្រើនគួរឱ្យកត់សម្គាល់លើគ្រប់វិស័យ។ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ លើកឡើងបែបនេះក្នុងពិធីចុះសួរសុខទុក្ខនាយទាហាន ពលទាហាន គ្រួសារទ័ព និងសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវសមិទ្ធផលនានា នៅបញ្ជាការដ្ឋានរថក្រោះកងទ័ពជើងគោក និងកងការពារព្រំដែន៥០១ ដោយមានការចូលរួមជាអធិបតីភាពពី **ឯកឧត្តមឧត្តមសេនីយ៍ឯក ហ៊ុន ម៉ានិត មេបញ្ជាការរង បញ្ជាការដ្ឋានកងទ័ពជើងគោក និងជាអគ្គ-នាយកនៃអគ្គនាយកដ្ឋានស្រាវជ្រាវចារកិច្ច ក្រសួងការពារជាតិ**។ ឆ្លៀតក្នុងឱកាសនេះដែរ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូបានពាំនាំនូវការផ្តាំផ្ញើសេចក្តីនឹករលឹក និងការសួរសុខទុក្ខយ៉ាងកក់ក្តៅពី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ជូនបងប្អូនទាំងអស់គ្នា ដែលជានិច្ចកាលសម្តេចតែងតែគិតគូរអំពីសុខទុក្ខជីវភាពរស់នៅរបស់កងទ័ព ព្រមទាំងបានផ្តល់នូវការលើកទឹកចិត្តតាមរយៈការឧបត្ថម្ភជាថវិកា សម្ភារៈ និងគ្រឿងឧបភោគបរិភោគមួយចំនួនផងដែរ។

សូមរំលឹកផងដែរថា នេះជាលើកទី១១ ហើយដែលប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារបានរៀបចំពិធីសំណេះសំណាលនិងសាកសួរសុខទុក្ខយុទ្ធជនជានាយទាហាន នាយទាហានរង ពលទាហាន គ្រួសារកងទ័ព និងនិវត្តជន នៃបញ្ជាការដ្ឋានរថក្រោះកងទ័ពជើងគោក និងកងការពារព្រំដែនលេខ៥០១ បន្ទាប់ពីបានចងសម្ព័ន្ធមេត្រីនៅឆ្នាំ២០១៥៕

















# ផ្នែកទី១
# ស្ថានភាពនៃការគ្រប់គ្រងការប្រមូលចំណូលពន្ធ

១. លទ្ធផលការងារប្រមូលចំណូលពន្ធ

២. ស្ថានភាពចំណូលពន្ធតាមប្រភេទអ្នកជាប់ពន្ធ

៣. ស្ថានភាពចំណូលពន្ធតាមប្រភេទពន្ធសំខាន់ៗ

៤. ស្ថានភាពចំណូលពន្ធតាមសកម្មភាពអាជីវកម្មសំខាន់ៗ

# ๒

# ១. លទ្ធផលការងារប្រមូលចំណូលពន្ធ

ចំណូលពន្ធអាករ សរុបរយៈពេល ៣ខែដើមឆ្នាំ២០២៤ ដែលប្រមូលបានជាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ មានចំនួន **៤ ៨១៤,៦៥ ប៊ីលានរៀល** (ប្រមាណជា **១ ១៨៨,៨០ លានដុល្លារ**) ស្មើនឹង **២៨,៥៥%** នៃផែនការដែលបានកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤៕

**ចំណូលពន្ធអាករគ្រប់ប្រភេទ រយៈពេល ៣ខែដើមឆ្នាំ២០២៤**




| | ខែមករា | ខែកុម្ភៈ | ខែមីនា | សរុបរួម |
|---|---|---|---|---|
| ឆ្នាំ២០២៤ | ១ ២០៩,១៤ | ១ ០១១,៧៥ | ២ ៥៩៣,២៤ | ៤ ៨១៤,៦៥ |

# ២. ស្ថានភាពចំណូលពន្ធតាមប្រភេទអ្នកជាប់ពន្ធ

**ចំណូលពន្ធអាករតាមប្រភេទអ្នកជាប់ពន្ធ រយៈពេល ៣ខែដើមឆ្នាំ២០២៤**



សរុបរយៈពេល ៣ខែដើមឆ្នាំ២០២៤ ចំណូលពន្ធអាករតាមប្រភេទអ្នកជាប់ពន្ធ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានក្នុងនោះរួមមាន៖

- ចំណូលពន្ធអាករពីអ្នកជាប់ពន្ធធំ ចំនួន **៣ ៨៤៥,៨៧ ប៊ីលានរៀល** (ប្រមាណជា **៩៤៩,៦០ លានដុល្លារ**) **ស្មើនឹង ៧៩,៨៨%** ធៀបនឹងចំណូលពន្ធអាករសរុប
- ចំណូលពន្ធអាករពីអ្នកជាប់ពន្ធមធ្យម ចំនួន **៧៣៩,៥៩ ប៊ីលានរៀល** (ប្រមាណជា **១៨២,៥៩ លានដុល្លារ**) ស្មើនឹង **១៥,៣៦%** ធៀបនឹងចំណូលពន្ធអាករសរុប
- ចំណូលពន្ធអាករពីអ្នកជាប់ពន្ធតូច ចំនួន **៣១,៣៧ ប៊ីលានរៀល** (ប្រមាណជា **៧,៧៤ លានដុល្លារ**) ស្មើនឹង **០,៦៥%** ធៀបនឹងចំណូលពន្ធអាករសរុប
- ចំណូលពន្ធអាករពីប្រភេទពន្ធផ្សេងៗ (ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ ពន្ធលើអចលនទ្រព្យ និងពន្ធផ្សេងៗ) ចំនួន **៩១ ប៊ីលានរៀល** (ប្រមាណជា **៤៨,៨៧ លានដុល្លារ**) ស្មើនឹង **៤,១១%** ធៀបនឹងចំណូលពន្ធអាករសរុប។

## ៣. ស្ថានភាពចំណូលពន្ធតាមប្រភេទពន្ធសំខាន់ៗ

**ចំណូលពន្ធអាករតាមប្រភេទពន្ធសំខាន់ៗ រយៈពេល ៣ខែដើមឆ្នាំ២០២៤**




| | ពន្ធលើប្រាក់ចំណូល | អាករលើតម្លៃបន្ថែម | អាករពិសេស | ពន្ធលើប្រាក់បៀវត្ស | ពន្ធប្រថាប់ត្រា | ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ |
|---|---|---|---|---|---|---|
| ឆ្នាំ២០២៤ | ២ ១៧១,២៥ | ៨៩៨,១៨ | ២៦៧,៩៣ | ៣៣៣,៩៤ | ១៦៤,០៨ | ៧,៩១ |

សរុបរយៈពេល ៣ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារប្រមូលចំណូលតាមប្រភេទពន្ធសំខាន់ៗរួមមាន៖

- ពន្ធលើប្រាក់ចំណូលចំនួន **២ ១៧១,២៥ ប៊ីលានរៀល**
- អាករលើតម្លៃបន្ថែមចំនួន **៨៩៨,១៨ ប៊ីលានរៀល**
- អាករពិសេសចំនួន **២៦៧,៩៣ ប៊ីលានរៀល**
- ពន្ធលើប្រាក់បៀវត្សចំនួន **៣៣៣,៩៤ ប៊ីលានរៀល**
- ពន្ធប្រថាប់ត្រា (ផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ) ចំនួន **១៦៤,០៨ ប៊ីលានរៀល**
- ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យចំនួន **៧,៩១ ប៊ីលានរៀល**។

**តារាងចំណូលពន្ធអាករតាមប្រភេទពន្ធសំខាន់ៗ រយៈពេល ៣ខែដើមឆ្នាំ២០២៤**

(តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញ Online របស់អគ្គនាយកដ្ឋានពន្ធដារ)

| បរិយាយ | ខែមករា | ខែកុម្ភៈ | ខែមីនា | សរុបរួម |
|---|---|---|---|---|
| ពន្ធលើប្រាក់ចំណូល | ២០៤,៥៤ | ១៧៤,៤៧ | ១ ៧៩២,១៥ | ២ ១៧១,២៥ |
| អាករលើតម្លៃបន្ថែម | ៣១៩,៧០ | ៣០៧,២៧ | ២៧១,០៦ | ៨៩៨,១៨ |
| អាករពិសេស | ៨៣,០០ | ៩៦,៧៥ | ៨៨,១៨ | ២៦៧,៩៣ |
| ពន្ធលើប្រាក់បៀវត្ស | ១២៥,៤៨ | ១០៣,៦០ | ១០៤,៧៦ | ៣៣៣,៨៤ |
| ពន្ធប្រថាប់ត្រា | ៦០,៦៨ | ៥៨,៦១ | ៤៤,៧៨ | ១៦៤,០៨ |
| ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ | ២,៦៣ | ២,៦៣ | ២,៦៥ | ៧,៩១ |

*សម្គាល់៖ ចំណូលឯកតាគិតជាប៊ីលានរៀល។

## ៤. ស្ថានភាពចំណូលពន្ធតាមសកម្មភាពអាជីវកម្មសំខាន់ៗ

ក្នុងរយៈពេល ៣ខែដើមឆ្នាំ២០២៤ ចំណូលពន្ធពីសកម្មភាពសេវាហិរញ្ញវត្ថុនិងធានារ៉ាប់រង អាហារ័ណ-នីហារ័ណ និងសកម្មភាពកម្មន្តសាល គឺជាចំណូលពន្ធចម្បង និងលេចធ្លោជាងគេ។ ជាក់ស្តែង ចំណូលពន្ធអាករពីសកម្មភាពសេវាហិរញ្ញវត្ថុនិងធានារ៉ាប់រងមានចំនួន **១ ២៦៣,៧៣ ប៊ីលានរៀល** ចំណូលពន្ធអាករពីសកម្មភាពអាហារ័ណ-នីហារ័ណមានចំនួន **៦៨០,៩១ ប៊ីលានរៀល** និងចំណូលពន្ធពីសកម្មភាពកម្មន្តសាលមានចំនួន **៩៩៩,៣៤ ប៊ីលានរៀល**។ ដោយឡែកចំណូលពន្ធអាករដែលកើនឡើងគួរឱ្យកត់សម្គាល់សម្រាប់ រយៈពេល៣ខែដើមឆ្នាំ២០២៤ គឺចំណូលពន្ធអាករបានមកពីការដឹកជញ្ជូននិងការស្តុកទុក ដែលមានចំនួន **២២៥,៩៣ ប៊ីលានរៀល** បើធៀបនឹងរយៈពេលនិងសកម្មភាពដូចគ្នានៃឆ្នាំ២០២៣ កើនឡើងចំនួន **២៦,៧៨ ប៊ីលានរៀល** ស្មើនឹង **១៣,៤៥%**។

តារាងចំណូលពន្ធអាករតាមសកម្មភាពអាជីវកម្មសំខាន់ៗដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន ជាក់ស្តែង ក្នុងរយៈពេល ៣ខែដើមឆ្នាំ២០២៤ មានបង្ហាញដូចខាងក្រោម៖

**តារាងចំណូលពន្ធអាករតាមសកម្មភាពអាជីវកម្មសំខាន់ៗ រយៈពេល ៣ខែដើមឆ្នាំ២០២៤**

(តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញ Online របស់អគ្គនាយកដ្ឋានពន្ធដារ)

| បរិយាយ | ខែមករា | ខែកុម្ភៈ | ខែមីនា | សរុបរួម |
|---|---|---|---|---|
| អាហារ័ណ-នីហារ័ណ(រួមបញ្ចូលការលក់ផលិតផលគេលសិលា) | ២១១,៥៣ | ១៧២,៣៨ | ២៩៦,៨៨ | ៦៨០,៩១ |
| សេវាហិរញ្ញវត្ថុ និងធានារ៉ាប់រង | ១៩៥,០៣ | ១៧៣,១៨ | ៨៩៥,៥០ | ១ ២៦៣,៧៣ |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១២,៥០ | ៦,៧៥ | ២៣,២៧ | ៤២,៥៣ |
| ប្រតិបត្តិការ និងអាជីវកម្មធនធានរ៉ែ | ៨,១០ | ៥,៤២ | ៩៨,៩៥ | ១១២,៤៨ |
| កម្មន្តសាល | ២៧២,៣៣ | ២៧៩,៩៧ | ៤៤៧,០២ | ៩៩៩,៣៤ |
| សកម្មភាពអចលនវត្ថុ | ៥៩,៨៨ | ៥២,៨៣ | ១០១,៩៩ | ២១៤,៧២ |
| ការដឹកជញ្ជូន និងការស្តុកទុក | ៥៦,៧៩ | ៤៨,៦២ | ១២០,៥៣ | ២២៥,៩៣ |
| ព័ត៌មានវិទ្យា និងទូរគមនាគមន៍ | ១០២,០៧ | ៥៦,០១ | ១៦៣,៩០ | ៣២៣,៩៩ |
| ការអប់រំ | ៩,២៩ | ៨,១១ | ១០,៨៤ | ២៨,៦២ |
| សេវាកម្មស្នាក់នៅ និងអាហារ | ៣៤,៨៥ | ៣៣,៩០ | ៣៨,៥២ | ១០៧,៣៤ |
| ការសាងសង់ | ៦៦,៥៦ | ៥០,១៤ | ៩៧,៩២ | ២១៤,៩៦ |

* សម្គាល់ ៖ ចំណូលឯកតាគិតជាប៊ីលានរៀល។

# ផ្នែកទី២

# វឌ្ឍនភាពការងារនៃមុខងារប្រតិបត្តិការស្នូល និងមុខងារគាំទ្រ

១. ការចុះបញ្ជីពន្ធដារ

២. ការផ្តល់សេវាអ្នកជាប់ពន្ធ

៣. ការចាត់ចែងលិខិតប្រកាសពន្ធ

៤. ការធ្វើសវនកម្មពន្ធដារ

៥. ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា

៦. បច្ចេកវិទ្យាព័ត៌មាន

## ១.ការចុះបញ្ជីពន្ធដារ

ក្នុងរយៈពេល ៣ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានចុះបញ្ជីសហគ្រាសជោគជ័យសរុបចំនួន **២ ៨៤០ សហគ្រាស** (ពន្ធធំ ១៦៤ ពន្ធមធ្យម ១ ២០១ និងពន្ធតូច ១ ៤៧៥) ក្នុងនោះតាមថ្នាលចំនួន **២ ៦៣៩ សហគ្រាស** (ពន្ធធំ ១៥៦ ពន្ធមធ្យម ១ ១១១ និងពន្ធតូច ១ ៣៧២)។ ដោយឡែក គិតត្រឹមខែមីនា ឆ្នាំ២០២៤ ចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានអ្នកជាប់ពន្ធដែលបានមកចុះបញ្ជីសរុបចំនួន **៨៦ សហគ្រាស** និងក្នុងរយៈពេល ៣ខែដើមឆ្នាំ២០២៤ ប្រមូលចំណូលពន្ធពីប្រតិបត្តិការនេះបានចំនួន **៧៨,៩១ ប៊ីលានរៀល** ស្មើនឹង **១៩,៤៨ លានដុល្លារ** ដែលក្នុងនោះប្រមូលបានពីអ្នកជាប់ពន្ធអនិវាសនជន (VAT) ចំនួន **២២,២៧ ប៊ីលានរៀល** ស្មើនឹង **៥,៥ លានដុល្លារ** និងប្រមូលបានពីអ្នកជាប់ពន្ធនិវាសនជន (VAT Reverse Charge) ចំនួន **៥៦,៦៤ ប៊ីលានរៀល** ស្មើនឹង **១៣,៩៩ លានដុល្លារ**។

## ២.ការផ្តល់សេវាអ្នកជាប់ពន្ធ

### មជ្ឈមណ្ឌលពិគ្រោះយោបល់

ក្នុងរយៈពេល ៣ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានផ្តល់សេវាអ្នកជាប់ពន្ធសរុបចំនួន **២៨ ៩៥៥ ករណី** បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២៣ ឃើញថាថយចុះ **-១ ០៩៨ ករណី** ស្មើនឹង **-៣,៦៥%** ក្នុងនោះមានការថយចុះករណីនៃការផ្តល់សេវាស្ទើរតែទាំងអស់ លើកលែងតែការផ្តល់សេវាតាមរយៈទូរស័ព្ទ (១២៧៧) មានការកើនឡើង **៧៣៣ ករណី** ស្មើនឹង ៤%។ ការថយចុះនៃការសាកសួរសំណួរតាមរយៈការផ្តល់សេវាអ្នកជាប់ពន្ធគឺឆ្លុះបញ្ចាំងអំពីការយល់ដឹងរបស់អ្នកជាប់ពន្ធមានការកើនឡើង។

**ការផ្តល់សេវាពិគ្រោះយោបល់ រយៈពេល ៣ខែដើមឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០២៣**

| បរិយាយ | ឆ្នាំ២០២៣ | ឆ្នាំ២០២៤ | %កើន/ថយ |
|---|---|---|---|
| ទូរស័ព្ទ (១២៧៧) | ១៨ ៣២៣ | ១៩ ០៥៦ | ៤,០០% |
| GDT Live Chat | ៩ ១៧៣ | ៨ ៤០៩ | -៨,៣៣% |
| បណ្តាញសង្គម Facebook | ១ ៧៥៦ | ១ ១៦២ | -៣៣,៨៣% |
| កម្មវិធី "ពន្ធដារកម្ពុជា" | ១៣ | ៩ | -៣០,៧៧% |
| កម្មវិធី "រៀនអំពីពន្ធដារតាមអនឡាញ" | ១៤ | ៦ | -៥៧,១៤% |
| តេឡេក្រាម "ព័ត៌មានពន្ធដារកម្ពុជា" | ៧៧៤ | ៣១៣ | -៥៩,៥៦% |
| **សរុបរួម** | ៣០ ០៥៣ | ២៨ ៩៥៥ | -៣,៦៥% |

### ការផ្តល់សេវាអ្នកជាប់ពន្ធចំពោះ "ការគាំទ្រប្រព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ (e-Tax Service)"

ក្នុងរយៈពេល ៣ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានផ្តល់សេវាដោះស្រាយបញ្ហាប្រឈមនានា ក្នុងការប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីតាមរយៈអនឡាញ (e-Tax Service) សរុបចំនួន **១១ ៣២៩ ដង** ដែលក្នុងនោះការស្នើសុំតាមរយៈ GDT Live Chat ចំនួន **៤ ១៥៦ ដង**, សារអេឡិចត្រូនិក (E-Mail) ចំនួន **២០២ ករណី**, ទូរស័ព្ទ (១២៧៧) ចំនួន **៤ ៧២៣ ដង**, ហ្វេសប៊ុកចំនួន **២ ដង** និងក្រុមតេឡេក្រាម (Telegram) ចំនួន **២ ២៤៦ ដង**។

# កម្មវិធីពន្ធដារកម្ពុជា

កម្មវិធីពន្ធដារកម្ពុជា គឺជាកម្មវិធីដែលអគ្គនាយកដ្ឋានពន្ធដារបានរៀបចំឡើងដើម្បីចែករំលែកចំណេះដឹង ព័ត៌មានទាក់ទងនឹងពន្ធដារ ជាពិសេសផ្តល់ឱកាសឱ្យសាធារណជនចូលរួមមតិយោបល់ ឬលើកឡើងនូវចម្ងល់នានាពាក់ព័ន្ធនឹងប្រធានបទនីមួយៗ ដែលធ្វើការផ្សាយផ្ទាល់តាមរយៈទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ រៀងរាល់ថ្ងៃព្រហស្បតិ៍ វេលាម៉ោង ១១:០០ ដល់ម៉ោង ១២:០០ថ្ងៃត្រង់។ កម្មវិធីនេះ ទទួលបានការគាំទ្រយ៉ាងខ្លាំងពីសំណាក់អ្នកជាប់ពន្ធ និងសាធារណជន ដែលទស្សនិកជនអាចផ្តល់មតិយោបល់ ឬសួរសំណួរតាមរយៈទូរស័ព្ទមកលេខ ១២៧៧ ដោយឥតគិតថ្លៃ ឬអាចចូលទៅផ្តល់មតិយោបល់ (Comment) នៅលើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារភ្លាមៗក្នុងពេលផ្សាយផ្ទាល់ នោះវាគ្មិននឹងធ្វើការឆ្លើយតបផ្ទាល់ក្នុងកម្មវិធីតែម្តង។ ក្នុងករណីខកខានមិនបានទស្សនាការផ្សាយផ្ទាល់ ទស្សនិកជនក៏អាចទស្សនាឡើងវិញ ព្រមទាំងអាចសួរសំណួរតាមរយៈ Comments ក្នុងវីដេអូនោះ ក្រុមការងារ GDT Call Center របស់អគ្គនាយកដ្ឋានពន្ធដារ នឹងធ្វើការឆ្លើយតបជូនតាមលំដាប់លំដោយ។ ក្រៅពីការចូលទៅទស្សនាឡើងវិញនៅលើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ ទស្សនិកជនក៏អាចចូលទៅទស្សនាក្នុងបណ្តាញយូធូប (YouTube) "General Department of Taxation, Cambodia" របស់អគ្គនាយកដ្ឋានពន្ធដារ ផងដែរ។

ក្នុងត្រីមាសទី១ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំកម្មវិធីពន្ធដារកម្ពុជាសរុបចំនួន **៩ លើក** ដោយផ្តោតលើប្រធានបទសំខាន់ៗរួមមាន ១.ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ (ប្រាក់ចំណូលជាប់ពន្ធ) ២.ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ (ចំណាយដែលអនុញ្ញាតឱ្យកាត់កងបាន) ៣.ការបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលនិងប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូល (ToI e-Filing) ៤.គណនេយ្យសាមញ្ញ សម្រាប់អ្នកជាប់ពន្ធតូច ៥.ការបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលនិងកម្មវិធីប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App) ៦.ពន្ធប៉ាតង់ និងពន្ធលើផ្ទាំងផ្សព្វផ្សាយ ៧.កាតព្វកិច្ចសារពើពន្ធរបស់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ៨.វិធាននិងនីតិវិធីសម្រាប់បែងចែកចំណូលនិងចំណាយក្នុងចំណោមបុគ្គលទាក់ទិន និង៩.ការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ៕



## កម្មវិធីពន្ធដារកម្ពុជាស្តីពី “ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ (ប្រាក់ចំណូលជាប់ពន្ធ)”




ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ត្រាំង ឡៃ** អនុប្រធាននាយកដ្ឋានសវនកម្មសហគ្រាស និងលោក **ទ្រី ច័ន្ទតារារិទ្ធ** អនុប្រធានការិយាល័យនៃនាយកដ្ឋានសវនកម្មសហគ្រាស ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី១ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ៥៨ អ្នកចូលទស្សនាចំនួន ៩ ២០០ ដង និងមានការចែករំលែកបន្តចំនួន ២០១ ដង៕

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ (ចំណាយដែលអនុញ្ញាតឱ្យកាត់កងបាន)"




ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ត្រាំង ឡៃ** អនុប្រធាននាយកដ្ឋានសវនកម្មសហគ្រាស និងលោកស្រី **អ៊ុក ម៉ូលីតា** អនុប្រធានការិយាល័យនៃនាយកដ្ឋានសវនកម្មសហគ្រាស ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី១ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ៤២ អ្នកចូលទស្សនាចំនួន ៥ ២០០ ដង និងមានការចែករំលែកបន្តចំនួន ១៣០ ដង៕

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "ការបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលនិងប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូល (ToI e-Filing)"




ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ឆាយ ជាហេង** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងលោក **សុធី គីរី** អនុប្រធានការិយាល័យនៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការ របស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី១ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ៦៥ អ្នកចូលទស្សនាចំនួន ១២ ៤០០ ដង និងមានការចែករំលែកបន្តចំនួន ៤៦០ ដង៕

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "គណនេយ្យសាមញ្ញ សម្រាប់អ្នកជាប់ពន្ធតូច"



ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ម៉ា ម៉ូរ៉ា** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម និងលោក **ម៉ូ ពិសិដ្ឋ** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជន ផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី១ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ២៥ អ្នកចូលទស្សនាចំនួន ៦ ៥០០ ដង និងមានការចែករំលែកបន្តចំនួន ១៦៨ ដង៕

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "ការបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលនិងកម្មវិធីប្រកាសពន្ធអេឡិចត្រូនិកសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App)"



ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ថៃ ពេជ្រ** ប្រធានការិយាល័យនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម និងលោក **សុធី គីរី** អនុប្រធានការិយាល័យនៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី១ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុក មានមតិយោបល់ (Comments) ចំនួន ៣៥ អ្នកចូលទស្សនាចំនួន ១០ ៥០០ ដង និងមានការចែករំលែកបន្តចំនួន ៣៥០ ដង៕

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "ពន្ធប៉ាតង់ និងពន្ធលើផ្ទាំងផ្សព្វផ្សាយ"



ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ម៉ៅ ម៉ុនធីម** ប្រធានការិយាល័យនៃទីចាត់ការពន្ធដារ និងលោក **ខៃន គីម** អនុប្រធានការិយាល័យនៃនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី១ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ៦០ អ្នកចូលទស្សនាចំនួន ៦ ៨០០ ដង និងមានការចែករំលែកបន្តចំនួន ២៤០ ដង៕

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "ភាតព្វកិច្ចសារពើពន្ធរបស់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស"



ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោកបណ្ឌិត **សេង សោភា** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងលោក **ឆាយ ជាហេង** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី១ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ៣៥ អ្នកចូលទស្សនាចំនួន ៤ ១០០ ដង និងមានការចែករំលែកបន្តចំនួន ១៣០ ដង៕

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "វិធាននិងនីតិវិធីសម្រាប់បែងចែកចំណូលនិងចំណាយក្នុងចំណោមបុគ្គលទាក់ទិន"



ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ហេង សុវណ្ណារ័ត្ន** ប្រធានការិយាល័យសវនកម្មសហគ្រាស និងលោក **ឡេី ច័ន្ទតារារិទ្ធ** អនុប្រធានការិយាល័យសវនកម្មសហគ្រាស ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី១ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ២៥ អ្នកចូលទស្សនាចំនួន ៤ ១០០ ដង និងមានការចែករំលែកបន្តចំនួន ១២០ ដង៕

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "ការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ"



ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **កែវ ម៉ង់តា** អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ និងលោក **ស៊ុន ឧុទ្ធី** អនុប្រធានការិយាល័យនៃនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី១ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ១១០ អ្នកចូលទស្សនាចំនួន ១០ ៣០០ ដង និងមានការចែករំលែកបន្តចំនួន ៣៩០ ដង៕

# ៣.ការចាត់ចែងលិខិតប្រកាសពន្ធ

អគ្គនាយកដ្ឋានពន្ធដារ បាននិងកំពុងដាក់ឱ្យប្រើប្រាស់កម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូចលើទូរស័ព្ទដៃ ឈ្មោះ GDT Tax Prefiling App ដែលមានមុខងារ ១.កត់ត្រាទិន្នន័យទិញ-លក់ ២.ប្រកាសពន្ធប្រចាំខែ-ប្រចាំឆ្នាំ ៣.មើលប្រវត្តិប្រកាសពន្ធ-ប្រវត្តិបង់ប្រាក់ពន្ធ និង៤.ពិនិត្យមើលបំណុលពន្ធរបស់ក្រុមហ៊ុនលោកអ្នកអាចចូលទៅទាញយកនៅក្នុង Play Store ឬ App Store។ សម្រាប់អ្នកជាប់ពន្ធមធ្យមនិងធំ ចាប់តាំងពីខែកញ្ញា ឆ្នាំ២០២២ អគ្គនាយកដ្ឋានពន្ធដារ បានដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (e-Filing) និងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing) ដែលមានលក្ខណៈពេញលេញភ្ជាប់ជាមួយនឹងមុខងារទូទាត់ប្រាក់ពន្ធតាមរយៈប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធធនាគារ ដើម្បីផ្តល់ភាពងាយស្រួលជូនអ្នកជាប់ពន្ធកាត់បន្ថយពេលវេលា និងដោះស្រាយបញ្ហាប្រឈមក្នុងការបំពេញលិខិតប្រកាសនិងទូទាត់ប្រាក់ពន្ធ។ បន្ថែមពីនេះ នាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣ អគ្គនាយកដ្ឋានពន្ធដារ បានចេញសេចក្តីណែនាំលេខ ៤៥៤១៧ អពដ ស្តីពីនីតិវិធីនៃការកែតម្រូវលិខិតប្រកាសពន្ធប្រចាំខែតាមអនឡាញ ក្នុងគោលបំណងផ្តល់ជូនអ្នកជាប់ពន្ធក្នុងការកែតម្រូវលិខិតប្រកាសពន្ធប្រចាំខែកន្លងមក ដែលបានប្រកាសខុសទិន្នន័យដោយផ្អែកលើមូលដ្ឋាន នៃការភាន់ច្រឡំ ឬភ្លាំងភ្លាត់ ឬមានបំណងធ្វើបច្ចុប្បន្នភាពទិន្នន័យ ព្រមទាំងបញ្ចូលមុខងារថ្មី រួមមាន ការភ្ជាប់លិខិតផ្ទេរសិទ្ធិនិងប័ណ្ណសម្គាល់សម្រាប់គណនីប្រើប្រាស់ជាភ្នាក់ងារសេវាកម្មពន្ធដារនិងតំណាងសហគ្រាស ភ្ជាប់របាយការណ៍ហិរញ្ញវត្ថុ និងការកែតម្រូវលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំដែលបានប្រកាសរួចរាល់៕

*ដើម្បីយល់កាន់តែច្បាស់អំពីនីតិវិធីក្នុងការដាក់ពាក្យស្នើសុំកែតម្រូវលិខិតប្រកាសពន្ធប្រចាំខែ សូមលោក លោកស្រីស្កេននូវ QR Code នេះ*



## ៤.ការធ្វើសវនកម្មពន្ធដារ

ក្នុងរយៈពេល ៣ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានធ្វើសវនកម្មគ្រប់ប្រភេទលើសហគ្រាសសរុបបានចំនួន **៣ ៧០៨ ករណី** មានប្រាក់ពន្ធចំនួន **១ ៩០០,៤០ ប៊ីលានរៀល**។ ប្រសិនបើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ ឃើញថាការធ្វើសវនកម្មមានការកើនឡើងចំនួន **៤៣៩ ករណី** ស្មើនឹង **១៣,៤០%**៕

**ចំនួនករណី និងប្រាក់ពន្ធអាករ ដែលបានមកពីការធ្វើសវនកម្ម រយៈពេល ៣ខែដើមឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០២៣**

| បរិយាយ | ចំនួនករណី | ប្រាក់ពន្ធអាករ(ប៊ីលានរៀល) |
|---|---|---|
| ឆ្នាំ២០២៤ | ៣ ៧០៨ | ១ ៩០០,៤០ |
| ឆ្នាំ២០២៣ | ៣ ២៦៩ | ២ ៥០៩,៥៤ |

## ៥.ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា

### ការប្រមូលបំណុលពន្ធ

ក្នុងរយៈពេល ៣ខែដើមឆ្នាំ២០២៤ បំណុលពន្ធប្រមូលបានមានចំនួន **១៧៣,២៩ ប៊ីលានរៀល** (ប្រមាណជា **២០៧,៣៩ លានដុល្លារ**) បើប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ មានចំនួន **២២៨,៤៦ ប៊ីលានរៀល** (ប្រមាណជា **៥៦,៤១ លានដុល្លារ**) គឺមានការថយចុះចំនួន **៥៥,១៧ ប៊ីលានរៀល** (ប្រមាណជា **១៣,៦២ លានដុល្លារ**) ស្មើនឹង **-២៤,១៥%**៕

**លទ្ធផលប្រមូលបំណុលពន្ធ រយៈពេល៣ខែដើមឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣**

ឯកតាគិតជាប៊ីលានរៀល

| បរិយាយ | ខែមករា | ខែកុម្ភៈ | ខែមីនា | សរុបរួម |
|---|---|---|---|---|
| ឆ្នាំ២០២៤ | ៦៩,១៨ | ៥៣,២៨ | ៥០,៨៣ | ១៧៣,២៩ |
| ឆ្នាំ២០២៣ | ៧៦,១២ | ៦៣,៣២ | ៨១,៩០ | ២២៨,៤៦ |
| %ថយ | -៩,១២% | -១៥,៨៦% | -៣៧,៩៤% | -២៤,១៥% |

*សម្គាល់៖ តួលេខប្រមូលបំណុលពន្ធ "សរុបរួម" មានការកែតម្រូវឡើងវិញ និងកត់ត្រាបន្ថែមនូវតួលេខបំណុលពន្ធទារបានក្នុងខែមករា-មីនា មួយចំនួន ដោយអ្នកជាប់ពន្ធមិនបានយកបង្កាន់ដៃទូទាត់ប្រាក់ពន្ធទៅប្រកាស ដើម្បីកត់ត្រា។

### បណ្តឹងតវ៉ា

ក្នុងរយៈពេល ៣ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានដោះស្រាយសំណុំឯកសារបណ្តឹងតវ៉ា ចំនួន **១២៧ ករណី** មានប្រាក់ពន្ធ **១៤៣,៩៤ ប៊ីលានរៀល** បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ គឺមានការកើនឡើងចំនួន **៣១ ករណី** ប្រាក់ពន្ធកើនឡើងចំនួន **៨៣,៣០ ប៊ីលានរៀល**។ បំណុលពន្ធបានបង់ក្នុងរយៈពេល ៣ខែដើមឆ្នាំ២០២៤ មានចំនួន **៧,១២ ប៊ីលានរៀល** ប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ កើនឡើងចំនួន **០,៧៥ ប៊ីលានរៀល**៕

# ៦.បច្ចេកវិទ្យាព័ត៌មាន

ក្នុងខែមីនា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានបន្តធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានពន្ធដារ សម្រាប់គាំទ្រដល់ការគ្រប់គ្រងការប្រមូលចំណូលពន្ធ ការផ្តល់សេវាអ្នកជាប់ពន្ធក្នុងនោះ ប្រព័ន្ធ-កម្មវិធីបានអភិវឌ្ឍថ្មីមានចំនួន ០, ប្រព័ន្ធ-កម្មវិធីកំពុងអភិវឌ្ឍថ្មីមានចំនួន ១, ប្រព័ន្ធ-កម្មវិធីបានធ្វើបច្ចុប្បន្នភាពមានចំនួន **១៧ ប្រព័ន្ធ-កម្មវិធី** ស្មើនឹង **៣០ លើក**, ប្រព័ន្ធ-កម្មវិធីកំពុងធ្វើបច្ចុប្បន្នភាពមានចំនួន **១៨ ប្រព័ន្ធ-កម្មវិធី** ស្មើនឹង **២៨ លើក**។ សរុបរយៈពេល ៣ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារមានការអភិវឌ្ឍប្រព័ន្ធ-កម្មវិធីថ្មីសរុបចំនួន **២** (បានបញ្ចប់ការអភិវឌ្ឍចំនួន ១) និងការងារធ្វើបច្ចុប្បន្នភាពប្រព័ន្ធ-កម្មវិធីសរុបចំនួន **៣៣ ប្រព័ន្ធ-កម្មវិធី** ស្មើនឹង **១១១ លើក** (បានបញ្ចប់ការធ្វើបច្ចុប្បន្នភាពចំនួន **២៨ ប្រព័ន្ធ-កម្មវិធី** ស្មើនឹង **៨៣ លើក**)៕

**ការធ្វើទំនើបកម្មសារពើពន្ធ ពីឆ្នាំ ២០២៣-២០២៤**

| បរិយាយ | ប្រព័ន្ធ | កម្មវិធី | សរុបរួម |
|---|---|---|---|
| ឆ្នាំ២០២៣ | ០៣ | ០៣ | ០៦ |
| រយៈពេល ៣ខែដើមឆ្នាំ២០២៤ | ០១ | ០០ | ០១ |

**ប្រព័ន្ធ-កម្មវិធីអភិវឌ្ឍថ្មី ដែលសម្រេចបាន ក្នុងរយៈពេល ៣ខែដើមឆ្នាំ២០២៤**

| បរិយាយ | ប្រភេទ | ជំនាន់ទី | វឌ្ឍនភាព |
|---|---|---|---|
| ប្រព័ន្ធគ្រប់គ្រងសហគ្រាសដើមនិងភ្នាក់ងារផ្គត់ផ្គង់បន្ត | ប្រព័ន្ធ | ១.០.០ | សម្រេច |
| ប្រព័ន្ធគ្រប់គ្រងពន្ធលើចំណេញមូលធន | ប្រព័ន្ធ | ១.០.០ | ៥០% |

## គេហទំព័រអគ្គនាយកដ្ឋានពន្ធដារ (GDT Website)

អគ្គនាយកដ្ឋានពន្ធដារមានគេហទំព័រផ្លូវការមួយ (www.tax.gov.kh) ដើម្បីផ្សព្វផ្សាយព័ត៌មានថ្មីៗ ទាក់ទងនឹងអ្នកជាប់ពន្ធ សេវាសាធារណៈ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ទំនាក់ទំនងអន្តរជាតិ សេវាកម្មអេឡិចត្រូនិកពន្ធដារ និងកិច្ចការទាំងឡាយរបស់អង្គភាពពន្ធដារ ដែលតែងតែមានអ្នកជាប់ពន្ធចូលទស្សនាជាប្រចាំ។ ជាក់ស្តែងក្នុងខែមីនា ឆ្នាំ២០២៤ មានចំនួនអ្នកចូលទស្សនា **២៥៩ ៤៣៧ ដង** និងក្នុងរយៈពេល ៣ខែដើមឆ្នាំ២០២៤ មានចំនួនអ្នកចូលទស្សនាសរុប **៧៤៧ ៤១៨ ដង**៕



# QR Code វីដេអូណែនាំអំពីការប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីនានាក់ទងនឹងពន្ធដារ

## កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDT e-Administration)




**ទស្សនាតាមផ្នែក៖**

- 03:49 : សម្រាប់បុគ្គលទូទៅ
- 07:33 : សម្រាប់ភ្នាក់ងារសេវាកម្មពន្ធដារ
- 11:46 : សម្រាប់អ្នកតំណាងសហគ្រាស

សូមស្កេន QR Code

## កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App)



មុខងារបង់ពន្ធតែមប្រើសារពើពន្ធ

**ទស្សនាតាមផ្នែក៖**

- 00:46 : ការបង្កើតគណនីប្រើប្រាស់កម្មវិធី
- 02:03 : ការចូលប្រើប្រាស់កម្មវិធី
- 02:38 : ការបំពេញលិខិតប្រកាស តែមប្រើសារពើពន្ធ

សូមស្កេន QR Code




មុខងារបន្ថែមយានយន្តថ្មី

**ទស្សនាតាមផ្នែក៖**

- 00:26 : ការចូលប្រើប្រាស់កម្មវិធី
- 02:03 : ការបំពេញបន្ថែមយានយន្តថ្មី

សូមស្កេន QR Code




មុខងារបង់ពន្ធអចលនទ្រព្យ រហ័ស

**ទស្សនាតាមផ្នែក៖**

- 01:00 : ការចូលប្រើប្រាស់កម្មវិធី
- 02:03 : របៀបបង់ពន្ធអចលនទ្រព្យ

សូមស្កេន QR Code

## ប្រព័ន្ធបង់ប្រាក់ពន្ធតាមអនឡាញ (E-Payment)




**ទស្សនាតាមផ្នែក៖**

- 00:30 : ការចូលប្រើប្រាស់កម្មវិធី
- 00:40 : ការបង្កើតគណនីប្រើប្រាស់កម្មវិធី
- 01:40 : របៀបបង់ពន្ធតាមអនឡាញ

សូមស្កេន QR Code

# QR Code វីដេអូណែនាំអំពីការប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីទាក់ទងនឹងពន្ធដារ

## ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ សម្រាប់អ្នកជាប់ពន្ធមធ្យម និង ធំ (e-Filing)




**ទស្សនាតាមផ្នែក៖**

- 00:50 : ការចុះឈ្មោះដើម្បីប្រើប្រាស់ប្រព័ន្ធ
- 01:54 : ការចូលប្រើប្រាស់ប្រព័ន្ធ
- 07:05 : ការប្រកាសពន្ធប្រចាំខែ

សូមស្កេន QR Code




មុខងារ (Reverse Charge)

**ទស្សនាតាមផ្នែក៖**

- 00:50 : ការចូលប្រើប្រាស់ប្រព័ន្ធ
- 01:30 : ការប្រកាសពន្ធ

សូមស្កេន QR Code

## កម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App)




**ទស្សនាតាមផ្នែក៖**

- 00:50 : ការបង្កើតគណនីប្រើប្រាស់កម្មវិធី
- 02:10 : ការចូលប្រើប្រាស់កម្មវិធី

សូមស្កេន QR Code



មុខងារប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

**ទស្សនាតាមផ្នែក៖**

- 00:40 : ការចូលប្រើប្រាស់កម្មវិធី
- 00:50 : ការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

សូមស្កេន QR Code

## ប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce Tax System)




( Khmer Version) ( English Version)

# ផ្នែកទី៣
# បច្ចុប្បន្នភាពច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសារពើពន្ធ


១. អនុក្រឹត្យ
២. ប្រកាស
៣. សេចក្តីណែនាំ
៤. សេចក្តីជូនដំណឹង

# បច្ចុប្បន្នភាពច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសារពើពន្ធ

សរុបក្នុងរយៈពេល ៣ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងកែលម្អគោលនយោបាយសារពើពន្ធ តាមរយៈការដាក់ចេញឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តនានាស្តីពីពន្ធដារ ដូចមានក្នុងតារាងនិងអត្ថបទខាងក្រោម៖

**បច្ចុប្បន្នភាពច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសារពើពន្ធ រយៈពេល ៣ខែដើមឆ្នាំ២០២៤**

| បរិយាយ | ខែមករា | ខែកុម្ភៈ | ខែមីនា | សរុបរួម |
|---|---|---|---|---|
| ច្បាប់ | ០០ | ០០ | ០០ | ០០ |
| អនុក្រឹត្យ | ០០ | ០០ | ០៣ | ០៣ |
| ប្រកាស | ០១ | ០២ | ០៩ | ១២ |
| សារាចរណែនាំ | ០០ | ០០ | ០០ | ០០ |
| សេចក្តីណែនាំ | ០១ | ០០ | ០២ | ០៣ |
| សេចក្តីជូនដំណឹង | ០៤ | ០០ | ០០ | ០៤ |
| សេចក្តីសម្រេច | ០០ | ០០ | ០០ | ០០ |
| **សរុបរួម** | ០៦ | ០២ | ១៤ | ២២ |

## ១.អនុក្រឹត្យ

### អនុក្រឹត្យ ស្តីពីពន្ធប៉ាតង់

នាថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ស្តីពីពន្ធប៉ាតង់ ក្នុងគោលបំណងកំណត់អត្រាពន្ធប៉ាតង់សម្រាប់សកម្មភាពអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អត្រាពន្ធប៉ាតង់ ត្រូវបានកំណត់ដូចខាងក្រោម៖

១.អ្នកជាប់ពន្ធតូច ត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៤០០ ០០០ រៀល។

២.អ្នកជាប់ពន្ធមធ្យម ត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ១ ២០០ ០០០ រៀល។

៣.អ្នកជាប់ពន្ធធំ ត្រូវបង់៖

ក.ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៣ ០០០ ០០០ រៀល។

ខ.ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៥ ០០០ ០០០ រៀល ក្នុងករណីដែលមានផលរបរលើសពី ១០ ០០០ លានរៀល។

៤.អ្នកជាប់ពន្ធដូចមានចែងក្នុងកថាខណ្ឌទី១ កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃមាត្រានេះ ដែលចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល ៦ ខែចុងឆ្នាំ ត្រូវបង់ពន្ធប៉ាតង់ចំនួនពាក់កណ្តាលនៃពន្ធប៉ាតង់ប្រចាំឆ្នាំ៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## អនុក្រឹត្យ ស្ដីពីកម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងកម្រិតប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ

នាថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ស្ដីពីកម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងកម្រិតប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ។ អនុក្រឹត្យនេះ ត្រូវបានអនុវត្តចំពោះប្រាក់បៀវត្សជាប់ពន្ធប្រចាំខែរបស់និយោជិតនិវាសនជន និងប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំរបស់សហគ្រាសឯកបុគ្គល និងចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## អនុក្រឹត្យ ស្ដីពីអាករលើតម្លៃបន្ថែម

នាថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ ៤៩ អនក្រ.បក ស្ដីពីអាករលើតម្លៃបន្ថែម ក្នុងគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលអាករលើតម្លៃបន្ថែម ចំពោះការផ្គត់ផ្គង់ជាប់អាករនូវទំនិញឬសេវានៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អនុក្រឹត្យនេះ មានចំនួន ១២ ជំពូក ដែលបានចែងទៅលើ ១.បទប្បញ្ញត្តិទូទៅ ២.បុគ្គលជាប់អាករនិងអាករលើធាតុចូល ៣.ការផ្គត់ផ្គង់មិនជាប់អាករចំពោះបេសកកម្មទូតនិងអង្គការអន្តរជាតិ ៤.ទីកន្លែង វិធាន និងនីតិវិធីសម្រាប់ការផ្គត់ផ្គង់ជាប់អាករ ៥.ការកែតម្រូវទឹកប្រាក់អាករ ៦.បញ្ជីគណនេយ្យ កំណត់ត្រានិងព័ត៌មាន ៧.ការផ្គត់ផ្គង់ទំនិញឬសេវា ៨.ការប្រមូលអាករលើការនាំចូល ៩.ដែនអនុវត្តនៃអត្រា ០ (សូន្យ) ភាគរយ ចំពោះការនាំចេញនូវទំនិញឬសេវា ១០.ការបញ្ឈប់និងការផ្ទេរអាជីវកម្ម ១១.អាករលើតម្លៃបន្ថែមចំពោះអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង១២.អវសានប្បញ្ញត្តិ៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

# ២.ប្រកាស

## ប្រកាស ស្ដីពីការលើកទឹកចិត្តចំពោះការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត

នាថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ០៧១ សហវ.ប្រក.អពជ ស្ដីពីការលើកទឹកចិត្តចំពោះការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត ដើម្បីលើកលែងទណ្ឌកម្មរដ្ឋបាល ស្របតាមវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល។ ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលស្នើសុំកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត ក្រោយកាលបរិច្ឆេទនៃការដាក់លិខិតប្រកាសពន្ធ ដោយផ្អែកលើមូលដ្ឋាននៃការភាន់ច្រឡំ ឬការភ្លាំងភ្លាត់ ដែលអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកបានធ្វើនៅក្នុងលិខិតប្រកាសពន្ធពីមុន៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## ប្រកាស ស្ដីពីការលើកទឹកចិត្តពន្ធដារចំពោះសហគ្រាសក្នុងវិស័យទេសចរណ៍

នាថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ១១៩ សហវ.ប្រក.អពជ ស្ដីពីការលើកទឹកចិត្តពន្ធដារចំពោះសហគ្រាសក្នុងវិស័យទេសចរណ៍។ ប្រកាសនេះ មានគោលបំណងផ្ដល់ការលើកទឹកចិត្តពន្ធដារដល់សហគ្រាសក្នុងវិស័យទេសចរណ៍ ស្របតាមវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល ដើម្បីជួយស្ដារវិស័យទេសចរណ៍ឱ្យបានល្អប្រសើរឡើងវិញ និងអនុវត្តចំពោះសហគ្រាសដែលបានចុះបញ្ជីពន្ធដារនិងមានសកម្មភាពអាជីវកម្មស្ថិតនៅរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តកែប និងខេត្តកំពត៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## ប្រកាស ស្តីពីការព្យួរទុកការបង់ប្រាក់រំដោះពន្ធ លើប្រាក់ចំណូលរបស់សហគ្រាសឧស្សាហកម្មផ្នែកវាយនភណ្ឌកាត់ដេរ

នាថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ១២០ សហវ.ប្រក.អពដ ស្តីពីការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលរបស់សហគ្រាសឧស្សាហកម្មផ្នែកវាយនភណ្ឌកាត់ដេរ ដើម្បីឱ្យមាននិរន្តរភាព ជំរុញការនាំចេញនិងបង្កើតការងារដល់កម្មករ កម្មការិនី ព្រមទាំងប្រជាពលរដ្ឋដែលទទួលបានផលប្រយោជន៍ពីវិស័យនេះ។ ប្រកាសនេះ នឹងអនុវត្តចំពោះសហគ្រាសជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ (គ.ល.គ) ក្នុងវិស័យវាយនភណ្ឌកាត់ដេរ ដែលផុតរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល។ ការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ត្រូវបានអនុគ្រោះព្យួរទុកជាបណ្ដោះអាសន្ននូវការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែ រហូតដល់ដំណាច់ឆ្នាំ២០២៥៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## ប្រកាស ស្តីពីអាករសម្រាប់បំភ្លឺសាធារណៈ

នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ១៦៨ សហវ.ប្រក.អពដ ស្តីពីអាករសម្រាប់បំភ្លឺសាធារណៈ ក្នុងគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈ និងអនុវត្តចំពោះការផ្គត់ផ្គង់ផលិតផលសុរាមេរ័យ ឬថ្នាំជក់ក្នុងព្រះរាជាណាចក្រកម្ពុជា។ ប្រកាសនេះ បានលើកឡើងនូវពាក្យគន្លឹះ អត្រាមូលដ្ឋានគិតអាករ ព្រមទាំងកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ប្រាក់អាករផងដែរ៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## ប្រកាស ស្តីពីពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ

នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ១៦៩ សហវ.ប្រក.អពដ ស្តីពីពន្ធលើថ្លៃឈ្នួលអចលនទ្រព្យក្នុងគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ និងអនុវត្តលើកម្មសិទ្ធិករ ឬសិទ្ធិវន្ត ដែលមិនមែនជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលជួលអចលនទ្រព្យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ប្រកាសនេះ បានលើកឡើងនូវពាក្យគន្លឹះ អត្រាពន្ធ មូលដ្ឋានគិតពន្ធ ការលើកលែងពន្ធ កាតព្វកិច្ចរបស់កម្មសិទ្ធករ ឬសិទ្ធិវន្ត ព្រមទាំងកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធផងដែរ៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## ប្រកាស ស្តីពីការលើកទឹកចិត្តពន្ធដារចំពោះវិស័យកសិកម្ម

នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ១៧០ សហវ.ប្រក.អពដ ស្តីពីការលើកទឹកចិត្តពន្ធដារចំពោះវិស័យកសិកម្ម ក្នុងគោលបំណងដាក់ចេញនូវវិធានការលើកទឹកចិត្តពន្ធដារចំពោះវិស័យកសិកម្ម។ ប្រកាសនេះ ត្រូវបានអនុវត្តចំពោះការដាំដុះ ការផលិត ការផ្គត់ផ្គង់ក្នុងស្រុក ឬការនាំចេញស្រូវ អង្ករ ពោត សណ្ដែក ម្រេច ដំឡូងមី គ្រាប់ស្វាយចន្ទី ជ័រកៅស៊ូ មៀនប៉ៃលិន ស្វាយ ចេក ការចិញ្ចឹមសត្វ វារីវប្បកម្ម និងផលិតផលដូងប្រេងក្នុងស្រុកដែលជាវត្ថុធាតុដើមសម្រាប់ផលិតចំណីសត្វ។ សហគ្រាសទាំងនេះ នឹងត្រូវទទួលបានការអនុគ្រោះរហូតដល់ដំណាច់ឆ្នាំ២០២៥ នូវការព្យួរទុកការបង់ពន្ធអប្បបរមា ការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងរួចផុតពីកាតព្វកិច្ចកាត់ទុកប្រាក់ពន្ធលើការទូទាត់ចំពោះការផ្គត់ផ្គង់សេវាដោយបុគ្គលមិនស្ថិតក្នុងរបបស្វ័យប្រកាស៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## ប្រកាស ស្តីពីការចាត់ជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែម លើមុខទំនិញដែលជាអាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ

នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ១៧១ សហវ.ប្រក.អពដ ស្តីពីការចាត់ជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមលើមុខទំនិញដែលជាអាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ប្រកាសនេះ មានគោលបំណងជួយសម្រួលនិងលើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ តាមរយៈការដាក់ជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមលើមុខទំនិញដែលជាអាហារជាមូលដ្ឋានរហូតដល់ដំណាច់ឆ្នាំ២០២៨ និងត្រូវបានអនុវត្តចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលធ្វើការផ្គត់ផ្គង់ក្នុងស្រុកនូវទំនិញទាំងអស់នេះ។

ដើម្បីទទួលបានឯកសារ
ឬអានលម្អិត សូមស្កេន QR Code

## ប្រកាស ស្តីពីការលើកទឹកចិត្តពន្ធដារចំពោះវិស័យអប់រំ

នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ១៧២ សហវ.ប្រក.អពដ ស្តីពីការលើកទឹកចិត្តពន្ធដារចំពោះវិស័យអប់រំ ក្នុងគោលបំណងផ្តល់ការលើកទឹកចិត្តពន្ធដារចំពោះវិស័យអប់រំ ដើម្បីជំរុញការអភិវឌ្ឍធនធានមនុស្ស និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។ ប្រកាសនេះ ត្រូវបានអនុវត្តចំពោះគ្រឹះស្ថានសិក្សា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានបំពេញកាតព្វកិច្ច តាមការកំណត់របស់រដ្ឋបាលសារពើពន្ធ ចំណែកឯការលើកទឹកចិត្តនេះ នឹងត្រូវផុតកំណត់នៅដំណាច់ឆ្នាំ២០២៨។

ដើម្បីទទួលបានឯកសារ
ឬអានលម្អិត សូមស្កេន QR Code

## ប្រកាស ស្តីពីអាករលើការស្នាក់នៅ

នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ១៧៣ សហវ.ប្រក.អពដ ស្តីពីអាករលើការស្នាក់នៅ ក្នុងគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលអាករលើការស្នាក់នៅ និងអនុវត្តចំពោះការផ្គត់ផ្គង់សេវាស្នាក់នៅក្នុងសណ្ឋាគារក្នុងព្រះរាជាណាចក្រកម្ពុជា។ ប្រកាសនេះ បានលើកឡើងនូវពាក្យគន្លឹះ អត្រានិងមូលដ្ឋានគិតអាករ ការកំណត់ការផ្គត់ផ្គង់សេវាស្នាក់នៅ ការកំណត់តម្លៃជាប់អាករ ព្រមទាំងកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធថែមទៀតផង។

ដើម្បីទទួលបានឯកសារ
ឬអានលម្អិត សូមស្កេន QR Code

## ប្រកាស ស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត

នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ១៧៤ សហវ.ប្រក.អពដ ស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត ក្នុងគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើប្រតិបត្តិការប្រេងកាត និងអនុវត្តចំពោះអ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការប្រេងកាត នៅក្នុងបូរណភាពទឹកដីនិងអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងតំបន់ផ្សេងៗទៀតដែលព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិអធិបតេយ្យ។ ប្រកាសនេះ បានលើកឡើងនូវពាក្យគន្លឹះ អត្រាពន្ធដែលកំណត់តាមអត្រាកំណើនតាមថ្នាក់ ការគណនាប្រាក់ពន្ធ ការធ្វើរំលស់ ព្រមទាំងកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធថែមទៀតផង។

ដើម្បីទទួលបានឯកសារ
ឬអានលម្អិត សូមស្កេន QR Code

## ប្រកាស ស្ដីពីពន្ធលើប្រតិបត្តិការធនធានរ៉ែ

នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ១៧៥ សហវ.ប្រក.អពដ ស្ដីពីពន្ធលើប្រតិបត្តិការធនធានរ៉ែ ក្នុងគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើប្រតិបត្តិការធនធានរ៉ែ និងអនុវត្តចំពោះអ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការធនធានរ៉ែ នៅក្នុងបូរណភាពទឹកដីនិងអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងតំបន់ផ្សេងៗទៀតដែលព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិអធិបតេយ្យ។ ប្រកាសនេះបានលើកឡើងនូវពាក្យគន្លឹះ អត្រាពន្ធដែលកំណត់តាមអត្រាកំណើនតាមថ្នាក់ ការគណនាប្រាក់ពន្ធ ការធ្វើរំលស់ ព្រមទាំងកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធថែមទៀតផង៕

ដើម្បីទទួលបានឯកសារ
ឬអានលម្អិត សូមស្កេន QR Code

## ប្រកាស ស្ដីពីពន្ធលើផ្ទាំងផ្សព្វផ្សាយ

នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ១៧៦ សហវ.ប្រក.អពដ ស្ដីពីពន្ធលើផ្ទាំងផ្សព្វផ្សាយ ក្នុងគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើផ្ទាំងផ្សព្វផ្សាយគ្រប់ប្រភេទនិងអនុវត្តចំពោះការផ្សព្វផ្សាយតាមគ្រប់រូបភាពទាំងចល័ត និងអចល័តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ប្រកាសនេះ ថែមទាំងបានលើកឡើងនូវពាក្យគន្លឹះ ប្រភេទអត្រានិងលក្ខខណ្ឌបន្ថែមដែលត្រូវជាប់ពន្ធ ព្រមទាំងការលើកលែងពន្ធផងដែរ៕

ដើម្បីទទួលបានឯកសារ
ឬអានលម្អិត សូមស្កេន QR Code

# ៣.សេចក្ដីណែនាំ

## សេចក្ដីណែនាំ ស្ដីពីការផ្ដល់អត្ថប្រយោជន៍ក្រោមកិច្ចព្រមព្រៀង ស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នា ( Double Taxation Agreement-DTA )

នាថ្ងៃទី៣ ខែមករា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្ដីណែនាំលេខ ១៨០ អពដ ស្ដីពីការផ្ដល់អត្ថប្រយោជន៍ក្រោមកិច្ចព្រមព្រៀងស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នា ( Double Taxation Agreement-DTA )។ ក្នុងគោលបំណងផ្ដល់ការលើកទឹកចិត្តនិងភាពងាយស្រួលបន្ថែមទៀតដល់អ្នកជាប់ពន្ធ ក្នុងការអនុវត្តនិងទទួលបានអត្ថប្រយោជន៍ក្រោមកិច្ចព្រមព្រៀង DTA អគ្គនាយកដ្ឋានពន្ធដារបញ្ជាក់ថា អត្ថប្រយោជន៍ក្រោមកិច្ចព្រមព្រៀង DTA នឹងត្រូវអនុវត្តសម្រាប់រយៈពេលមួយឆ្នាំពេញ សម្រាប់គ្រប់ករណីស្នើសុំដែលទទួលបានការអនុញ្ញាតពីអគ្គនាយកដ្ឋានពន្ធដារ ដោយគិតចាប់ពីថ្ងៃទី១ ខែមករា នៃឆ្នាំជាប់ពន្ធចរន្ត។ អ្នកជាប់ពន្ធត្រូវរួសរាន់ក្នុងការដាក់ពាក្យស្នើសុំអត្ថប្រយោជន៍ក្រោមកិច្ចព្រមព្រៀង DTA និងត្រូវអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិនានាស្ដីពីពន្ធដារជាធរមាន មុនពេលទទួលបានការអនុញ្ញាតនេះ៕

ដើម្បីទទួលបានឯកសារ
ឬអានលម្អិត សូមស្កេន QR Code

## សេចក្ដីណែនាំ ស្ដីពីការដាក់លិខិតរដ្ឋបាល តាមរយៈកម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ ( GDT e-Administration )

នាថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្ដីណែនាំលេខ ១១៩៣៦ អពដ ស្ដីពីការដាក់លិខិតរដ្ឋបាលតាមរយៈកម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ ( GDT e-Administration ) ក្នុងគោលបំណងផ្ដល់ភាពងាយស្រួល ឆាប់រហ័ស និងចំណេញពេលវេលា ប្រកបដោយភាពជឿទុកចិត្តលើការផ្ដល់សេវាអ្នកជាប់ពន្ធ ក្នុងការដាក់លិខិតរដ្ឋបាលផ្សេងៗមកអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្ត-ខណ្ឌ។ កម្មវិធីនេះនឹងជាជំនួយឱ្យកម្មវិធីបញ្ជូនឯកសារអេឡិចត្រូនិក ( e-Documents Submission System ) បន្ថែមពីលើជម្រើសនៃការអញ្ជើញមកដាក់លិខិតរដ្ឋបាលដោយផ្ទាល់នៅអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្ត-ខណ្ឌ៕

ដើម្បីទទួលបានឯកសារ
ឬអានលម្អិត សូមស្កេន QR Code

### សេចក្តីណែនាំ ស្តីពីការដាក់ឱ្យប្រើប្រាស់ មុខងារ "បញ្ជីឯកសារតាមរយៈ GDT e-Administration" ក្នុងប្រព័ន្ធគ្រប់គ្រងការតាមដានឯកសារ ( Document Tracking System )

នាថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានចេញលិខិតលេខ ១១៩៣៧ អពដ អំពីសេចក្តីណែនាំស្តីពីការដាក់ឱ្យប្រើប្រាស់មុខងារ "បញ្ជីឯកសារតាមរយៈ GDT e-Administration" ក្នុងប្រព័ន្ធគ្រប់គ្រងការតាមដានឯកសារ ( Document Tracking System ) ដើម្បីផ្តល់ភាពងាយស្រួលក្នុងការគ្រប់គ្រង និងផ្តល់សេវាជូនអ្នកជាប់ពន្ធដែលបានដាក់ពាក្យស្នើសុំ ឬដាក់ឯកសារលិខិតរដ្ឋបាលផ្សេងៗ តាមកម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ ( GDT e-Administration ) ដោយបែងចែកជា ៣ កម្រិតសម្រាប់មន្ត្រី គឺកម្រិតរដ្ឋបាលទទួលឯកសារ កម្រិតលេខាធិការដ្ឋាន និងកម្រិតនាយកដ្ឋាន/សាខាពន្ធដារខេត្ត-ខណ្ឌ៕

## ៤.សេចក្តីជូនដំណឹង

### សេចក្តីជូនដំណឹង ស្តីពីការបន្តគោលការណ៍លើកលែងពន្ធ ការអនុគ្រោះពន្ធបន្ថែមទៀត ការពន្យារ និងការព្យួរការអនុវត្តពន្ធសម្រាប់វិស័យអចលនទ្រព្យ

នាថ្ងៃទី៤ ខែមករា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីជូនដំណឹងលេខ ០០១ សហវ.ស.ជ.ណ អពដ ស្តីពីការបន្តគោលការណ៍លើកលែងពន្ធ ការអនុគ្រោះពន្ធបន្ថែមទៀត ការពន្យារ និងការព្យួរការអនុវត្តពន្ធសម្រាប់វិស័យអចលនទ្រព្យ។ អនុលោមតាមការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩ នាថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានជូនដំណឹងដល់លោក-លោកស្រី និងសាធារណជន ចំពោះការបន្តគោលការណ៍លើកលែងពន្ធ ការអនុគ្រោះពន្ធបន្ថែមទៀត ការពន្យារ និងការព្យួរការអនុវត្តពន្ធតាមស្ថានភាពនៃប្រភេទពន្ធនីមួយៗ មានដូចជា ១.ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ២.ពន្ធលើចំណេញមូលធន ៣.ពន្ធលើអចលនទ្រព្យ និង ៤.ពន្ធលើដីធ្លីមិនបានប្រើប្រាស់៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

### សេចក្តីជូនដំណឹង ស្តីពីការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ សម្រាប់ឆ្នាំជាប់ពន្ធ ២០២៣

នាថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីជូនដំណឹងលេខ ២២៨៤ អពដ ស្តីពីការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ សម្រាប់ឆ្នាំជាប់ពន្ធ ២០២៣ ជម្រាបជូនដំណឹងដល់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ អំពីកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ២០២៣ ដូចខាងក្រោម៖

១. សហគ្រាសត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមប្រព័ន្ធអនឡាញ ( Tax on Income-ToI e-Filing ) ដោយត្រូវដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤។

២. សហគ្រាសដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ឆ្នាំជាប់ពន្ធខុសពីឆ្នាំប្រតិទិន ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំយ៉ាងយឺតបំផុតក្នុងរយៈពេល ៣ខែ ក្រោយពីដំណាច់ឆ្នាំជាប់ពន្ធ។

៣. សហគ្រាសដែលមានសាខាត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំជាមួយគ្នាដោយសរុបលទ្ធផលរបស់គ្រឹះស្ថានជាគោលដើម និងគ្រប់សាខាទាំងអស់។

៤. ចំពោះបុគ្គលិក ឬភ្នាក់ងារសេវាកម្មពន្ធដារ ដែលទទួលបន្ទុកការងារដាក់លិខិតប្រកាសពន្ធប្រចាំខែ ប្រចាំឆ្នាំ ជំនួសមុខឱ្យអ្នកជាប់ពន្ធ ត្រូវភ្ជាប់ (Upload) ចូលទៅក្នុងប្រព័ន្ធនូវប័ណ្ណសម្គាល់ខ្លួនបុគ្គលិក ចំពោះបុគ្គលិកក្រុមហ៊ុន ឬលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរពីអ្នកជាប់ពន្ធចំពោះភ្នាក់ងារសេវាកម្មពន្ធដារ។

៥. គ្រប់សហគ្រាសទាំងអស់ ដែលមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ត្រូវភ្ជាប់ (Upload) ចូលទៅក្នុងប្រព័ន្ធនូវតារាងតុល្យការ គណនីលទ្ធផល និងព័ត៌មានបន្ថែម (ប្រសិនបើមាន)៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កែន QR Code

## សេចក្តីជូនដំណឹង ស្តីពីកម្រិតអត្រាការប្រាក់ទីផ្សារសម្រាប់ប្រាក់កម្ចីប្រចាំឆ្នាំ២០២៣

នាថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីជូនដំណឹងលេខ ៣៨៣០ អពដ ស្តីពីកម្រិតអត្រាការប្រាក់ទីផ្សារសម្រាប់ប្រាក់កម្ចីប្រចាំឆ្នាំ២០២៣ សូមធ្វើការកំណត់អត្រាការប្រាក់ទីផ្សារសម្រាប់ប្រាក់កម្ចីប្រចាំឆ្នាំ២០២៣ ដោយផ្អែកលើការគណនាមធ្យមភាគ នៃមធ្យមភាគអត្រាការប្រាក់ឱ្យខ្ចីប្រចាំឆ្នាំរបស់ធនាគារពាណិជ្ជធំៗក្នុងស្រុកចំនួន ១២ (ដប់ពីរ) ដូចខាងក្រោម៖

- ៩,៦៦% ក្នុងមួយឆ្នាំ ចំពោះប្រាក់រៀល
- ៨,៧៥% ក្នុងមួយឆ្នាំ ចំពោះប្រាក់ដុល្លារអាមេរិក។

អត្រាការប្រាក់ខាងលើនេះ ប្រើប្រាស់ក្នុងគោលដៅអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែមលើការផ្តល់ប្រាក់ឱ្យនិយោជិតខ្ចី និងក្នុងគោលដៅកម្រិតអត្រាការប្រាក់លើការខ្ចីពីបុគ្គលទាក់ទិនតែប៉ុណ្ណោះ៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កែន QR Code

## សេចក្តីជូនដំណឹង ស្តីពីករណីព្យួរអាជ្ញាប័ណ្ណ ភ្នាក់ងារសេវាកម្មពន្ធដាររបស់ក្រុមហ៊ុន អេចធី & ភី ផាតនើរ ឯ.ក

នាថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីជូនដំណឹងលេខ ៤៣០៨ អពដ ស្តីពីករណីព្យួរអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដាររបស់ក្រុមហ៊ុន អេចធី & ភី ផាតនើរ ឯ.ក ជាអក្សរឡាតាំង HT & P Partners Co., LTD. លេខអត្តសញ្ញាណកម្មសារពើពន្ធ K010-901703637 រយៈពេល ៦ខែ គិតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ រហូតដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០២៤។ ស្ថិតក្នុងអំឡុងពេលនៃការព្យួរអាជ្ញាប័ណ្ណនេះ ក្រុមហ៊ុនមិនមាននីតិសម្បទាជាភ្នាក់ងារសេវាកម្មពន្ធដារ ដែលអាចផ្តល់សេវាពាក់ព័ន្ធនឹងពន្ធដារជូនអតិថិជន ឬជូនអ្នកជាប់ពន្ធទៀតទេ៕

# ផ្នែកទី៤
# កិច្ចសហប្រតិបត្តិការក្របខ័ណ្ឌជាតិ-អន្តរជាតិ

១. សកម្មភាពផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ

២. កិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន

៣. កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន អង្គការ សមាគម និងស្ថាប័នអន្តរជាតិ

# ១. សកម្មភាពផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ

## កិច្ចប្រជុំបូកសរុបលទ្ធផលការងារគ្រប់គ្រងប្រមូលចំណូលពន្ធប្រចាំខែមករា ឆ្នាំ២០២៤ ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្ត របស់អគ្គនាយកដ្ឋានពន្ធដារ



*ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ*

នាព្រឹកថ្ងៃចន្ទ ទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ នៅសាលាជាតិពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារគ្រប់គ្រងប្រមូលចំណូលពន្ធប្រចាំខែមករា ឆ្នាំ២០២៤ ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្តរបស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាព ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារ នាយកដ្ឋានថ្នាក់កណ្តាល និងសាខាពន្ធដារខេត្ត-ខណ្ឌ និងមន្ត្រីរាជការពន្ធដារពាក់ព័ន្ធក្រោមចំណុះរបស់អគ្គនាយកដ្ឋានពន្ធដារ ដោយផ្ទាល់និងតាមប្រព័ន្ធអនឡាញ (Zoom Meeting)។

ចំពោះលទ្ធផលនៃការគ្រប់គ្រងប្រមូលចំណូលពន្ធ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ បានបង្ហាញថាក្នុងខែមករា ឆ្នាំ២០២៤ ចំណូលពន្ធអាករគ្រប់ប្រភេទ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញ មានចំនួន **១ ២០៩,១៤ ប៊ីលានរៀល (ប្រមាណជា ២៩៨,៥៥ លានដុល្លារ)** ស្មើនឹង **៧,១៧%** នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ ថយចុះចំនួន **៨,២៤ ប៊ីលានរៀល (ប្រមាណជា ២,០៣ លានដុល្លារ)** ស្មើនឹង ០,៦៨%។

**ប្រសាសន៍សំខាន់ៗរបស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ និងលទ្ធផលការងារសំខាន់ៗក្នុងខែមករា ឆ្នាំ២០២៤៖**

- អគ្គនាយកដ្ឋានពន្ធដារត្រៀមដាក់ឱ្យអនុវត្តនូវកម្មវិធីរដ្ឋបាលអេឡិចត្រូនិក (GDT e-Administration) ដែលផ្តល់ភាពងាយស្រួល ឆាប់រហ័ស ចំណេញពេលវេលា ប្រកបដោយភាពជឿទុកចិត្តលើការផ្តល់សេវាអ្នកជាប់ពន្ធ ក្នុងការដាក់លិខិតរដ្ឋបាលផ្សេងៗមកអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្ត-ខណ្ឌ ដែលយន្តការនេះគឺបានបង្កើតនូវជម្រើសតាមអនឡាញបន្ថែមពីលើជម្រើសនៃការអញ្ជើញមកផ្ទាល់នៅអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្ត-ខណ្ឌ
- បន្តពង្រឹងការផ្សព្វផ្សាយ និងអនុវត្តប្រកបដោយការយកចិត្តទុកដាក់នូវវិធានការលើកទឹកចិត្តនិងសម្រួលផ្នែកពន្ធដារជូនវិស័យឯកជនក្នុងក្របខ័ណ្ឌវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩ ដោយក្នុងខែមករា ឆ្នាំ២០២៤

នេះ អគ្គនាយកដ្ឋានពន្ធដារ ១.បានសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីរៀបចំនិយាមនីតិវិធីប្រតិបត្តិការងារ (SOP) ស្តីពីការជូនវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលទទួលបានការលើកលែងពន្ធ និងការស្នើសុំទិន្នន័យអចលនទ្រព្យ ២.បានបញ្ចប់ការរៀបចំសេចក្តីព្រាងសៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីប្រតិបត្តិ ដែលជាឯកសារនិយាមនីតិវិធីប្រតិបត្តិការងារ (SOP) ចំពោះមុខងារ និងប្រភេទពន្ធសំខាន់ៗ នៅកម្រិតអគ្គនាយកដ្ឋានពន្ធដារ ៣.បន្តពង្រឹងកិច្ចសហការជាមួយវិស័យឯកជន ជាពិសេសក្នុងក្របខ័ណ្ឌក្រុមការងារអគ្គនាយកដ្ឋានពន្ធដារផ្នែកឯកជន ស្របតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ថ្នាក់ដឹកនាំក្នុងការរៀបចំប្រជុំរៀងរាល់ ២ខែម្តង និង ៤.បានបញ្ចប់ការរៀបចំសេចក្តីព្រាងអនុក្រឹត្យ និងប្រកាសសំខាន់ៗ ដើម្បីគាំទ្រការអនុវត្តច្បាប់ស្តីពីសារពើពន្ធ និងបានគោរពជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានដោះស្រាយបណ្តឹងតវ៉ាផ្នែកពន្ធដារជូនសហគ្រាសនិងអ្នកជាប់ពន្ធលើករណីសវនកម្មសហគ្រាសបានសរុបចំនួន **៣៧ ករណី**
- បាននិងកំពុងធ្វើសិក្ខាសាលាផ្សព្វផ្សាយស្តីពីពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ដែលរៀងរាល់ឆ្នាំចាប់ខែមករា-មីនាគឺជារដូវកាល នៃការប្រកាសនិងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ
- ក្នុងខែមករា ឆ្នាំ២០២៤ ចំណូលពន្ធពីប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (e-Commerce) ប្រមូលបានចំនួន **៣៥,១១ ប៊ីលានរៀល (ប្រមាណ ៨,៦៧លានដុល្លារ)**
- កម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App) ទទួលបានការគាំទ្រយ៉ាងខ្លាំងពីសាធារណជន ដោយចាប់ពីខែឧសភា ឆ្នាំ២០២២ រហូតមកដល់ខែមករា ឆ្នាំ២០២៤ មានវិក្កយបត្របានបញ្ជូនមកសរុបជាង **៩១ម៉ឺន វិក្កយបត្រ**
- បានពិគ្រោះយោបល់ជូនអ្នកជាប់ពន្ធ តាមរយៈមជ្ឈមណ្ឌលពិគ្រោះយោបល់តាមទូរស័ព្ទលេខ ១២៧៧ (GDT Call Center-1277) កម្មវិធីជជែកផ្ទាល់ជាមួយពន្ធដារ (GDT Live Chat) បណ្តាញទំនាក់ទំនងសង្គម Facebook កម្មវិធី "រៀនអំពីពន្ធដារតាមអនឡាញ (GDT e-Learning)" សារអេឡិចត្រូនិក E-Mail, GDT News Channel, ពិគ្រោះយោបល់ដោយផ្ទាល់ និងកម្មវិធី "ពន្ធដារកម្ពុជា" សរុបចំនួន **៩ ៣៩៧ ករណី**
- បានផ្តល់សេវាគាំទ្រការប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីនានា (e-Tax Service) ដោះស្រាយរាល់បញ្ហាប្រឈមនានាក្នុងការប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីនានាតាមប្រព័ន្ធអនឡាញសរុបចំនួន **៣ ៥២០ ករណី**
- ការបណ្តុះបណ្តាលនិងសិក្ខាសាលាសម្រាប់មន្ត្រីនិងសាធារណជនទូទៅមានចំនួន **៣៩ លើក** មានសិក្ខាកាមចូលរួម ចំនួន **៨ ៤២៣ រូប** ក្នុងនោះ វគ្គបណ្តុះបណ្តាលចំនួន **១៥ លើក** មានសិក្ខាកាមចូលរួមចំនួន **៧ ១៤៥ រូប** និងសិក្ខាសាលាចំនួន **២៤ លើក** មានសិក្ខាកាមចូលរួមចំនួន **១ ២៧៨ រូប**៕



# កិច្ចប្រជុំបូកសរុបលទ្ធផលការងារគ្រប់គ្រងប្រមូលចំណូលពន្ធប្រចាំខែកុម្ភៈ ឆ្នាំ២០២៤ ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្ត របស់អគ្គនាយកដ្ឋានពន្ធដារ



*ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ*

នាព្រឹកថ្ងៃចន្ទ ទី២៥ ខែមីនា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារគ្រប់គ្រងប្រមូលចំណូលពន្ធប្រចាំខែកុម្ភៈ និងសម្រាប់រយៈពេល២ខែ ឆ្នាំ២០២៤ ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្តរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលរៀបចំតាមប្រព័ន្ធអនឡាញ (Zoom Meeting) ក្រោមអធិបតីភាពរបស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីឯកឧត្តម-លោកជំទាវ-លោកអគ្គនាយករង ទីប្រឹក្សាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារពាក់ព័ន្ធទាំងអស់ ក្រោមចំណុះរបស់អគ្គនាយកដ្ឋានពន្ធដារ៕



# ពិធីសំណេះសំណាលជាមួយក្រុមនិស្សិត ជ័យលាភីអាហារូបករណ៍រដ្ឋាភិបាលប្រទេសណូវែលសេឡង់




*ពិធីសំណេះសំណាលជាមួយក្រុមនិស្សិតជ័យលាភីអាហារូបករណ៍រដ្ឋាភិបាលប្រទេសណូវែលសេឡង់ (Manaaki New Zealand Scholarships 2023) ក្រោមអធិបតីភាពឯកឧត្តម **លីម ហ៊ុយជីវ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ*

នាព្រឹកថ្ងៃសុក្រ ទី១២ ខែមករា ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំពិធីសំណេះសំណាលជាមួយក្រុមនិស្សិតជ័យលាភីអាហារូបករណ៍រដ្ឋាភិបាលប្រទេសណូវែលសេឡង់ (Manaaki New Zealand Scholarships 2023) ចំនួន **៣២ រូប** សម្រាប់ឆ្នាំសិក្សា ២០២៤-២០២៥ ក្រោមអធិបតីភាព ឯកឧត្តម **លីម ហ៊ុយជីវ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ តំណាង ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងមានការចូលរួមពីតំណាងនាយកដ្ឋានពាក់ព័ន្ធក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ។

បន្ទាប់ពីបានស្តាប់សេចក្តីរាយការណ៍រួមរបស់តំណាងនិស្សិតជ័យលាភី និងបទឧទ្ទេសនាមសង្ខេបរបស់និស្សិតនីមួយៗរួចមក ឯកឧត្តមអគ្គនាយករង បានសម្តែងនូវការកោតសរសើរ និងចូលរួមអបអរសាទរចំពោះនិស្សិតជ័យលាភីទាំងអស់ដែលបានទទួលជ័យលាភីអាហារូបករណ៍ទៅបន្តការសិក្សានៅប្រទេសណូវែលសេឡង់ ដែលជាប្រទេសអភិវឌ្ឍន៍មួយមានប្រព័ន្ធអប់រំឈានមុខគេនៅលើពិភពលោក។ ឯកឧត្តមអគ្គនាយករង បានមានប្រសាសន៍បន្ថែមទៀតថា ដោយមានទំនាក់ទំនងល្អរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយប្រទេសណូវែលសេឡង់ រដ្ឋាភិបាលប្រទេសណូវែលសេឡង់ តែងតែបន្តផ្តល់ជំនួយអភិវឌ្ឍន៍ធនធានមនុស្សដល់ប្រទេសកម្ពុជាយើងជាប្រចាំ។ ទន្ទឹមនឹងនេះ ឯកឧត្តមអគ្គនាយករង បានផ្តាំផ្ញើឱ្យក្រុមនិស្សិតជ័យលាភីទាំងអស់ខិតខំរៀនសូត្រ និងសិក្សាពីចំណុចល្អៗក្នុងអំឡុងពេលនៃការសិក្សានេះ ដើម្បីយកចំណេះដឹងនិងបង្កើនសមត្ថភាពរបស់ខ្លួនប្រើប្រាស់ជាប្រយោជន៍ក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិ ស្របតាមគោលបំណងរបស់រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលប្រទេសណូវែលសេឡង់ដែលជាម្ចាស់ជំនួយ៕

# ២. កិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន

## កិច្ចប្រជុំរវាងអគ្គនាយកដ្ឋានពន្ធដារ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីពិនិត្យពិភាក្សាលើការរៀបចំសេចក្តីព្រាង និយាមនីតិវិធីប្រតិបត្តិការងារ (SOP)




ឯកឧត្តម **កែន សម្បត្តិ** (រូបកណ្តាល) ឯកឧត្តម **គិត ច័ន្ទត្រីស្នា** (រូបឆ្វេង) ឯកឧត្តម **លីម ហ៊ុយជីវ** (រូបស្តាំ)

នារសៀលថ្ងៃសុក្រ ទី២ ខែកុម្ភៈ ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំក្រុមការងារអន្តរក្រសួងរវាងអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រោមអធិបតីភាពសហប្រធានក្រុមការងារអន្តរក្រសួង រួមមាន ឯកឧត្តមបណ្ឌិត **កែន សម្បត្តិ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ និងឯកឧត្តម **គិត ច័ន្ទត្រីស្នា** អនុរដ្ឋលេខាធិការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ កិច្ចប្រជុំនេះ ជាកិច្ចប្រជុំលើកដំបូងនៃក្រុមការងារអន្តរក្រសួង ដែលរៀបចំឡើងដើម្បីពិនិត្យពិភាក្សាជាលក្ខណៈបច្ចេកទេស និងជំរុញការរៀបចំសេចក្តីព្រាងនិយាមនីតិវិធីប្រតិបត្តិការងារ (SOP) របស់ក្រុមការងារស្របតាមសេចក្តីសម្រេចលេខ ០០៤ សហវ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០២៤។ និយាមនីតិវិធីប្រតិបត្តិការងារ (SOP) នេះជួយឱ្យលេខាធិកាដ្ឋាននៃក្រុមការងារអន្តរក្រសួងអនុវត្តឱ្យបានត្រឹមត្រូវ ឯកភាពគ្នា និងបង្កភាពងាយស្រួលក្នុងការផ្តល់សេវា ដើម្បីដោះស្រាយការកកស្ទះនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនិងការចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ។

គួររំលឹកផងដែរថា កន្លងមកអគ្គនាយកដ្ឋានពន្ធដារ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានសហការដោះស្រាយការកកស្ទះនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនិងការចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលទទួលបានការលើកលែងពន្ធប្រថាប់ត្រាស្របតាមបទប្បញ្ញត្តិស្តីពីពន្ធដារ (ពន្ធសូន្យ) នៅខេត្តកណ្តាលចប់សព្វគ្រប់ម្តងរួចទៅហើយ។ ប៉ុន្តែដោយសង្កេតឃើញថា បញ្ហាកកស្ទះឯកសារនេះ នៅតែមានចំពោះបណ្តាខេត្តមួយចំនួនទៀត ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានពិភាក្សាស្វែងរកយន្តការរួមមួយសម្រាប់ដោះស្រាយបញ្ហាកកស្ទះនេះតែម្តង៕

# កិច្ចប្រជុំលើកទី១៤ នៃក្រុមការងារចម្រុះរវាង អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដើម្បីពិនិត្យ និងពិភាក្សាលើវឌ្ឍនភាពការងារ ចែករំលែកទិន្នន័យ-ព័ត៌មាន នៃអគ្គនាយកដ្ឋានទាំងពីរ




*កិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សាលើវឌ្ឍនភាពការងារចែករំលែកទិន្នន័យ-ព័ត៌មាន រវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដឹកនាំដោយឯកឧត្តមបណ្ឌិត **កែន សម្បត្តិ** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*

នារសៀលថ្ងៃពុធ ទី៦ ខែមីនា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងពិភាក្សាលើវឌ្ឍនភាពការងារចែករំលែកទិន្នន័យ-ព័ត៌មាន រវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលដឹកនាំដោយ ឯកឧត្តមបណ្ឌិត **កែន សម្បត្តិ** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ និងឯកឧត្តម **សែ សុឃន** អគ្គនាយករងនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលជាសហប្រធានក្រុមការងារចម្រុះរវាង អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានទាំងពីរ។

ជាកិច្ចចាប់ផ្តើមនៃកិច្ចប្រជុំ ឯកឧត្តមបណ្ឌិត **កែន សម្បត្តិ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារបានរំលឹក និងលើកឡើងថា កន្លងមកអគ្គនាយកដ្ឋានទាំងពីរបានសហការគ្នាក្នុងការបង្កើតមុខងារសន្ទានកម្មប្រព័ន្ធស្វ័យប្រវត្តិកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលបានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការតាំងពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១។ តាមរយៈការចែករំលែកទិន្នន័យ-ព័ត៌មានតាមរយៈមុខងារសន្ទានកម្មប្រព័ន្ធស្វ័យប្រវត្តិកម្មនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននេះធ្វើឱ្យអគ្គនាយកដ្ឋានទាំងពីរ ទទួលបាននូវសក្តានុពល និងកាលានុវត្តបច្ចេកវិទ្យាព័ត៌មាន ដែលជាការបង្ហាញនូវការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តប្រកបដោយភាពម៉ឺងម៉ាត់ ទាន់ពេលវេលា ទាន់សភាពការណ៍ និងមានភាពប្រទាក់ក្រឡាគ្នា សំដៅកាត់បន្ថយការគេចវេះនិងបន្លំពន្ធ ក្នុងគោលដៅពង្រឹងអនុលោមភាពសារពើពន្ធនិងជាប្រយោជន៍នៃការកៀរគរប្រមូលចំណូលពន្ធចូលថវិកាជាតិរបស់អគ្គនាយកដ្ឋានទាំងពីរឱ្យអស់សក្តានុពល និងធានាបាននូវចីរភាព នៃកំណើនចំណូលពន្ធក្រោមឆត្រនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជំរុញការអភិវឌ្ឍសង្គមសេដ្ឋកិច្ច រក្សាបាននូវសុខសន្តិភាព និងធានាចីរភាពនៃកំណើនសេដ្ឋកិច្ចជាតិ ក្រោមការចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**។

គួរបញ្ជាក់ផងដែរថា មុខងារសន្ទានកម្មប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ បានអនុញ្ញាតឱ្យអគ្គនាយកដ្ឋានទាំងពីរ អាចទាញយកទិន្នន័យចេញពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អគ្គនាយកដ្ឋានពន្ធដារ ឬអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានតាមតម្រូវការភ្លាមៗ ប្រកបដោយតម្លាភាពនិងសុវត្ថិភាពខ្ពស់។

ទិន្នន័យដែលត្រូវចែករំលែកតាមមុខងារសន្ទានកម្មប្រព័ន្ធស្វ័យប្រវត្តិកម្ម និងតាមការស្នើសុំរួមមាន៖ ១.ព័ត៌មាននៃការចុះបញ្ជីសហគ្រាស ២.ព័ត៌មាននៃការប្រកាសសារពើពន្ធ ៣.ព័ត៌មាននៃការប្រកាសប្រតិវេទន៍ទំនិញនាំចេញ-នាំចូល និងព័ត៌មានចាំបាច់មួយចំនួនទៀត។

បន្ទាប់ពីបានពិនិត្យនិងពិភាក្សាគ្នារួចមក ដោយមានវឌ្ឍនភាពល្អក្នុងការផ្លាស់ប្ដូរ និងប្រើប្រាស់ទិន្នន័យគ្នាទៅវិញទៅមកតាមរយៈមុខងារសន្ទានកម្មប្រព័ន្ធស្វ័យប្រវត្តិកម្មរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋានទាំងពីរ សម្រាប់ពង្រឹងអនុលោមភាពសារពើពន្ធ និងកិច្ចការពាក់ព័ន្ធអង្គប្រជុំបានធ្វើការកត់សម្គាល់លើកិច្ចការមួយចំនួន ហើយបានជំរុញក្រុមការងារចម្រុះនៃអគ្គនាយកដ្ឋានទាំងពីរ និងជាពិសេសក្រុមការងារបច្ចេកទេសបន្តសហការគ្នាល្អ និងជិតស្និទ្ធថែមទៀត ដើម្បីឱ្យការចែករំលែកទិន្នន័យ-ព័ត៌មាននៃអគ្គនាយកដ្ឋានទាំងពីរប្រព្រឹត្តទៅកាន់តែមានភាពគ្រប់ជ្រុងជ្រោយ និងប្រសិទ្ធភាពខ្ពស់៕





# ៣. កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន អង្គការ សមាគម និងស្ថាប័នអន្តរជាតិ

## ការចូលរួមសិក្ខាសាលាស្តីពី កម្ពុជាទំព័រថ្មី "ឱកាសធុរកិច្ច និងការវិនិយោគ" (Cambodia's New Page: Business and Investment Opportunities)




*លោកជំទាវ **ប៊ុន នារី** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ ចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាស្តីពីកម្ពុជាទំព័រថ្មី "ឱកាសធុរកិច្ច និងការវិនិយោគ"*

នាព្រឹកថ្ងៃសុក្រ ទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤ នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ លោកជំទាវ **ប៊ុន នារី** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ បានចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាស្តីពីកម្ពុជាទំព័រថ្មី "ឱកាសធុរកិច្ច និងការវិនិយោគ" (Cambodia's New Page: Business and Investment Opportunities) ដែលរៀបចំឡើងដោយស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃ។ សិក្ខាសាលានេះមានការចូលរួមពីឯកឧត្តម **ហ៊ុន សារឿន** ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃ ឯកឧត្តម **ផាន់ ផល្លា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតំណាងក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តំណាងស្ថានទូតបរទេសនៅទីក្រុងបាងកក អង្គការអន្តរជាតិ ក្រសួងស្ថាប័នរដ្ឋនិងវិស័យឯកជននៅព្រះរាជាណាចក្រថៃ ព្រមទាំងសមាគមមិត្តភាពថៃ-កម្ពុជា និងសមាគមឧកញ៉ាកម្ពុជា សរុបប្រមាណ **២៣០ នាក់**។

ស្របតាមរបៀបវារៈដែលបានគ្រោងទុក លោកជំទាវអគ្គនាយករង បានធ្វើបទបង្ហាញជូនអង្គសិក្ខាសាលាលើប្រធានបទស្តីពី "ប្រព័ន្ធពន្ធដារ និងនីតិវិធីទូទៅ" ដោយផ្តោតលើគោលការណ៍គន្លឹះសំខាន់ៗ ដូចខាងក្រោម៖

១. ច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារនិងនីតិវិធីទូទៅ៖ របបកំណត់ពន្ធ ប្រភេទពន្ធនីមួយៗ ប្រភេទអ្នកជាប់ពន្ធ នីតិវិធីនៃការចុះបញ្ជីពន្ធដារ និងការដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែនិងប្រចាំឆ្នាំ។

២. គោលនយោបាយរបស់រាជរដ្ឋាភិបាលដែលមិនបង្កើតពន្ធថ្មី មិនដំឡើងអត្រាពន្ធ ដោយវិនិយោគិនទទួលបាននូវការលើកទឹកចិត្តផ្នែកពន្ធដារដែលមានស្រាប់ និងការលើកទឹកចិត្តថ្មីៗបន្ថែមទៀត។

៣. ការលើកទឹកចិត្តផ្នែកពន្ធដារចំពោះគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ តំបន់សេដ្ឋកិច្ចពិសេស កម្មវិធី

ពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុឆ្នាំ២០២៤ សហគ្រាសធុនតូចនិងមធ្យម វិស័យអប់រំ វិស័យអចលនទ្រព្យ វិស័យវាយនភណ្ឌ វិស័យមូលបត្រ និងវិស័យកសិកម្ម។

៤. កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលរវាងប្រទេសកម្ពុជានិងបណ្តាប្រទេសមួយចំនួននិងអត្ថប្រយោជន៍ដែលទទួលបានពីកិច្ចព្រមព្រៀងនេះ។

សិក្ខាសាលានេះ រៀបចំឡើងក្នុងគោលបំណងបង្ហាញនូវ ១.វឌ្ឍនភាពថ្មីៗនៃស្ថានភាពនយោបាយនិងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជា ២.កាលានុវត្តភាពនៃគោលនយោបាយលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល នីតិវិធីចាំបាច់ក្នុងការវិនិយោគ និងការធ្វើធុរកិច្ចនៅកម្ពុជា ៣.បច្ចុប្បន្នភាពនៃទីផ្សារក្នុងស្រុក ពាណិជ្ជកម្មអន្តរជាតិ កិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីនិងពហុភាគីរវាងកម្ពុជា និងបណ្តាប្រទេសក្នុងតំបន់និងសកលលោក និង៤.ទាក់ទាញវិនិយោគិនបរទេសឱ្យទៅបណ្តាក់ទុននៅកម្ពុជា៕



*លោកជំទាវ **ប៊ុន នារី** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*



# កិច្ចពិភាក្សាតុមូលស្តីពី "ច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ និងពាណិជ្ជកម្ម" ក្នុងកម្មវិធី KPMG Tax Institute




*កិច្ចពិភាក្សាតុមូល ស្តីពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារនិងពាណិជ្ជកម្ម ក្នុងកម្មវិធី KPMG Tax Institute ក្រោមអធិបតីភាពលោកជំទាវ **ប៊ុន នារី** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*

នារសៀលថ្ងៃសុក្រ ទី១ ខែមីនា ឆ្នាំ២០២៤ នៅសណ្ឋាគារ Hyatt Regency Phnom Penh មានរៀបចំកិច្ចពិភាក្សាតុមូល ស្តីពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារនិងពាណិជ្ជកម្ម ក្នុងកម្មវិធី KPMG Tax Institute ក្រោមអធិបតីភាពលោកជំទាវ **ប៊ុន នារី** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ អមដោយថ្នាក់ដឹកនាំ មន្ត្រីជំនាញនៃអគ្គ-នាយកដ្ឋានពន្ធដារនិងវត្តមានចូលរួមរបស់ថ្នាក់ដឹកនាំបុគ្គលិកនៃក្រុមហ៊ុនKPMGព្រមទាំងមានការចូលរួមពីតំណាងសហគ្រាស វិនិយោគិនក្នុងស្រុក និងក្រៅស្រុកផងដែរ។

លោកជំទាវ **ប៊ុន នារី** អគ្គនាយករង បានគូសបញ្ជាក់ថា យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដែលត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា គឺជាមូលដ្ឋានគ្រឹះមួយដើម្បីសម្រេចបាននូវចក្ខុវិស័យរបស់កម្ពុជាឆ្នាំ២០៥០ ជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់។ យុទ្ធសាស្ត្រនេះ គឺផ្តោតលើការធានានូវប្រសិទ្ធភាពសមិទ្ធកម្មតាមរយៈការអនុវត្តអភិបាលកិច្ចល្អ និងជវភាពនៃប្រព័ន្ធតួអង្គតែមួយ ដែលជាក្របខ័ណ្ឌគោលនយោបាយមុតស្រួចលើកកម្ពស់ការប្រកួតប្រជែង បង្កើនពិពិធកម្ម និងការបង្កើនភាពធន់សម្រាប់កំណើនសេដ្ឋកិច្ច។ រដ្ឋាភិបាលកម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលនៃការបង្កើតយុទ្ធសាស្ត្រកៀរគរចំណូល ដំណាក់កាលទី៣ (២០២៤-២០២៨) ដែលផ្តោតលើគោលការណ៍ស្នូល៖ ១.ធានាកំណើនសេដ្ឋកិច្ច បង្កើតបរិយាកាសអំណោយផលសម្រាប់សកម្មភាពសេដ្ឋកិច្ច និងជំរុញសកម្មភាពពាណិជ្ជកម្ម ២.មិនបង្កើតបន្ទុកពន្ធថ្មី បន្តការលើកលែងពន្ធដែលមានស្រាប់ និងធានាយន្តការប្រមូលពន្ធមិនត្រួតស៊ីគ្នា ព្រមទាំងពង្រឹងយន្តការឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកជាប់ពន្ធ តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា និងពង្រឹងក្រមសីលធម៌មន្ត្រីរាជការពន្ធដារ ៣.រៀបចំយុទ្ធសាស្ត្រដ៏មុតស្រួច ដែលមានចរិតបង្កើតប្រាក់ចំណូល ប៉ុន្តែមិនបង្កឱ្យមានវិការភាពសេដ្ឋកិច្ច និងធានាបាននូវសមធម៌ និង៤.ធានានូវការចូលរួមពីវិស័យឯកជន ដើម្បីធានាទស្សនៈរួម ភាពគ្រប់ជ្រុងជ្រោយ និងភាពជាក់ស្តែង។

ជាមួយគ្នានេះ អនុលោមតាមច្បាប់ស្តីពីសារពើពន្ធ និងស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ក៏ដូចជាគោលនយោបាយនៃយុទ្ធសាស្ត្រកៀរគរចំណូលរបស់រដ្ឋាភិបាលនាពេលអនាគត អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវសកម្មភាពអាទិភាពលើ៖ ១.ពិនិត្យឡើងវិញនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដែលកំពុងអនុវត្ត ដើម្បីធ្វើបច្ចុប្បន្នភាព

ឱ្យមានសង្គតិភាព ភាពច្បាស់លាស់ និងងាយស្រួលប្រើប្រាស់ ២.រៀបចំផែនការយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានពន្ធដារ ២០២៤-២០២៨ ដើម្បីសម្រេចបាននូវគោលដៅទី១៖ បង្កើនអនុលោមភាពសារពើពន្ធ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវគុណភាពសេវាកម្ម ភាពច្បាស់លាស់ តម្លាភាព និងគណនេយ្យភាព ព្រមទាំងការពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ គោលដៅទី២៖ ទំនើបភាវូបនីយកម្មនៃមុខងារស្នូល និងមុខងារគាំទ្រ ក្នុងគោលបំណងឱ្យក្លាយជារដ្ឋបាលសារពើពន្ធជំនាន់ទី២ តាមរយៈការពង្រឹងនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាឌីជីថល និងគោលដៅទី៣៖ បន្តអភិវឌ្ឍមូលធនមនុស្ស និងការអភិវឌ្ឍស្ថាប័ន និង៣.ទំនើបកម្មនៃរដ្ឋបាលសារពើពន្ធជាទម្រង់បច្ចេកវិទ្យាព័ត៌មានដែលមានដូចជា e-Filing, e-Payment, GDT Taxpayer App និង e-Tax Services ជាដើម។ ក្នុងន័យនេះ សូមបញ្ជាក់ថាកាលពីពេលថ្មីៗនេះ អគ្គនាយកដ្ឋានពន្ធដារ បានបង្កើតកម្មវិធី GDT e-Administration ដែលផ្តល់ភាពងាយស្រួលជាងមុនដល់អ្នកជាប់ពន្ធក្នុងការដាក់ និងតាមដានលិខិតរដ្ឋបាលដោយមិនចាំបាច់មកជួបរដ្ឋបាលសារពើពន្ធផ្ទាល់ ដែលនឹងដាក់ឱ្យដំណើរការជាផ្លូវការក្នុងពេលឆាប់ៗនេះ។

ស្របតាមលទ្ធផលនៃវេទិការាជរដ្ឋាភិបាល-វិស័យឯកជន (GPSF) លើកទី១៩ នាពេលថ្មីៗនេះ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីដោះស្រាយនូវកង្វល់សម្រួលធុរកិច្ច និងការប្រកួតប្រជែង ក៏ដូចជាការសម្រាលបន្ទុកដល់អ្នកជាប់ពន្ធទូទៅនិងភាគីពាក់ព័ន្ធ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំសេចក្តីព្រាងប្រកាស សេចក្តីណែនាំ សេចក្តីជូនដំណឹងមួយចំនួន ដាក់ឱ្យអនុវត្តសម្រាប់លើកទឹកចិត្តផ្នែកពន្ធដាររួមមាន៖ ១.ការផ្តល់ការអនុគ្រោះព្យួរទុកជាបណ្តោះអាសន្ននូវការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែរហូតដល់ដំណាច់ឆ្នាំ២០២៥ សម្រាប់សហគ្រាស គ.ល.គ រួមមាន សហគ្រាសផលិតស្លាកយីហោសម្រាប់សម្លៀកបំពាក់ ផលិតផលស្រោមដៃ ស្រោមជើង កន្សែង ស្រោមខ្នើយ ស្រោមភួយ កម្រាលពូក និងកម្រាលតុ ២.ការលើកលែងទណ្ឌកម្មរដ្ឋបាលចំពោះការកែតម្រូវលិខិតប្រកាសដោយស្ម័គ្រចិត្ត ទុកពេលរហូតដំណាច់ខែមិថុនា ឆ្នាំ២០២៤ ៣.ការផ្តល់ការបន្ធូរបន្ថយពន្ធប្រថាប់ត្រា ពន្ធលើចំណេញមូលធន ពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ៤.ការលើកទឹកចិត្តផ្នែកពន្ធដារលើវិស័យទេសចរណ៍ចំពោះសណ្ឋាគារ ផ្ទះសំណាក់ ក្រុមហ៊ុនភ្នាក់ងារទេសចរណ៍និងភោជនីយដ្ឋាន ដែលមានសកម្មភាពអាជីវកម្មនៅខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តកែប ខេត្តកំពត និងរាជធានីភ្នំពេញ និង៥.ការផ្តល់ការសម្រួលដល់សហគ្រាសក្នុងវិស័យកសិកម្ម ដោយបន្ធូរបន្ថយការអនុវត្តវិធានវិក្កយបត្រចំពោះប្រតិបត្តិការជាមួយកសិករ។

ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំនិយាមនីតិវិធីប្រតិបត្តិការងារ (SOP) សម្រាប់ពន្ធមួយចំនួន និងទិដ្ឋភាពផ្សេងៗនៃមុខងាររបស់អគ្គនាយកដ្ឋានពន្ធដារ ដែលជាគំនិតផ្តួចផ្តើមមួយដើម្បីកែលម្អការអនុវត្តការងារឱ្យមានតម្លាភាព និងអាចព្យាករបានសម្រាប់សហគ្រាសអាជីវកម្ម ជាពិសេសគឺនិយាមនីតិវិធីប្រតិបត្តិការងារស្តីពីសវនកម្មពន្ធដារដែលជាគោលដៅអាទិភាពមុនគេ ដោយសារត្រូវបានលើកឡើងជាញឹកញាប់ពីវិស័យឯកជន ដែល SOP មួយនេះកំណត់យ៉ាងច្បាស់លាស់នូវវិសាលភាពនៃសវនកម្មពន្ធដារ នីតិវិធី និងក្រមសីលធម៌សម្រាប់សវនករពន្ធដារ ក្នុងកិច្ចដំណើរការការងារ។ បច្ចុប្បន្ននេះ សេចក្តីព្រាង SOP នេះ ត្រូវបានពិនិត្យ និងបញ្ចូលធាតុចូលពីវិស័យឯកជន ហើយឥឡូវនេះឯកសារកំពុងស្ថិតក្នុងដំណាក់កាលស្នើសុំការអនុម័ត។

នៅក្នុងកម្មវិធីនេះផងដែរ ក៏មានកិច្ចពិភាក្សាតុមូលលើប្រធានបទសំខាន់ៗទាក់ទងនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ និងការធ្វើសវនកម្មពីវាគ្មិនជំនាញពាក់ព័ន្ធរួមមាន លោក **អេង រតនា** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ លោក **តែ ហង្សឌី** ប្រធាននាយកដ្ឋានសវនកម្មសហគ្រាស លោក **សេង ជាសិទ្ធ** ប្រធាន នាយកដ្ឋាននីតិកម្មគោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ លោក **Hoang Thuy Duong** Partner and Head of Tax នៃក្រុមហ៊ុន KPMG Cambodia and Vietnam អ្នកនាង **តាន់ ម៉ូណា** ប្រធាននាយកដ្ឋានសារពើពន្ធនៃក្រុមហ៊ុន KPMG Cambodia និងសម្របសម្រួលដោយអ្នកនាង **Andrea Godfrey** ប្រធានផ្នែកពន្ធដារអន្តរជាតិនៃក្រុមហ៊ុន KPMG Cambodia៕

# កិច្ចប្រជុំពិភាក្សាអំពីកម្មវិធីពាណិជ្ជកម្ម និងភាពប្រកួតប្រជែង ជាមួយក្រុមបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី



នាព្រឹកថ្ងៃចន្ទ ទី៤ ខែមីនា ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ លោក **សេង ជាសិទ្ធ** ប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ តំណាងឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ បានទទួលជួបពិភាក្សាការងារអំពីកម្មវិធីពាណិជ្ជកម្ម និងភាពប្រកួតប្រជែង ជាមួយក្រុមបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank – ADB) ដឹកនាំដោយលោក Sion Morton ប្រធានក្រុមបេសកកម្ម ដោយមានការចូលរួមពីលោកស្រី Minsoo Kim នាយករងនៃធនាគារនីហារ័ណ-អាហារ័ណកូរ៉េ (The Export-Import Bank of Korea – Korea Eximbank) ប្រចាំកម្ពុជា និងសេដ្ឋវិទូជាន់ខ្ពស់នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ព្រមទាំងមានវត្តមានចូលរួមពីតំណាងនាយកដ្ឋាន និងមន្ត្រីជំនាញពាក់ព័ន្ធ នៃអគ្គនាយកដ្ឋានពន្ធដារ។

លោក **សេង ជាសិទ្ធ** ប្រធាននាយកដ្ឋានបានគូសបញ្ជាក់អំពីកិច្ចសហប្រតិបត្តិការដ៏ល្អនាពេលកន្លងមករវាងអគ្គនាយកដ្ឋានពន្ធដារ និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្រោមក្របខ័ណ្ឌជំនួយបច្ចេកទេស ការប្រឹក្សាយោបល់ និងវគ្គបណ្តុះបណ្តាលផ្សេងៗពាក់ព័ន្ធនឹងពន្ធដារ។ លោកប្រធាននាយកដ្ឋានបានអនុញ្ញាតឱ្យក្រុមបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) លើកឡើងអំពីគោលបំណងសំខាន់នៃដំណើរបេសកកម្មការងារនេះ និងបន្តធ្វើបទបង្ហាញលម្អិតអំពីកម្មវិធីពាណិជ្ជកម្ម និងភាពប្រកួតប្រជែង។

ជាកិច្ចឆ្លើយតប លោក Sion Morton ប្រធានក្រុមបេសកកម្មបានគូសបញ្ជាក់ថា កម្មវិធីពាណិជ្ជកម្ម និងភាពប្រកួតប្រជែងនេះ សំដៅដល់ការស្វែងរកការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តកំណែទម្រង់ជាអាទិភាព ដើម្បីលើកកម្ពស់សមត្ថភាពប្រកួតប្រជែងអន្តរជាតិរបស់កម្ពុជា។ ក្របខ័ណ្ឌកម្មវិធីនេះ ត្រូវបានអនុម័តយល់ព្រម រួមគ្នាដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងរាជរដ្ឋាភិបាលកម្ពុជា ហើយបានដាក់ចេញនូវសកម្មភាពគោលនយោបាយ ដែលត្រូវសម្រេចឱ្យបាននៅក្នុងចន្លោះពីខែកុម្ភៈ ឆ្នាំ២០២០ ដល់ខែសីហា ឆ្នាំ២០២២ (អនុកម្មវិធីទី១) ក្នុងចន្លោះ ពីខែកញ្ញា ឆ្នាំ២០២២ ដល់ខែសីហា ឆ្នាំ២០២៤ (អនុកម្មវិធីទី២) និងក្នុងចន្លោះពីខែកញ្ញា ឆ្នាំ២០២៤ ដល់ខែសីហា ឆ្នាំ២០២៦ (អនុកម្មវិធីទី៣)។ ទន្ទឹមនឹងនេះ កម្មវិធីនេះបានកំណត់នូវផ្នែកសម្រាប់កំណែទម្រង់ចំនួន ៣ រួមមាន ១.ការលើកកម្ពស់បរិយាកាសអំណោយផលសម្រាប់ការវិនិយោគ និងការធ្វើធុរកិច្ច ២.ការពង្រីកអាជីវកម្មខ្នាតមីក្រូ តូចនិងមធ្យម និង៣.ការកែលម្អគោលនយោបាយពាណិជ្ជកម្ម និងការសម្រួលពាណិជ្ជកម្ម ដែលលទ្ធផលចុងក្រោយ (Outcome)

គឺសំដៅដល់ការបង្កើតឱ្យមានបរិយាកាសធុរកិច្ចប្រកបដោយលក្ខណៈប្រកួតប្រជែង និងមានភាពងាយស្រួលសម្រាប់ការវិនិយោគ។

ស្របជាមួយគ្នានេះ លោក Sion Morton ប្រធានក្រុមបេសកកម្ម បានលើកឡើងថា ដំណើរបេសកកម្មការងារនេះ មានគោលបំណងចំនួន ៤ រួមមាន៖ ១.វាយតម្លៃវឌ្ឍនភាពសម្រាប់ការអនុវត្តសកម្មភាពគោលនយោបាយ ក្រោមអនុកម្មវិធីទី២ ២.ធ្វើសុពលភាពបន្តពាក់ព័ន្ធនៃសកម្មភាពដែលបានស្នើឡើងក្រោមអនុកម្មវិធីទី៣ ៣.កំណត់ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដែលមានចំណាប់អារម្មណ៍ក្នុងការចូលរួមកម្មវិធីនេះ និង៤.ពិភាក្សាអំពីតម្រូវការជំនួយបច្ចេកទេស (Technical Assistance) ទាក់ទិននឹងសកម្មភាពគោលនយោបាយ។

បន្ទាប់ពីបទបង្ហាញត្រូវបានបញ្ចប់ អង្គប្រជុំបានពិភាក្សាអំពីអាទិភាពកំណែទម្រង់រយៈពេលមធ្យមរបស់អគ្គនាយកដ្ឋានពន្ធដារ ឆ្លុះបញ្ចាំងពីលទ្ធភាពនៃការរួមបញ្ចូលសកម្មភាពគោលនយោបាយក្រោមកម្មវិធីពាណិជ្ជកម្ម និងភាពប្រកួតប្រជែង ដែលទាក់ទិនទៅនឹងតួនាទីសំខាន់របស់អគ្គនាយកដ្ឋានពន្ធដារក្នុងការបង្កបរិយាកាសអំណោយផលសម្រាប់អាជីវកម្ម និងការវិនិយោគនៅកម្ពុជា និងពិភាក្សាអំពីរបៀបដែលធនាគារអភិវឌ្ឍន៍អាស៊ី (ADB) អាចមានលទ្ធភាពគាំទ្រការងាររបស់អគ្គនាយកដ្ឋានពន្ធដារ តាមរយៈការងារវិភាគ ការចែករំលែកចំណេះដឹង ឬជំនួយបច្ចេកទេស៕






# កិច្ចប្រជុំលើកទី១៨ នៃក្រុមការងារវេទិកាអាស៊ានស្តីពីពន្ធដារ (ASEAN Forum on Taxation-AFT) និងកិច្ចប្រជុំលើកទី១៥ នៃក្រុមការងារអនុវេទិកាអាស៊ានស្តីពីអាករពិសេស (ASEAN Sub-Forum on Excise Taxation-SFET)




*កិច្ចពិភាក្សាតុមូល ស្តីពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារនិងពាណិជ្ជកម្ម ក្នុងកម្មវិធី KPMG Tax Institute*
*ក្រោមអធិបតីភាពលោកជំទាវ **ប៊ុន នារី** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*

នាថ្ងៃទី២០ដល់២២ ខែមីនា ឆ្នាំ២០២៤ គណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារ ដឹកនាំដោយលោក **សេង ជាសិទ្ធ** ប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ តំណាងឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អមដោយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញពាក់ព័ន្ធ នៃអគ្គនាយកដ្ឋានពន្ធដារ បានចូលរួមកិច្ចប្រជុំលើកទី១៨ នៃក្រុមការងារវេទិកាអាស៊ានស្តីពីពន្ធដារ ( ASEAN Forum on Taxation-AFT ) និងកិច្ចប្រជុំលើកទី១៥ នៃក្រុមការងារអនុវេទិកាអាស៊ានស្តីពីអាករពិសេស ( ASEAN Sub-Forum on Excise Taxation-SFET ) ជាលក្ខណៈរូបវន្ត នៅទីក្រុងវៀងចន្ទ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលជាប្រទេសប្រធានប្តូរវេននៃកិច្ចប្រជុំ AFT និង SFET សម្រាប់ឆ្នាំ២០២៤ នេះ។ កិច្ចប្រជុំនេះដឹកនាំដោយ លោក Thammaloth RASPHONE អគ្គនាយករង និងលោក Sivay VILAIHAN ប្រធានផ្នែកផែនការ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ នៃនាយកដ្ឋានពន្ធដារ នៃក្រសួងហិរញ្ញវត្ថុឡាវ ដែលជាសហប្រធានដឹកនាំកិច្ចប្រជុំ ព្រមទាំងមានការចូលរួមពីតំណាងមកពីបណ្តារដ្ឋសមាជិកអាស៊ាន ( ASEAN Member State-AMS ) ទាំងអស់ តំណាងលេខាធិការដ្ឋានអាស៊ាន ( ASEAN Secretariat-ASEC ) តំណាងធនាគារអភិវឌ្ឍន៍អាស៊ី ( Asian Development Bank-ADB ) អង្គការសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច ( Organization for Economic Cooperation and Development-OECD ) អង្គការសុខភាពពិភពលោក ( World Health Organization-WHO ) និងក្រុមហ៊ុន Ernst & Young ( EY UK ) ផងដែរ។

ជាកិច្ចចាប់ផ្តើម លោក Thammaloth RASPHONE បានថ្លែងសុន្ទរកថាបើកកិច្ចប្រជុំ ដោយបានវាយតម្លៃខ្ពស់នៃ

ការចូលរួមរបស់គ្រប់ភាគីពាក់ព័ន្ធ ជាពិសេសរដ្ឋជាសមាជិកអាស៊ាន។ សម្រាប់ឆ្នាំ២០២៤ ដែលឡាវ ជាប្រធានប្តូរវេននៃកិច្ចប្រជុំ AFT និង SFET បន្ទាប់ពីឥណ្ឌូនេស៊ីនេះ AFT និង SFET បានបន្តពិភាក្សាលើរបៀបវារៈសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- រហូតមកដល់ពេលនេះ មាន DTA ចំនួន ៧៤ ហើយត្រូវបានចុះហត្ថលេខា ក្នុងចំណោមកិច្ចព្រមព្រៀង DTA សរុបចំនួន ៩០ ក្នុងអាស៊ាន។ កម្ពុជាក៏បានរាយការណ៍ជូនអង្គប្រជុំដែរថា សម្រាប់កិច្ចព្រមព្រៀង DTA ជាមួយ AMS ចំនួន ៣ ដែលនៅសេសសល់ថ្មីៗនេះ កម្ពុជាបានបញ្ចប់ការចរចាជាមួយឡាវនិងកំពុងត្រៀមរៀបចំសម្រាប់ការចុះហត្ថលេខា រីឯជាមួយហ្វីលីពីន និងមីយ៉ាន់ម៉ា ការចរចានឹងត្រូវរៀបចំក្នុងខែមេសា និងត្រីមាសទី៤ ខាងមុខនេះ បន្តបន្ទាប់គ្នា
- ឧត្តមានុវត្តន៍ (Best Practices-BPs) នៃការសិក្សាលើរចនាសម្ព័ន្ធពន្ធកាត់ទុកលើការប្រាក់របស់អាស៊ាន ដោយបានផ្តោតទៅលើការអនុវត្តច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ និងតម្រូវការឯកសារពាក់ព័ន្ធ។ គួររំលឹកដែរថា ក្នុងនាមជាប្រធានរបស់កិច្ចប្រជុំ AFT ក្នុងឆ្នាំ២០២២ កន្លងទៅ កម្ពុជាបានផ្តួចផ្តើមឱ្យមានយន្តការបោះឆ្នោតជ្រើសរើស BP ដែលមានអាទិភាពជាងគេ មកពិភាក្សា។ រហូតមកដល់បច្ចុប្បន្ននេះ មាន BP ចំនួន ៦ ក្នុងចំណោម ១២ ត្រូវបានជ្រើសរើសមកពិភាក្សាលម្អិត ដោយអនុលោមតាមគោលការណ៍មូលមតិគ្នា (Consensus)។ សម្រាប់ឆ្នាំ២០២៤ នេះ ប្រធានអង្គប្រជុំឡាវ បានជ្រើសរើសដោយផ្ទាល់នូវ BP ចំនួន ២ មកបន្តពិភាក្សា គឺ BP ទី៣ “Verify compliance with eligibility requirements through audit” និង BP ទី៤ “Standardize relief claims and processes across the community with a view to establishing a regional claims procedure” មកពិភាក្សា។ កម្ពុជាបានជម្រាបជូនអង្គប្រជុំអំពីផលប្រយោជន៍ និងបញ្ហាប្រឈមនៃការអនុវត្តជាក់ស្តែងទាក់ទិននឹងBPទាំងពីរនេះហើយក៏បានសង្កត់ធ្ងន់ដែរថាAMSនីមួយៗមានច្បាប់បទប្បញ្ញត្តិនិងនីតិវិធីផ្ទៃក្នុងខុសៗគ្នា ដែលនាំឱ្យការចាប់យក BP ទាំងពីរ នេះ មកអនុវត្តនឹងក្លាយជាបន្ទុកបន្ថែមសម្រាប់រដ្ឋបាលសារពើពន្ធ
- ការរៀបចំ និងប្រមូលផ្តុំច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងអាករពិសេសក្នុងអាស៊ាន
- បញ្ហាប្រឈមក្នុងការគ្រប់គ្រង និងប្រមូលពន្ធលើបារីអេឡិចត្រូនិក (E-Cigarettes) និងការគ្រប់គ្រងប្រមូលអាករ ផលិតផលជាប់អាករពិសេសតាមប្រព័ន្ធឌីជីថល (Digital Solutions to Administering Excise Tax)
- ការកសាងសមត្ថភាព ការចែករំលែកបទពិសោធន៍ និងភាពរួចរាល់របស់អាស៊ាន សម្រាប់ការដោះស្រាយបញ្ហាថ្មីៗ ដែលបាននិងកំពុងកើតឡើងពាក់ព័ន្ធនឹងពន្ធអន្តរជាតិ និងអាករពិសេសជាដើម។

អង្គប្រជុំក៏បានកត់សម្គាល់អំពីរបាយការណ៍របស់ ASEC ទាក់ទិននឹងការរៀបចំសហគមន៍សេដ្ឋកិច្ចអាស៊ាន ក្រោយឆ្នាំ ២០២៥ (AEC Post 2025) និងបច្ចុប្បន្នភាពនៃការអនុវត្តសសរស្តម្ភ១ និង ២ (Pillar 1 & 2) ដែលឧទ្ទេសនាម ដោយជំនាញការពី ADB និង OECD។ កិច្ចប្រជុំបានបញ្ចប់ទៅយ៉ាងជោគជ័យ និងទទួលបានលទ្ធផលជាវិជ្ជមានក្នុងស្មារតីទទួលខុសត្រូវ និងគោលការណ៍មូលមតិគ្នា (Consensus) ដែលនៅក្នុងសុន្ទរកថាបិទកិច្ចប្រជុំ លោក Thammaloth RASPHONE សហប្រធានកិច្ចប្រជុំក៏បានវាយតម្លៃខ្ពស់ចំពោះភាគីពាក់ព័ន្ធទាំងអស់ដែលបានចូលរួមនិងគាំទ្រភាពជាប្រធានរបស់ឡាវ ក្នុងឆ្នាំ២០២៤ នេះ៕

# កិច្ចប្រជុំពិភាក្សាលើគម្រោងជំនួយបច្ចេកទេសក្រោមកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈពាក់ព័ន្ធនឹងការគ្រប់គ្រងប្រមូលចំណូលពន្ធ ចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងរូបិយប័ណ្ណឌីជីថល



នាព្រឹកថ្ងៃសុក្រ ទី២២ ខែមីនា ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ លោកបណ្ឌិត **អេង រតនា** ប្រធាននាយក-ដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ តំណាងឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ បានទទួលជួបជាមួយនឹងលោក Paul Baker ដែលជាអ្នកប្រឹក្សាយោបល់របស់អង្គការ GIZ ប្រចាំនៅប្រទេសកម្ពុជា និងអ្នកតំណាងរបស់សហភាពអឺរ៉ុបប្រចាំនៅប្រទេសកម្ពុជា ដើម្បីពិភាក្សាអំពីលទ្ធផលបឋមនៃការសិក្សាស្រាវជ្រាវលើគម្រោងជំនួយបច្ចេកទេសក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពាក់ព័ន្ធនឹងការគ្រប់គ្រងប្រមូលចំណូលពន្ធចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងរូបិយប័ណ្ណឌីជីថល ព្រមទាំងមានវត្តមានចូលរួមពីលោក **សុខ កុសល** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមន្ត្រីជំនាញពាក់ព័ន្ធ នៃអគ្គនាយកដ្ឋានពន្ធដារ។

លោក Paul Baker បានធ្វើបទបង្ហាញអំពីការសិក្សារបស់ខ្លួនលើការគ្រប់គ្រងប្រមូលចំណូលពន្ធចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងរូបិយប័ណ្ណឌីជីថល ដោយក្នុងនោះរួមមាន ឧត្តមានុវត្តន៍ក្នុងការរៀបចំគោលនយោបាយ នីតិវិធីក្នុងការរៀបចំគោលនយោបាយ និងផែនទីចង្អុលផ្លូវពាក់ព័ន្ធនឹងគម្រោងជំនួយបច្ចេកទេសខាងលើ។ ជាមួយគ្នានេះ លោក Paul Baker ក៏បានបង្ហាញអំពី ការអនុវត្តសម្រាប់ការគ្រប់គ្រងប្រមូលចំណូលពន្ធចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងរូបិយប័ណ្ណឌីជីថល នៅតាមបណ្តាប្រទេសជាច្រើន រួមមាន ប្រទេសអង់គ្លេស វៀតណាម សិង្ហបុរី ម៉ាឡេស៊ី និង ថៃ ដើម្បីឱ្យរដ្ឋបាលសារពើពន្ធកម្ពុជាពិនិត្យមើលបន្ថែម និងផ្តល់ជាធាតុចូលក្នុងរបាយការណ៍សិក្សាស្រាវជ្រាវ។

បន្ទាប់ពីលោក Paul Baker បានបញ្ចប់បទបង្ហាញរបស់ខ្លួន លោកប្រធាននាយកដ្ឋានបានផ្តល់ជាធាតុចូលបន្ថែមលើលទ្ធផលបឋមនៃការសិក្សាស្រាវជ្រាវ ដើម្បីឱ្យលោក Paul Baker ពិនិត្យមើលបន្ថែម ក្នុងគោលដៅបញ្ចប់របាយការណ៍សិក្សាស្រាវជ្រាវលើការគ្រប់គ្រងប្រមូលចំណូលពន្ធចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនិងរូបិយប័ណ្ណឌីជីថល៕

# ផ្នែកទី៥

# ការផ្សព្វផ្សាយ និងបញ្ជ្រាបវប្បធម៌បង់ពន្ធ

១. កិច្ចការបណ្តុះបណ្តាល និងសិក្ខាសាលារបស់សាលាជាតិពន្ធដារ

២. ការស្រាវជ្រាវ អភិវឌ្ឍន៍កម្មវិធី និងបណ្ណាល័យ

៣. សិក្ខាសាលាសំខាន់ៗ

# ការផ្សព្វផ្សាយ និងបញ្ជ្រាបវប្បធម៌បង់ពន្ធ

ក្នុងគោលដៅពង្រឹងការយល់ដឹងអំពីពន្ធដារ ពាក់ព័ន្ធនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ការធ្វើទំនើបកម្មពន្ធដារ និងវឌ្ឍនភាពថ្មីៗ ជាពិសេសពាក់ព័ន្ធការផ្តល់សេវាអ្នកជាប់ពន្ធ ក្នុងខែមីនា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយនិងវគ្គបណ្តុះបណ្តាលចំនួន **៨២ លើក** មានសិក្ខាកាមចូលរួមចំនួន **១០ ៧៦៦ រូប** ក្នុងនោះ វគ្គបណ្តុះបណ្តាលចំនួន **២៥ លើក** មានសិក្ខាកាមចូលរួមចំនួន **៣ ៨២៨ រូប** និងសិក្ខាសាលាចំនួន **៥៧ លើក** មានសិក្ខាកាមចូលរួមចំនួន **៦ ៩៣៨ រូប**។

សរុបរយៈពេល ៣ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយនិងវគ្គបណ្តុះបណ្តាលចំនួន **២៤០ លើក** មានសិក្ខាកាមចូលរួមចំនួន **៣៤ ០១២ រូប** ក្នុងនោះវគ្គបណ្តុះបណ្តាលចំនួន **៦៩ លើក** មានសិក្ខាកាមចូលរួមចំនួន **១៨ ៨៦៦ រូប** និងសិក្ខាសាលាចំនួន **១៧១ លើក** មានសិក្ខាកាមចូលរួមចំនួន **១៥ ១៤៦ រូប**៕

**របាយការណ៍ ស្តីពីការរៀបចំវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា ក្នុងរយៈពេល ៣ខែដើមឆ្នាំ២០២៤**

| បរិយាយ | ចំនួនដង ក្នុងខែមករា | ចំនួនសិក្ខាកាម ក្នុងខែមករា | ចំនួនដង ក្នុងខែកុម្ភៈ | ចំនួនសិក្ខាកាម ក្នុងខែកុម្ភៈ | ចំនួនដង ក្នុងខែមីនា | ចំនួនសិក្ខាកាម ក្នុងខែមីនា | ចំនួនដង រយៈពេល៣ខែ | ចំនួនសិក្ខាកាម រយៈពេល៣ខែ |
|---|---|---|---|---|---|---|---|---|
| **I.វគ្គបណ្តុះបណ្តាល** | | | | | | | | |
| មន្ត្រីធនាគារដៃគូ | ០៤ | ១ ៥០៤ | ០៨ | ៤ ១៦០ | ០៤ | ១ ៥៦០ | ១៦ | ៧ ២២៤ |
| មន្ត្រីរាជការពន្ធដារ | ១១ | ៥ ៦៤១ | ២១ | ៣ ៧៣៣ | ២១ | ២ ២៦៨ | ៥៣ | ១១ ៦៤២ |
| អ្នកជាប់ពន្ធ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ |
| **សរុបវគ្គបណ្តុះបណ្តាល** | **១៥** | **៧ ១៤៥** | **២៩** | **៧ ៨៩៣** | **២៥** | **៣ ៨២៨** | **៦៩** | **១៨ ៨៦៦** |
| **II.សិក្ខាសាលា** | | | | | | | | |
| អ្នកជាប់ពន្ធ | ២៣ | ១ ១៥៦ | ៥៦ | ៥ ៥២៤ | ៥៥ | ៦ ៦៧៩ | ១៣៤ | ១៣ ៣៥៩ |
| មន្ត្រីរាជការពន្ធដារ | ០០ | ០០ | ២៧ | ៨៥២ | ០២ | ២៥៩ | ២៩ | ១ ១១១ |
| សិស្ស-និស្សិត | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ |
| សាធារណជន | ០១ | ១២២ | ០៧ | ៥៥៤ | ០០ | ០០ | ០៨ | ៦៧៦ |
| មន្ត្រីធនាគារដៃគូ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ |
| **សរុបសិក្ខាសាលា** | **២៤** | **១ ២៧៨** | **៩០** | **៦ ៩៣០** | **៥៧** | **៦ ៩៣៨** | **១៧១** | **១៥ ១៤៦** |
| **សរុបរួម** (I+II) | ៣៩ | ៨ ៤២៣ | ១១៩ | ១៤ ៨២៣ | ៨២ | ១០ ៧៦៦ | ២៤០ | ៣៤ ០១២ |







វគ្គបណ្តុះបណ្តាលស្តីពី "នីតិវិធីសវនកម្មនិង ក្រមសីលធម៌ វិន័យ វិជ្ជាជីវៈ សម្រាប់សវនករពន្ធដារនៃសាខាពន្ធដារខណ្ឌ" ក្រោមអធិបតីភាព ឯកឧត្តម **កែន សម្បត្តិ**



សិក្ខាសាលា ស្តីពី "ពន្ធលើប្រាក់ចំណូលនិងការកំណត់ហានិភ័យអ្នកជាប់ពន្ធ" ក្រោមអធិបតីភាព ឯកឧត្តម **រ័ត្ន មុន្នី**




សិក្ខាសាលា ស្តីពី "ពន្ធលើប្រាក់ចំណូល"



សិក្ខាសាលា ស្តីពី "ពន្ធលើប្រាក់ចំណូល"



សិក្ខាសាលា ស្តីពី "ពន្ធលើប្រាក់ចំណូល"



សិក្ខាសាលា ស្តីពី "ពន្ធលើប្រាក់ចំណូល"



សិក្ខាសាលា ស្តីពី "ពន្ធលើប្រាក់ចំណូល"



សិក្ខាសាលា ស្តីពី "ពន្ធលើប្រាក់ចំណូល"

# ១.កិច្ចការបណ្តុះបណ្តាល និងសិក្ខាសាលារបស់សាលាជាតិពន្ធដារ

## វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពន្ធដារ

ក្នុងត្រីមាសទី១ ឆ្នាំ២០២៤ នេះ សាលាជាតិពន្ធដារនៃអគ្គនាយកដ្ឋានពន្ធដារបានបើកវគ្គបណ្តុះបណ្តាល ជំនាញវិជ្ជាជីវៈពន្ធដារជំនាន់ទី១៨ ជូនសិក្ខាកាមដែលបានចុះឈ្មោះចូលរៀន ចំនួន **៤៤ ក្រុម** សរុបចំនួន **៧៨៦ នាក់**៕



នាព្រឹកថ្ងៃចន្ទ ទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ សាលាជាតិពន្ធដារបានរៀបចំបើកវគ្គបណ្តុះបណ្តាល ជំនាញវិជ្ជាជីវៈពន្ធដារជំនាន់ទី១៨ (Intake 1) ក្រោមអធិបតីភាព លោក **ស៊ុន វុទ្ធី** នាយកសាលាជាតិពន្ធដារ អមដោយថ្នាក់ដឹកនាំ លោកគ្រូ-អ្នកគ្រូ និងមន្ត្រី នៃសាលាជាតិពន្ធដារ ព្រមទាំងសិក្ខាកាមដែលបានចុះឈ្មោះសិក្សាសរុបចំនួន **១២០ នាក់**៕



*លោក ស៊ុន វុទ្ធី នាយកសាលាជាតិពន្ធដារ*



*សកម្មភាពសិក្សារបស់សិក្ខាកាម វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ*

## វគ្គបណ្តុះបណ្តាលខ្លីៗសម្រាប់អ្នកជាប់ពន្ធ និងសាធារណជនទូទៅ

ស្របតាមផែនការប្រតិបត្តិឆ្នាំ២០២៤ របស់សាលាជាតិពន្ធដារ នៅក្នុងត្រីមាសទី១ នេះ សាលាជាតិពន្ធដារបានបន្តបើកវគ្គបណ្តុះបណ្តាលខ្លីៗសរុបចំនួន ៩ ក្រុម ដែលមានសិក្ខាកាមចុះឈ្មោះសិក្សាចំនួន **២៨៨ នាក់**៕



## សិក្ខាសាលារបស់សាលាជាតិពន្ធដារ

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២៨ ខែមីនា ឆ្នាំ២០២៤ សាលាជាតិពន្ធដារបានរៀបចំសិក្ខាសាលាតាមអនឡាញស្តីពី "ការស្នើសុំវិញ្ញាបនបត្រពន្ធដារ មុខងារ៖ ស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ" ក្រោមអធិបតីភាពលោក **ស៊ុន ឧុទ្ធី** នាយកសាលាជាតិពន្ធដារ និងជាតំណាងរបស់ថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមផងដែរពីថ្នាក់ដឹកនាំ និងមន្ត្រីនៃសាលាជាតិពន្ធដារ ព្រមទាំងអ្នកជាប់ពន្ធ និងភ្នាក់ងារសេវាកម្មពន្ធដារ សរុបចំនួន **១៥៥ នាក់**៕



# ២.ការស្រាវជ្រាវ អភិវឌ្ឍន៍កម្មវិធី និងបណ្ណាល័យ

## ការធ្វើបច្ចុប្បន្នភាពឯកសារបណ្តុះបណ្តាល

ដើម្បីបន្តពង្រឹងគុណភាព និងពង្រីកសេវាបណ្តុះបណ្តាល អប់រំ និងផ្សព្វផ្សាយ ជូនមន្ត្រីពន្ធដារ និងសាធារណជនទូទៅ ព្រមទាំងគ្រប់គ្រងភ្នាក់ងារសេវាកម្មពន្ធដារដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សាលាជាតិពន្ធដារ បានរៀបចំនិងដាក់ឱ្យអនុវត្តនូវផែនការយុទ្ធសាស្ត្ររបស់សាលាជាតិពន្ធដារ ២០២៤-២០២៨ ក្នុងគោលបំណង ១.ចូលរួមលើកកម្ពស់វប្បធម៌បង់ពន្ធ និងអនុលោមភាពសារពើពន្ធដារតាមរយៈការពង្រឹងគុណភាព និងពង្រីកសេវាបណ្តុះបណ្តាល អប់រំ និងផ្សព្វផ្សាយ ជូនមន្ត្រីពន្ធដារ ភ្នាក់ងារសេវាកម្មពន្ធដារ អ្នកជាប់ពន្ធ និងសាធារណជនទូទៅ ព្រមទាំងគ្រប់គ្រងភ្នាក់ងារសេវាកម្មពន្ធដារប្រកបដោយប្រសិទ្ធភាព ឱ្យស្របតាមការវិវត្តនៃបច្ចេកវិទ្យាព័ត៌មាន និងឧត្តមានុវត្តជាតិ និងអន្តរជាតិ ២.សហការជាមួយអង្គភាពពាក់ព័ន្ធ ក្នុងការបន្តអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់សាលាជាតិពន្ធដារឱ្យស្របតាមការវិវត្តនៃលិខិតបទដ្ឋានគតិយុត្ត និងបរិវត្តកម្មឌីជីថល ៣. ចូលរួមលើកកម្ពស់ការផ្តល់សេវាផ្សព្វផ្សាយ និងបញ្ញាបវប្បធម៌បង់ពន្ធតាមរយៈការធ្វើទំនើបកម្មសម្ភារបរិក្ខារសិក្សា និងការគ្រប់គ្រងមន្ត្រី និងថវិការបស់សាលាជាតិពន្ធដារ ស្របតាមបរិវត្តកម្មសង្គមឌីជីថល។

គិតត្រឹមត្រីមាសទី១ ឆ្នាំ២០២៤ នេះ សាលាជាតិពន្ធដារបានធ្វើការកែសម្រួលឯកសារបណ្តុះបណ្តាលឱ្យស្របតាមច្បាប់សារពើពន្ធរួមមាន៖

**មុខវិជ្ជាតម្រូវទី១៖**

១. សេចក្តីផ្តើមនៃពន្ធ និងប្រព័ន្ធពន្ធដារកម្ពុជា

២. សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ និងភ្នាក់ងារសេវាកម្មពន្ធដារ

៣. ទោសទណ្ឌល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ

៤. ការចុះបញ្ជីពន្ធដារ

**មុខវិជ្ជាតម្រូវទី២៖**

១. ពន្ធលើចំណេញមូលធន

២. ពន្ធលើផ្ទាំងផ្សព្វផ្សាយ និងពន្ធលើមធ្យោបាយដឹកជញ្ជូន

៣. ពន្ធអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងពន្ធប្រថាប់ត្រា

**មុខវិជ្ជាជ្រើសរើសទី៣៖**

១. ការអនុវត្តប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាល-បច្ចេកវិទ្យាព័ត៌មាន

**មុខវិជ្ជាតម្រូវទី៤៖**

១. គណនេយ្យសាមញ្ញ

២. ពន្ធអន្តរជាតិ

**មុខវិជ្ជាតម្រូវទី៥៖**

១. ពន្ធលើប្រាក់ចំណូល (កម្រិតមូលដ្ឋាន)

**មុខវិជ្ជាឯកទេសទី១៖**

១. ពន្ធលើប្រាក់ចំណូល (កម្រិតខ្ពស់)

## ការងារអភិវឌ្ឍន៍កម្មវិធី

ក្នុងទិសដៅរក្សាបាននូវគុណភាព នៃការបណ្តុះបណ្តាលឱ្យមានចីរភាព សំដៅឱ្យមានការទទួលស្គាល់ពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារ សិស្ស និស្សិត អ្នកជាប់ពន្ធ និងសាធារណជនទូទៅ និងចូលរួមចំណែកបង្កើនអនុលោមភាពរបស់អ្នកជាប់ពន្ធតាមរយៈសេវាអប់រំ និងផ្សព្វផ្សាយ សាលាជាតិពន្ធដារ តែងតែធ្វើការយកចិត្តទុកដាក់ខ្ពស់លើការរៀបចំនិងកែលម្អកម្មវិធីបណ្តុះបណ្តាលរបស់ខ្លួនជានិច្ច។ ក្នុងត្រីមាសទី១ ឆ្នាំ២០២៤ សាលាជាតិពន្ធដារបានធ្វើការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលតាមរយៈការធ្វើសម្រង់មតិកែលម្អគុណភាពវគ្គបណ្តុះបណ្តាលរបស់សាលាជាតិពន្ធដារ បានចំនួន **៩ វគ្គ** ក្នុងនោះ ខែកុម្ភៈចំនួន **៥ វគ្គ** និងមីនាចំនួន **៤ វគ្គ**៕

## ការផ្តល់សេវាបណ្ណាល័យសាលាជាតិពន្ធដារ

នៅក្នុងត្រីមាសទី១ ឆ្នាំ២០២៤ សាលាជាតិពន្ធដារបានពង្រឹងសេវាបណ្ណាល័យតាមរយៈការផ្តល់សៀវភៅ និងឯកសារជូនដល់មន្ត្រីរាជការពន្ធដារ សិស្ស-និស្សិត និងសាធារណជន តាមរយៈការបញ្ចូលសៀវភៅ-ឯកសារថ្មីៗពាក់ព័ន្ធនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដែលបានស្រាវជ្រាវប្រមូលចងក្រង ដើម្បីរក្សាទុកក្នុងបណ្ណាល័យ ចំនួន **៤០ក្បាល** សរុប ១ ត្រីមាស ឆ្នាំ២០២៤ ចំនួន **៤០ក្បាល**៕






### ក. ការងារស្រាវជ្រាវប្រមូលឯកសារ និងរក្សាទុកឯកសារ

ក្នុងត្រីមាសទី១ ឆ្នាំ២០២៤ ការិយាល័យស្រាវជ្រាវ អភិវឌ្ឍន៍កម្មវិធី និងបណ្ណាល័យ បានស្រាវជ្រាវ និងប្រមូលឯកសារសម្រាប់រក្សាទុកក្នុងបណ្ណាល័យសរុប **១៥០ ឯកសារ** ក្នុងនោះរួមមាន៖

| បរិយាយ | ប្រភេទ | | ចំនួន |
|---|---|---|---|
| | Hard Copy | Soft Copy | |
| សរុបឯកសារថ្មីក្នុងត្រីមាសនេះ | ៧៨ | ៧២ | ១៥០ |
| សរុបឯកសារត្រឹមឆ្នាំ២០២៣ | ៥ ៤០៧ | ១ ៧៩០ | ៧ ១៩៧ |
| សរុបឯកសារត្រឹមត្រីមាសទី១ ឆ្នាំ២០២៤ | ៥ ៤៨៥ | ១ ៨៦២ | ៧ ៣៤៧ |

### ខ. ការងារគ្រប់គ្រងអ្នកមកទទួលសេវាពីបណ្ណាល័យ

ក្នុងត្រីមាសទី១ ឆ្នាំ២០២៤ ការិយាល័យស្រាវជ្រាវ អភិវឌ្ឍន៍កម្មវិធី និងបណ្ណាល័យ បានកត់ត្រានូវចំនួនអ្នកមកទទួលសេវាពីបណ្ណាល័យ (អាន ខ្ចី សង និងទទួលយកឯកសារ) **៧៦ នាក់** ក្នុងនោះ៖

| បរិយាយ | ប្រភេទ | | ចំនួន |
|---|---|---|---|
| | ប្រុស | ស្រី | |
| ចំនួនអ្នកចូលអានសៀវភៅ/ឯកសារ ក្នុងបណ្ណាល័យ | ១៩ | ២ | ២១ |
| ចំនួនអ្នកចូលខ្ចី/សង សៀវភៅ/ឯកសារ ពីបណ្ណាល័យ | ២៨ | ២៧ | ៥៥ |
| សរុប | ៤៧ | ២៩ | ៧៦ |

### គ. ការងារគ្រប់គ្រង ខ្ចី/សង សៀវភៅក្នុងបណ្ណាល័យ

ក្នុងត្រីមាសទី១ ឆ្នាំ២០២៤ ការិយាល័យស្រាវជ្រាវ អភិវឌ្ឍន៍កម្មវិធី និងបណ្ណាល័យ បានកត់ត្រានូវចំនួនសៀវភៅ ខ្ចី/សង ក្នុងបណ្ណាល័យដូចខាងក្រោម៖

| បរិយាយ | ខ្ចី | សង |
|---|---|---|
| ផ្តល់ជូនមន្ត្រីរាជការពន្ធដារ | ៥ | ៤ |
| ផ្តល់ជូនមន្ត្រីកិច្ចសន្យានៃអគ្គនាយកដ្ឋានពន្ធដារ | ១៩ | ១៩ |
| ផ្តល់ជូនសាធារណជនទូទៅ | ៨៤ | ៨៤ |
| សរុប | ១០៨ | ១០៧ |

# ៣.សិក្ខាសាលាសំខាន់ៗ

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ពន្ធលើប្រាក់ចំណូល និងការកំណត់ហានិភ័យអ្នកជាប់ពន្ធ"




*សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ពន្ធលើប្រាក់ចំណូល និងការកំណត់ហានិភ័យអ្នកជាប់ពន្ធ"*
*ក្រោមអធិបតីភាពឯកឧត្តម **រ័ត្ន មុនី** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*

ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤ ឯកឧត្តម **រ័ត្ន មុនី** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ បានដឹកនាំរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ពន្ធលើប្រាក់ចំណូល និងការកំណត់ហានិភ័យអ្នកជាប់ពន្ធ" សម្រាប់អ្នកជាប់ពន្ធ នៅតាមបណ្តាសាខាពន្ធដារខេត្ត-ខណ្ឌ នៅទូទាំងប្រទេស។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយ និងពង្រឹងការយល់ដឹងបន្ថែមដល់អ្នកជាប់ពន្ធពាក់ព័ន្ធនឹងកាតព្វកិច្ចពន្ធលើប្រាក់ចំណូល ដែលផ្តោតទៅលើ ១.កាតព្វកិច្ចពន្ធលើប្រាក់ចំណូលដែលបញ្ជាក់ពីប្រភពចំណូល អត្រាពន្ធ ប្រភេទចំណូល ប្រាក់ចំណូលជាប់ពន្ធ និងប្រាក់ចំណូលមិនជាប់ពន្ធ ការទទួលស្គាល់ចំណូល គោលការណ៍ស្តីពីចំណាយ រំលស់សារពើពន្ធ វិភាគទានសប្បុរសធម៌ ចំណាយការប្រាក់ ការយោងខាត និង ២.ការគណនាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ដោយផ្តោតទៅលើតារាងនិយ័តកម្មកែតម្រូវក្រៅបញ្ជិកាគណនេយ្យ តាមច្បាប់ស្តីពីសារពើពន្ធ។ សិក្ខាកាមដែលបានចូលរួមក្នុងសិក្ខាសាលានេះ មានឱកាសលើកជាមតិយោបល់ សំណួរ និងសំណូមពរពាក់ព័ន្ធនឹងការបំពេញកាតព្វកិច្ចសារពើពន្ធ និងទទួលបានការឆ្លើយតបពីវាគ្មិនជំនាញជាថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារផ្ទាល់។

កម្មវិធីសិក្ខាសាលាស្តីពី ពន្ធលើប្រាក់ចំណូល និងការកំណត់ហានិភ័យអ្នកជាប់ពន្ធ ត្រូវបានរៀបចំឡើងនៅគ្រប់សាខាពន្ធដារខេត្ត-ខណ្ឌទូទាំងប្រទេស ដោយបានចែកចេញជា ៧ ទិសដៅ និងមានសិក្ខាកាមចូលរួមសរុប **២ ៥៦៤ នាក់** ដូចខាងក្រោម៖

- ទិសដៅទី១៖ លោក **ចាន់ ពិសិដ្ឋ** អនុប្រធាននាយកដ្ឋានសវនកម្មសហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ

ដឹកនាំក្រុមការងារសម្រាប់ទិសដៅ សាខាពន្ធដារខេត្តកណ្ដាល តាកែវ កំពត និងខេត្តកែប ព្រមទាំងមានសិក្ខាកាមចូលរួមចំនួន **៣៧៥ នាក់**

- ទិសដៅទី២៖ លោក **ខៀន សន្ធា** អនុប្រធាននាយកដ្ឋានសវនកម្មសហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ ដឹកនាំក្រុមការងារសម្រាប់ទិសដៅ សាខាពន្ធដារខេត្តកំពង់ស្ពឺ ព្រះសីហនុ និងខេត្តកោះកុង ព្រមទាំងមានសិក្ខាកាមចូលរួមចំនួន **២២៧ នាក់**
- ទិសដៅទី៣៖ លោក **សៀង ស៊ីថា** អនុប្រធាននាយកដ្ឋានសវនកម្មសហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ ដឹកនាំក្រុមការងារសម្រាប់ទិសដៅ សាខាពន្ធដារខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ សៀមរាប ព្រះវិហារ និងខេត្តកំពង់ធំ ព្រមទាំងមានសិក្ខាកាមចូលរួមចំនួន **៤៧៨ នាក់**
- ទិសដៅទី៤៖ លោក **ឆ ឆាយសេរីបុត្រ** អនុប្រធាននាយកដ្ឋានសវនកម្មសហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ ដឹកនាំក្រុមការងារសម្រាប់ទិសដៅ សាខាពន្ធដារខេត្តប៉ៃលិន បាត់ដំបង ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង ព្រមទាំងមានសិក្ខាកាមចូលរួមចំនួន **៣៤៩ នាក់**
- ទិសដៅទី៥៖ លោក **ម៉ែន រ៉ាសេត** អនុប្រធាននាយកដ្ឋានសវនកម្មសហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ ដឹកនាំក្រុមការងារសម្រាប់ទិសដៅ សាខាពន្ធដារខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង និងខេត្តក្រចេះ ព្រមទាំងមានសិក្ខាកាមចូលរួមចំនួន **៣៩៥ នាក់**
- ទិសដៅទី៦៖ លោក **ជួរ សែ** អនុប្រធាននាយកដ្ឋានសវនកម្មសហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ ដឹកនាំក្រុមការងារសម្រាប់ទិសដៅ សាខាពន្ធដារខេត្តត្បូងឃ្មុំ កំពង់ចាម ព្រៃវែង និងខេត្តស្វាយរៀង ព្រមទាំងមានសិក្ខាកាមចូលរួមចំនួន **៣៦២ នាក់**
- ទិសដៅទី៧៖ លោក **ត្រាំង ឡៃ** អនុប្រធាននាយកដ្ឋានសវនកម្មសហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ ដឹកនាំក្រុមការងារសម្រាប់ទិសដៅ សាខាពន្ធដារខណ្ឌទាំងអស់នៃរាជធានីភ្នំពេញ ព្រមទាំងមានសិក្ខាកាមចូលរួមចំនួន **៣៧៨ នាក់**៕



# សិក្ខាសាលាស្តីពី "ពន្ធលើប្រាក់ចំណូល និងប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing)"




*សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ពន្ធលើប្រាក់ចំណូល និងប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing)" ក្រោមអធិបតីភាពឯកឧត្តម **ហេង សុខណាង** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*

នាព្រឹកថ្ងៃអង្គារ ទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំសិក្ខាសាលាស្តីពី "ពន្ធលើប្រាក់ចំណូល និងប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing)" សម្រាប់សហគ្រាស អ្នកជាប់ពន្ធមធ្យម ក្រោមអធិបតីភាពឯកឧត្តម **ហេង សុខណាង** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារពាក់ព័ន្ធ ព្រមទាំងអភិបាល បណ្ណាធិការ និងតំណាងសហគ្រាស សរុបចំនួន **២០០ នាក់**។

ក្នុងកម្មវិធីសិក្ខាសាលាពន្ធលើប្រាក់ចំណូល និងប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing) មានប្រធានបទសំខាន់ៗចំនួន ៣ គឺ៖

- បទបង្ហាញស្តីពី "ការបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូល" ដោយលោក **ម៉ា ម៉ូរ៉ា** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម
- បទបង្ហាញស្តីពី "ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ" ដោយលោក **ឌួ សុចិត្រ** អនុប្រធានការិយាល័យនៃនាយកដ្ឋានសវនកម្មសហគ្រាស
- បទបង្ហាញស្តីពី "ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing)" ដោយលោក **សុធី គីរី** អនុប្រធានការិយាល័យនៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន។

សិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណងរួមចំណែកលើកកម្ពស់ការអនុវត្តកាតព្វកិច្ចសារពើពន្ធរបស់ម្ចាស់សហគ្រាសទាំងអស់ ដែលបាននិងកំពុងប្រកបអាជីវកម្ម ដោយទទួលបាននូវចំណេះដឹងថ្មីបន្ថែមទៀត ស្តីពីពន្ធលើប្រាក់ចំណូល និងប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing)។ ជាមួយគ្នានេះ សិក្ខាកាមដែលបានចូលរួមបានលើកជាមតិយោបល់ សំណួរពាក់ព័ន្ធ ដើម្បីផ្តល់ជាគុចូលបន្ថែម និងស្រូបយកនូវចំណេះដឹង ចំណេះធ្វើ និងបទពិសោធន៍ ដើម្បីប្រើប្រាស់ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធឱ្យបានត្រឹមត្រូវស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន៕

# សិក្ខាសាលាស្ដីពី"ពន្ធលើប្រាក់ចំណូល និងប្រព័ន្ធគ្រប់គ្រង ការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing)"



*សិក្ខាសាលាស្ដីពី "ពន្ធលើប្រាក់ចំណូល និងប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing)" សម្រាប់សហគ្រាសអ្នកជាប់ពន្ធមធ្យម ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **កែន សម្បត្តិ** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី១៤ ខែមីនា ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំសិក្ខាសាលាស្ដីពី "ពន្ធលើប្រាក់ចំណូល និងប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing)" សម្រាប់សហគ្រាសអ្នកជាប់ពន្ធមធ្យម ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **កែន សម្បត្តិ** អគ្គនាយករងនៃអគ្គ-នាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារពាក់ព័ន្ធ តំណាងមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រាជធានីភ្នំពេញ ព្រមទាំង អភិបាល បណ្ណាធិការ និងតំណាងសហគ្រាស សរុបចំនួន **២២៥ នាក់**។

ក្នុងកម្មវិធីសិក្ខាសាលាពន្ធលើប្រាក់ចំណូល និងប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing) មានប្រធានបទសំខាន់ៗចំនួន ៣ គឺ៖ ១.បទបង្ហាញស្ដីពី "ការបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូល" ២.បទបង្ហាញស្ដីពី "ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ" និង ៣.បទបង្ហាញស្ដីពី "ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing)"។

សិក្ខាសាលានេះរៀបចំឡើងស្របតាមមាត្រា ១៩៣ នៃច្បាប់ស្ដីពីសារពើពន្ធ ដែលបានចែងអំពីសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ ដែលអគ្គនាយកដ្ឋានពន្ធដារតែងតែធ្វើជាប្រចាំ ដោយការផ្ដល់សេវាអ្នកជាប់ពន្ធ ទាំងនៅថ្នាក់អគ្គនាយកដ្ឋានពន្ធដារ និងទាំងនៅថ្នាក់សាខាពន្ធដារខេត្ត-ខណ្ឌ ដើម្បីបង្កើនការយល់ដឹងរបស់អ្នកជាប់ពន្ធឱ្យបានកាន់តែស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ អំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារ សំដៅលើកកម្ពស់វប្បធម៌នៃការបង់ពន្ធ និងអនុលោមភាពសារពើពន្ធនៅកម្ពុជា។ ជាមួយគ្នានេះ សិក្ខាសាលាមានគោលបំណងពង្រឹងបន្ថែមនូវការយល់ដឹងអំពីការប្រកាសពន្ធលើប្រាក់ចំណូល និងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing) ដែលជាអំឡុងពេលត្រូវដាក់លិខិតប្រកាសពន្ធនិងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០២៣ ដែលត្រូវបិទបញ្ចប់នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤។

# វគ្គបណ្តុះបណ្តាលស្តីពី ការពង្រឹងសមត្ថភាពលើនីតិវិធីសវនកម្ម និង ក្រមសីលធម៌ វិន័យ វិជ្ជាជីវៈរបស់សវនករពន្ធដារនៅតាមបណ្តាសាខាពន្ធដារខណ្ឌ




*វគ្គបណ្តុះបណ្តាលស្តីពី "ការពង្រឹងសមត្ថភាពលើនីតិវិធីសវនកម្ម និងក្រមសីលធម៌ វិន័យ វិជ្ជាជីវៈរបស់សវនករពន្ធដារនៅតាមបណ្តាសាខាពន្ធដារខណ្ឌ" ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **កែន សម្បត្តិ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ*

នាព្រឹកថ្ងៃចន្ទ ទី១៨ ខែមីនា ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ការពង្រឹងសមត្ថភាពលើនីតិវិធីសវនកម្ម និងក្រមសីលធម៌ វិន័យ វិជ្ជាជីវៈរបស់សវនករពន្ធដារនៅតាមបណ្តាសាខាពន្ធដារខណ្ឌ" ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **កែន សម្បត្តិ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារពាក់ព័ន្ធ សរុបចំនួន **២៤៥ នាក់**។

ក្នុងកម្មវិធីសិក្ខាសាលាពន្ធលើប្រាក់ចំណូល និងប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing) មានប្រធានបទសំខាន់ៗចំនួន ៣ គឺ៖ ១.បទបង្ហាញស្តីពី "ការប្រមូលផ្តុំព័ត៌មាន និងវិភាគហានិភ័យរបស់សហគ្រាស មុនពេលចុះធ្វើសវនកម្ម (Pre Audit)" និង "ការប្រមូលផ្តុំព័ត៌មានអំឡុងពេលចុះធ្វើសវនកម្ម" ២.បទបង្ហាញស្តីពី "ការរៀបចំរបាយការណ៍លទ្ធផលសវនកម្ម" និង ៣.បទបង្ហាញស្តីពី "ក្រមសីលធម៌មន្ត្រីរាជការពន្ធដារ" និង "វិន័យការងារមន្ត្រីរាជការពន្ធដារ" ។

ឯកឧត្តមបណ្ឌិតអគ្គនាយករង បានលើកឡើងថា វគ្គបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយ និងចែករំលែកនូវចំណេះដឹង ចំណេះធ្វើ និងបទពិសោធន៍នៃការអនុវត្តការងារពាក់ព័ន្ធនឹងសវនកម្មពន្ធដារ ព្រមទាំងប្រមូលធាតុចូល និងបញ្ហាប្រឈមនានា ដើម្បីពង្រឹងសមត្ថភាពសវនករពន្ធដារ ស្របតាមវិធានការកែទម្រង់មុតស្រួចជាកញ្ចប់របស់រាជរដ្ឋាភិបាលកម្ពុជា និងអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ក្នុងគោលដៅដោះស្រាយបញ្ហាប្រឈម និងកង្វល់ពាក់ព័ន្ធនឹងការវិនិយោគរបស់វិស័យឯកជន ក៏ដូចជាការគិតគូរសម្រួលបន្ថែមសម្រាប់វិស័យមួយចំនួនទៀត ក្នុងការកាត់បន្ថយបន្ទុកលើការធ្វើធុរកិច្ច សំដៅលើកកម្ពស់ភាពប្រកួតប្រជែង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា៕

# សិក្ខាសាលា ស្តីពី "ការចុះបញ្ជីសកម្មភាពអាជីវកម្ម ដោយឡែករបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល"




*សិក្ខាសាលាស្តីពី "ការចុះបញ្ជីសកម្មភាពអាជីវកម្មដោយឡែករបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល"*
*ក្រោមអធិបតីភាពឯកឧត្តម **ម៉ិញ បានកុសល** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២១ ខែមីនា ឆ្នាំ២០២៤ នៅសណ្ឋាគារ រ៉ាហ្វ៊ល ឡឺរ៉ូយ៉ាល់ អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) បានស្នើសុំកិច្ចសហប្រតិបត្តិការពីអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងនិយ័តករគណនេយ្យ និងសវនកម្ម រៀបចំសិក្ខាសាលាបំប៉នបន្ថែមដល់បុគ្គលិកផ្នែកហិរញ្ញវត្ថុ និងថ្នាក់ដឹកនាំរបស់បណ្តាសមាគម និងអង្គការមិនមែនរដ្ឋាភិបាលទាំងសមាជិក និងមិនមែនសមាជិកនៃអង្គការ គ.ស.ក លើប្រធានបទ "សិក្ខាសាលាស្តីពីការចុះបញ្ជីសកម្មភាពអាជីវកម្មដោយឡែករបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល" ដើម្បីរួមចំណែកធ្វើឱ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលអាចត្រៀមខ្លួនបានល្អប្រសើរក្នុងការពង្រឹងអនុលោមភាពស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ក្រោមអធិបតីភាពឯកឧត្តម **ម៉ិញ បានកុសល** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងលោកស្រី **ស៊ិន ពុទ្ធារី** នាយិកាប្រតិបត្តិអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ដោយមានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីជំនាញពីនាយកដ្ឋានពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងនិយ័តករគណនេយ្យ និងសវនកម្ម ព្រមទាំងតំណាងអង្គការ ជាតិនិងអន្តរជាតិ សមាគមនានាក្នុងប្រទេសកម្ពុជាចំនួន **១៤២ នាក់**។

សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងបញ្រ្ជាបបន្ថែមនូវការយល់ដឹងអំពីការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ សំដៅពង្រឹងអនុលោមភាពសារពើពន្ធ និងលើកកម្ពស់វប្បធម៌បង់ពន្ធ។ នៅក្នុងសិក្ខាសាលាមានការធ្វើបទបង្ហាញស្តីពី "ការចុះបញ្ជីសកម្មភាពអាជីវកម្មដោយឡែករបស់សមាគម និងអង្គការមិនមែន រដ្ឋាភិបាល" ដោយលោក **ប៉ូ ពិសិដ្ឋ** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម ដែលផ្តោតលើចំណុចសំខាន់ ចំនួនបួន រួមមាន៖ ១.ការលើកលែងពន្ធលើប្រាក់ចំណូលសម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ២.សកម្មភាពអាជីវកម្មដោយឡែក ៣.ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និង៤.ការលើកទឹកចិត្តក្នុងការចុះបញ្ជី។

ឯកឧត្តមអគ្គនាយករង បានសម្តែងនូវការវាយតម្លៃខ្ពស់ចំពោះសិក្ខាកាមទាំងអស់ ដែលមានវត្តមានចូលរួមនៅក្នុងសិក្ខាសាលានេះ ឆ្លុះបញ្ចាំងឱ្យឃើញអំពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការពង្រឹង និងបង្កើនការយល់ដឹងបន្ថែមអំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ជាពិសេសឈ្វេងយល់ឱ្យបានកាន់តែស៊ីជម្រៅថែមទៀត ចំពោះកាតព្វកិច្ចសារពើពន្ធសម្រាប់សកម្មភាពអាជីវកម្មដោយឡែកបន្ថែមលើសកម្មភាពគោលដៅសុទ្ធសាធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបំពេញកាតព្វកិច្ចសារពើពន្ធក្នុងឋានៈជាអ្នកជាប់ពន្ធ និង/ឬក្នុងឋានៈជាភ្នាក់ងារកាត់ទុក ឱ្យបានត្រឹមត្រូវស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន។ បន្ថែមពីនេះ ឯកឧត្តមអគ្គនាយករងបានគូសបញ្ជាក់អំពីការខិតខំប្រឹងប្រែងរបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងការលើកកម្ពស់ និងបញ្ជ្រាបវប្បធម៌បង់ពន្ធឱ្យបានជ្រួតជ្រាបដល់គ្រប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាអ្នកជាប់ពន្ធទាំងអស់ ឱ្យយល់ដឹងកាន់តែច្បាស់អំពីកាតព្វកិច្ចសារពើពន្ធ និងការវិវត្តឥតឈប់ឈរនៃការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ ដើម្បីប្រែក្លាយស្ថាប័នរដ្ឋមួយនេះ ឱ្យមានលក្ខណៈទំនើប ដែលអាចឆ្លើយតបទៅនឹងការវិវត្តនៃសង្គម និងសេដ្ឋកិច្ចជាតិក្នុងដំណាក់កាលប្រែប្រួលថ្មី ក៏ដូចជាបរិបទនៃសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់និងពិភពលោក។ ឯកឧត្តមអគ្គនាយករងបានជំរុញនិងលើកទឹកចិត្តសិក្ខាកាមទាំងអស់ ចូលរួមឱ្យបានសកម្មនៅក្នុងសិក្ខាសាលានេះ តាមរយៈការលើកជាមតិយោបល់សំណួរពាក់ព័ន្ធដើម្បីផ្តល់និងស្រូបយកជាតុចូលពាក់ព័ន្ធនៅក្នុងសិក្ខាសាលានេះព្រមទាំងចែករំលែកជាចំណេះដឹង ចំណេះធ្វើ បទពិសោធន៍ ការអនុវត្ត និងបទប្បញ្ញត្តិ ដើម្បីជាប្រយោជន៍ ជាចំណេះដឹងសម្រាប់បំពេញកាតព្វកិច្ចសារពើពន្ធឱ្យបានត្រឹមត្រូវតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន សំដៅពង្រឹងវប្បធម៌នៃការបង់ពន្ធ និងអនុលោមភាពសារពើពន្ធ។ ឯកឧត្តមអគ្គនាយករង បានបញ្ជាក់ថា ករណីបន្ទាប់ពីស្តាប់ការធ្វើបទបង្ហាញ និងវេទិកាសំណួរ-ចម្លើយបានបញ្ចប់ ប្រសិនបើសិក្ខាកាមនៅមានចម្ងល់នានា អាចធ្វើការទំនាក់ទំនងសួរនាំព័ត៌មានបន្ថែមតាមរយៈកម្មវិធី GDT Live Chat ឬតាមរយៈមជ្ឈមណ្ឌលពិគ្រោះយោបល់តាមទូរស័ព្ទ (GDT-Call Center-1277) ដោយឥតគិតថ្លៃ ឬជួបដោយផ្ទាល់ជាមួយនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម ឬជាមួយមន្ត្រីជំនាញទទួលបន្ទុកសាខាពន្ធដារនីមួយៗ ឬអាចទាញយកនូវច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ព្រមទាំងព័ត៌មានពន្ធដារផ្សេងៗ ដែលមាននៅក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ មានអាសយដ្ឋាន www.tax.gov.kh ឬបណ្តាញទំនាក់ទំនងសង្គម Facebook, YouTube, Instagram និង Telegram របស់អគ្គនាយកដ្ឋានពន្ធដារ៕



*សិក្ខាសាលាស្តីពី "ការចុះបញ្ជីសកម្មភាពអាជីវកម្មដោយឡែករបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល"*
*ក្រោមអធិបតីភាពឯកឧត្តម **ម៉ិញ បានកុសល** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*

## កម្មវិធីទូរស័ព្ទដៃពេញនិយមទាំង ១០ របស់អគ្គនាយកដ្ឋានពន្ធដារ

**កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App)**
សម្រាប់បង់ពន្ធលើអចលនទ្រព្យ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងពន្ធលើផ្ទាំងផ្សព្វផ្សាយ

**កម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App)**
សម្រាប់ប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ របស់សហគ្រាសដែលជាអ្នកជាប់ពន្ធតូច

**កម្មវិធីត្រួតពិនិត្យ និងតាមដានឯកសារ (GDT Check & Track App)**
សម្រាប់តាមដានឯកសារដែលបានដាក់ស្នើមករដ្ឋបាលសារពើពន្ធ ពិនិត្យភាពត្រឹមត្រូវនៃឯកសារដែលមាន QR Code ចេញដោយអគ្គនាយកដ្ឋានពន្ធដារ

**កម្មវិធីគណនាពន្ធលើប្រាក់បៀវត្ស (GDT Salary Tax Calculation App)**
សម្រាប់គណនាពន្ធលើប្រាក់បៀវត្សប្រចាំខែដែលត្រូវបង់

**កម្មវិធីគណនាពន្ធលើមធ្យោបាយដឹកជញ្ជូន (GDT Means of Transportation Tax Calculation App)**
សម្រាប់គណនាប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន ដែលត្រូវបង់ប្រាក់ពន្ធប្រចាំឆ្នាំ

**ព័ត៌មានពន្ធដារ (GDT News App)**
សម្រាប់ទទួលបានព័ត៌មាន វគ្គបណ្តុះបណ្តាល សិក្ខាសាលា ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត វីដេអូផ្សេងៗទៀតស្តីពីពន្ធដារ...

**កម្មវិធីជជែកផ្ទាល់ជាមួយពន្ធដារ (GDT Live Chat App)**
សម្រាប់សាកសួរព័ត៌មានផ្សេងៗស្តីពីពន្ធដារ (ផ្នែកពន្ធទូទៅ និង e-Tax Service)

**ប្រតិទិនពន្ធដារ (GDT Calendar App)**
អាចពិនិត្យកាលបរិច្ឆេទដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធប្រចាំខែ និងឆ្នាំ

**កម្មវិធីសទ្ទានុក្រមពន្ធដារ (Tax Glossary App)**
សម្រាប់ស្វែងរកពាក្យគន្លឹះផ្សេងៗស្តីពីពន្ធដារ

**កម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)**
សម្រាប់បញ្ចូលវិក្កយបត្រ ដើម្បីចូលរួមផ្សងសំណាងឈ្នះរង្វាន់ជាច្រើនពីអគ្គនាយកដ្ឋានពន្ធដារ

## តើលោក-លោកស្រី បានឈ្វេងយល់អំពីព្រឹត្តិបត្រនេះបានកម្រិតណាដែរ? លោក-លោកស្រី អាចសាកល្បងឆ្លើយនូវសំណួរខាងក្រោម៖

១. គិតមកដល់ត្រឹមថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ តើមានអ្នកជាប់ពន្ធប៉ុន្មាន % នៃអ្នកជាប់ពន្ធដែលបានចុះបញ្ជីទាំងអស់ដែលកំពុងប្រើប្រាស់ប្រព័ន្ធ-កម្មវិធីអេឡិចត្រូនិករបស់អគ្គនាយកដ្ឋានពន្ធដារក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ?

- ○ **ក.** ៩៥%
- ○ **គ.** ៨០%
- ○ **ខ.** ៩០%
- ○ **ឃ.** ៨៥%

២. តើអគ្គនាយកដ្ឋានពន្ធដារប្រមូលចំណូលពន្ធអាករគ្រប់ប្រភេទ បានប៉ុន្មានប៊ីលានរៀលក្នុងរយៈពេល ៣ខែដើមឆ្នាំ២០២៤?

- ○ **ក.** ១ ៨១៤,៦៥ ប៊ីលានរៀល
- ○ **គ.** ៨ ៤១៤,៦៥ ប៊ីលានរៀល
- ○ **ខ.** ១៤ ២៩,៦៥ ប៊ីលានរៀល
- ○ **ឃ.** ៤ ៨១៤,៦៥ ប៊ីលានរៀល

៣. តើអគ្គនាយកដ្ឋានពន្ធដារប្រមូលចំណូលបានប៉ុន្មានភាគរយ ក្នុងរយៈពេល ៣ខែដើមឆ្នាំ២០២៤ បើធៀបនឹងផែនការច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ?

- ○ **ក.** ២៥,២៨%
- ○ **គ.** ២៨,៥៥%
- ○ **ខ.** ១៨,៣៧%
- ○ **ឃ.** ៨២,៥៥%

៤. តើអ្នកជាប់ពន្ធតូច អាចប្រកាសពន្ធតាមរយៈ App ឈ្មោះអ្វី?

- ○ **ក.** GDT Taxpayer App
- ○ **គ.** GDT Tax Prefiling App
- ○ **ខ.** GDT Check & Track App
- ○ **ឃ.** GDT Live Chat

៥. តើក្នុងរយៈពេល ៣ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារប្រមូលបំណុលពន្ធបានប៉ុន្មានប៊ីលានរៀល?

- ○ **ក.** ២២៨,៤៦ ប៊ីលានរៀល
- ○ **គ.** ៥៥,១៧ ប៊ីលានរៀល
- ○ **ខ.** ១៧៣,២៩ ប៊ីលានរៀល
- ○ **ឃ.** ៣១៧,២៩ ប៊ីលានរៀល

៦. តើ Call Center មានលេខប៉ុន្មាន?

- ○ **ក.** ១២៧៧
- ○ **គ.** ១២២២
- ○ **ខ.** ១២៧២
- ○ **ឃ.** ១២៥២

៧. តើក្នុងរយៈពេល ៣ខែដើមឆ្នាំ២០២៤ ចំណូលពន្ធអាករពីអ្នកជាប់ពន្ធមធ្យមមានចំនួនប៉ុន្មានភាគរយនៃគ្រប់ប្រភេទអ្នកជាប់ពន្ធ?

- ○ **ក.** ១៥,៣៦%
- ○ **គ.** ៧៩,៨៨%
- ○ **ខ.** ៤,១២%
- ○ **ឃ.** ៥១,៣៦%

៨. តើអគ្គនាយកដ្ឋានពន្ធដារបានដោះស្រាយសំណុំឯកសារបណ្ដឹងតវ៉ា បានចំនួនប៉ុន្មានករណី ក្នុងរយៈពេល ៣ខែដើមឆ្នាំ២០២៤?

- ○ **ក.** ៣ ៨០៧ ករណី
- ○ **គ.** ៣ ០៧៨ ករណី
- ○ **ខ.** ៣ ០៨៧ ករណី
- ○ **ឃ.** ៣ ៧០៨ ករណី

៩. តើក្នុងរយៈពេល ៣ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានដោះស្រាយសំណុំឯកសារបណ្តឹងតវ៉ា បានចំនួនប៉ុន្មានករណី?

- ក. ១២៧ ករណី
- គ. ២៤៤ ករណី
- ខ. ២១៧ ករណី
- ឃ. ២៧១ ករណី

១០. តើក្នុងត្រីមាសទី១ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំកម្មវិធីពន្ធដារសរុបចំនួនប៉ុន្មានលើក?

- ក. ៧ លើក
- គ. ៩ លើក
- ខ. ៦ លើក
- ឃ. ៤ លើក

១១. តើកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App) ប្រើក្នុងគោលបំណងបញ្ចូលវិក្កយបត្រថ្មីដើម្បីឈ្នះរង្វាន់ជាច្រើនពីអគ្គនាយកដ្ឋានពន្ធដារ ត្រូវឬខុស?

- ក. ខុស
- ខ. ត្រូវ

១២. GDT Taxpayer App អនុញ្ញាតឱ្យអ្នកជាប់ពន្ធបង់ប្រាក់ពន្ធនៃប្រភេទដូចខាងក្រោមលើកលែងតែ

- ក. ពន្ធអចលនទ្រព្យ
- គ. ពន្ធលើមធ្យោបាយដឹកជញ្ជូន
- ខ. ពន្ធលើផ្ទាំងផ្សព្វផ្សាយ
- ឃ. ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ

១៣. តើចំណូលតាមប្រភេទពន្ធមួយណាដែលដើរតួនាទីស្នូលនៃចំណូលពន្ធដារ?

- ក. ពន្ធលើប្រាក់បៀវត្ស
- គ. ពន្ធលើប្រាក់ចំណូល
- ខ. អាករលើតម្លៃបន្ថែម
- ឃ. ពន្ធប្រថាប់ត្រា

១៤. តើក្នុងត្រីមាសទី១ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយនិងវគ្គបណ្តុះបណ្តាលចំនួនសរុបប៉ុន្មានលើក?

- ក. ២៤០ លើក
- គ. ៤៤០ លើក
- ខ. ២២០ លើក
- ឃ. ៤២០ លើក

១៥. តើចំណូលតាមប្រភេទអ្នកជាប់ពន្ធមួយណាដែលដើរតួនាទីស្នូលនៃចំណូលពន្ធដារ?

- ក. អ្នកជាប់ពន្ធតូច
- គ. អ្នកជាប់ពន្ធធំ
- ខ. អ្នកជាប់ពន្ធមធ្យម
- ឃ. អ្នកជាប់ពន្ធផ្សេងៗទៀត

---

ចម្លើយ

| សំណួរ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ចម្លើយ | ខ | ឃ | គ | គ | ខ | ក | ក | ឃ | ក | ខ | ខ | ឃ | គ | ក | គ |



# អគ្គនាយកដ្ឋានពន្ធដារ
# សូមស្វាគមន៍

**សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច លេខតំណាងភ្ជាប់របស់អង្គភាព**
**(ដោយមិនចាំបាច់ជ្រើសរើសភាសា)**
**ដើម្បីទាក់ទងទៅកាន់នាយកដ្ឋាន ឬសាខាពន្ធដារខេត្ត-ខណ្ឌ**
**ដោយឥតគិតថ្លៃ**

អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
សារអេឡិចត្រូនិក: gdt@tax.gov.kh លេខទូរស័ព្ទ: (855) 23 266 668

## អាសយដ្ឋាននាយកដ្ឋាន សាលាជាតិពន្ធដារ ទីចាត់ការពន្ធដាររាជធានីភ្នំពេញ និងសាខាពន្ធដារខេត្ត-ខណ្ឌ

## នាយកដ្ឋានថ្នាក់កណ្ដាល សាលាជាតិពន្ធដារ និងទីចាត់ការពន្ធដាររាជធានីភ្នំពេញ

### នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ១០៩៩
សារអេឡិចត្រូនិក: admin.info@tax.gov.kh

### នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ១៨០០
សារអេឡិចត្រូនិក: dfp@tax.gov.kh

### នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ២១០០
សារអេឡិចត្រូនិក: dlpic@tax.gov.kh

### នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ២៧០១
សារអេឡិចត្រូនិក: dpt@tax.gov.kh

### នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៨០១៤
សារអេឡិចត្រូនិក: dit@tax.gov.kh

### នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៣២០១
សារអេឡិចត្រូនិក: dtci@tax.gov.kh

### នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៣៦០១
សារអេឡិចត្រូនិក: dlt@tax.gov.kh

### នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម
អគារជាន់ទី១៩ ផ្លូវ១០២ មជ្ឈមណ្ឌលភ្នំពេញ ភូមិ១
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៤៩០០
សារអេឡិចត្រូនិក: dsmt@tax.gov.kh

### នាយកដ្ឋានសវនកម្មសហគ្រាស
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៥៦០០
សារអេឡិចត្រូនិក: dea@tax.gov.kh

### សាលាជាតិពន្ធដារ
អគារលេខ៤១-៤៣ ផ្លូវ១១២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក
រាជធានីភ្នំពេញ (ខាងកើតអគ្គនាយកដ្ឋានពន្ធដារ)
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៦៤០១
សារអេឡិចត្រូនិក: nts@tax.gov.kh

### ទីចាត់ការពន្ធដាររាជធានីភ្នំពេញ
អគារជាន់ទី១៨ ផ្លូវ១០២ មជ្ឈមណ្ឌលភ្នំពេញ ភូមិ១
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៦៨០១
សារអេឡិចត្រូនិក: ppmd@tax.gov.kh

## សាខាពន្ធដារខណ្ឌ

### សាខាពន្ធដារ ខណ្ឌឫស្សីកែវ
អគារ១០២ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦
ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩០០៧
សារអេឡិចត្រូនិក: russeykeo@tax.gov.kh

### សាខាពន្ធដារ ខណ្ឌដូនពេញ
ផ្ទះលេខ១៦៦ ផ្លូវលេខ១៣០ សង្កាត់ផ្សារកណ្ដាលទី២
ខណ្ឌដូនពេញ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩០៣២
សារអេឡិចត្រូនិក: daunpenh@tax.gov.kh

### សាខាពន្ធដារ ខណ្ឌ៧មករា
ដីឡូលេខ០៥ ផ្លូវលេខ១៥០ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩០៥៧
សារអេឡិចត្រូនិក: 7makara@tax.gov.kh

### សាខាពន្ធដារ ខណ្ឌមានជ័យ
អគារលេខ៣៤C ផ្លូវ៣៦១ កែងផ្លូវ៦៤២ សង្កាត់ច្បារអំពៅ១
ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩០៨៣
សារអេឡិចត្រូនិក: meanchey@tax.gov.kh

### សាខាពន្ធដារ ខណ្ឌចំការមន
អគារលេខ២៨ ផ្លូវលេខ៤៨៨ សង្កាត់ផ្សារដើមថ្កូវ
ខណ្ឌចំការមន រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩១០៩
សារអេឡិចត្រូនិក: chamkarmorn@tax.gov.kh

### សាខាពន្ធដារ ខណ្ឌទួលគោក
ផ្ទះលេខ២៤ ផ្លូវ២៨៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក
រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩១៣៥
សារអេឡិចត្រូនិក: tuolkork@tax.gov.kh

### សាខាពន្ធដារ ខណ្ឌដង្កោ

ផ្លូវ២១៧ ភូមិរលួស សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩១៦១
សារអេឡិចត្រូនិក: dangkor@tax.gov.kh

### សាខាពន្ធដារ ខណ្ឌសែនសុខ

អគារលេខ៩ ផ្លូវលេខ១០១៩(ហាណូយ) សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩១៨៨
សារអេឡិចត្រូនិក: sensok@tax.gov.kh

### សាខាពន្ធដារ ខណ្ឌពោធិ៍សែនជ័យ

ផ្ទះលេខ២៣៤B ផ្លូវលេខ ២០០៧ សង្កាត់កាកាប១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩២១៣
សារអេឡិចត្រូនិក: porsenchey@tax.gov.kh

## សាខាពន្ធដារខេត្ត

### សាខាពន្ធដារ ខេត្តបន្ទាយមានជ័យ

ភូមិក្បាលស្ពាន សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ(ខាងត្បូងស្ពានសៃសិនចំងាយ ៣០០ម៉ែត្រ តាមបណ្តោយផ្លូវជាតិលេខ៥ ឆ្ពោះទៅកាន់ស្រុកមង្គលបូរី)
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៧០៨
សារអេឡិចត្រូនិក: banteaymeanchey@tax.gov.kh

### សាខាពន្ធដារ ខេត្តបាត់ដំបង

ផ្ទះលេខ២ ផ្លូវជាតិលេខ៥ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩២៩២
សារអេឡិចត្រូនិក: battambang@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពង់ចាម

ផ្ទះលេខ៥ ភូមិទី១៥ ផ្លូវខេមរភូមិន្ទ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩២៦៥
សារអេឡិចត្រូនិក: kampongcham@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពង់ឆ្នាំង

ភូមិឃ្លាំងប្រាក់ សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៤៧៣
សារអេឡិចត្រូនិក: kampongchhnang@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពង់ធំ

ភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៣៦៩
សារអេឡិចត្រូនិក: kampongthom@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពង់ស្ពឺ

ផ្លូវជាតិលេខ៤ ភូមិត្រពាំងលើក សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៤៩៩
សារអេឡិចត្រូនិក: kampongspeu@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពត

ផ្លូវលេខ៧២៩ ភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៥២៦
សារអេឡិចត្រូនិក: kampot@tax.gov.kh

### សាខាពន្ធដារ ខេត្តកណ្តាល

អគារលេខ២៦ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩២៣៩
សារអេឡិចត្រូនិក: kandal@tax.gov.kh

### សាខាពន្ធដារ ខេត្តកោះកុង

អគារកែងផ្លូវលេខ៩០០ និងផ្លូវលេខ៩៩៥ ភូមិ២ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៥៧៧
សារអេឡិចត្រូនិក: kohkong@tax.gov.kh

### សាខាពន្ធដារ ខេត្តក្រចេះ

ភូមិក្រចេះ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៦៣០
សារអេឡិចត្រូនិក: kratie@tax.gov.kh

### សាខាពន្ធដារ ខេត្តមណ្ឌលគិរី

ផ្លូវលេខ ៣៧៦៣ ភូមិកណ្តាល សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៦៨១
សារអេឡិចត្រូនិក: mondulkiri@tax.gov.kh

### សាខាពន្ធដារ ខេត្តព្រៃវែង

អាគារកែងផ្លូវលេខ៥ និងផ្លូវលេខ៣ ភូមិ២ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៣១៨
សារអេឡិចត្រូនិក: preyveng@tax.gov.kh

### សាខាពន្ធដារ ខេត្តព្រះវិហារ

ភូមិអណ្តូងពោធិ៍ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៦០៤
សារអេឡិចត្រូនិក: preahvihear@tax.gov.kh

### សាខាពន្ធដារ ខេត្តពោធិ៍សាត់

ផ្លូវជាតិលេខ៥ ភូមិមាន់ចៃ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៤៤៧
សារអេឡិចត្រូនិក: pursat@tax.gov.kh

### សាខាពន្ធដារ ខេត្តរតនគិរី

ផ្លូវលេខ ២០ ភូមិថ្មដា សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៦៥៥
សារអេឡិចត្រូនិក: ratanakiri@tax.gov.kh

### សាខាពន្ធដារ ខេត្តសៀមរាប

ផ្លូវជាតិលេខ 6 ភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៣៤៣
សារអេឡិចត្រូនិក: siamreap@tax.gov.kh

### សាខាពន្ធដារ ខេត្តព្រះសីហនុ

វិថី ២៨មិថុនា ភូមិ០១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៥៥២
សារអេឡិចត្រូនិក: preahsihanouk@tax.gov.kh

### សាខាពន្ធដារ ខេត្តស្ទឹងត្រែង

ផ្លូវភូមិស្ពានថ្ម សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៧៣៣
សារអេឡិចត្រូនិក: stoengtreng@tax.gov.kh

### សាខាពន្ធដារ ខេត្តស្វាយរៀង

ផ្លូវលេខ១១៤ ភូមិរោងបន្លែ សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៤២១
សារអេឡិចត្រូនិក: svayrieng@tax.gov.kh

### សាខាពន្ធដារ ខេត្តតាកែវ

ភូមិ១ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៣៩៦
សារអេឡិចត្រូនិក: takeo@tax.gov.kh

### សាខាពន្ធដារ ខេត្តឧត្តរមានជ័យ

អគារខាងលិចសាលាខេត្ត ទល់មុខវិមានឯករាជ្យ ភូមិបុរីរដ្ឋបាល សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៨១១
សារអេឡិចត្រូនិក: odormeanchey@tax.gov.kh

### សាខាពន្ធដារ ខេត្តកែប

ផ្លូវលេខ២៣៥០ ភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៧៥៩
សារអេឡិចត្រូនិក: kep@tax.gov.kh

### សាខាពន្ធដារ ខេត្តប៉ៃលិន

ភូមិប៉ាហ៊ីត្បូង សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៧៨៥
សារអេឡិចត្រូនិក: pailin@tax.gov.kh

### សាខាពន្ធដារ ខេត្តត្បូងឃ្មុំ

ភូមិនិគមលើ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ (ជាប់ខាងត្បូងសាលាឧទ្ធរណ៍ខេត្តត្បូងឃ្មុំ)
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៨៣៧
សារអេឡិចត្រូនិក: tboungkhmum@tax.gov.kh

# កម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)

លោកអ្នកគ្រាន់តែថតវិក្កយបត្រដែលបានទិញទំនិញ-សេវា រួចបញ្ចូល ( Upload ) ក្នុងកម្មវិធីវិក្កយបត្រនាំសំណាង ( GDT Lucky Draw App ) របស់អគ្គនាយកដ្ឋានពន្ធដារ នោះលោកអ្នកនឹងទទួលបានឱកាសឈ្នះរង្វាន់ដ៏សន្ធឹកសន្ធាប់ពីអគ្គនាយកដ្ឋានពន្ធដារ លើសពីនេះទៅទៀត លោកអ្នកក៏បានចូលរួមចំណែកក្នុងការបង្កើនចំណូលថវិកាជាតិ ដើម្បីចូលរួមអភិវឌ្ឍប្រទេសជាតិយើងផងដែរ៕

សូមស្កេន ដើម្បីទទួលបាន វីដេអូណែនាំពីកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)






# កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ ( GDT Taxpayer App)

សូមស្កេនដើម្បីទស្សនាវីដេអូណែនាំ
កម្មវិធីទូរស័ព្ទដៃ
សម្រាប់អ្នកជាប់ពន្ធ
GDT Taxpayer App




កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ ( GDT Taxpayer App ) គឺជាកម្មវិធីទូរស័ព្ទដៃដែលផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ អាចបង់ពន្ធនៅគ្រប់ទីកន្លែងបានតាមទូរស័ព្ទ លើប្រភេទពន្ធមួយចំនួនដូចជា ៖

- ពន្ធលើអចលនទ្រព្យ
- ពន្ធលើមធ្យោបាយដឹកជញ្ជូន និង
- ពន្ធលើផ្ទាំងផ្សព្វផ្សាយ។

សូមធ្វើការទាញយកកម្មវិធី GDT Taxpayer App ដើម្បីងាយស្រួលក្នុងការបង់ពន្ធ៕

## មជ្ឈមណ្ឌលពិគ្រោះយោបល់តាមទូរស័ព្ទរបស់អគ្គនាយកដ្ឋានពន្ធដារ (១២៧៧) មានចម្ងល់ពីពន្ធដារ មិនដឹងសួរនៅទីណាមែនទេ?

លោកអ្នកអាចទទួលសេវាពិគ្រោះយោបល់តាមទូរស័ព្ទដោយទាក់ទងមកលេខ ១២៧៧ ដោយឥតគិតថ្លៃ រៀងរាល់ថ្ងៃនិងម៉ោងធ្វើការ ដើម្បីសាកសួររាល់ចម្ងល់ទាំងឡាយស្ដីពីពន្ធដារ ដូចជា៖

- ច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារ
- សេវាកម្មអេឡិចត្រូនិក
- ការចុះបញ្ជីនិងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ
- ពន្ធលើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់
- ពន្ធប្រថាប់ត្រា
- ពន្ធលើមធ្យោបាយដឹកជញ្ជូន
- ការប្រកាសបង់ពន្ធទូទៅ និង
- ព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងពន្ធដារ




## ឬលោកអ្នកអាច Chat សួរសំណួរពីពន្ធដារតាម កម្មវិធី GDT Live Chat ដោយគ្រាន់តែស្កេន QR Code ខាងក្រោម



# កាន់តែងាយស្រួល និងរហ័សចំពោះការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន




ជាមួយកម្មវិធី GDT Taxpayer App លោក លោកស្រីអាចបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនពីគ្រប់ទីកន្លែង មិនតែប៉ុណ្ណោះបន្ទាប់ពីធ្វើការបង់ពន្ធរួចរាល់ អគ្គនាយកដ្ឋានពន្ធដារនឹងដឹកជញ្ជូនលតាបត្រដល់ទីតាំង។ ក្រៅពីបង់ពន្ធតាមកម្មវិធី លោក លោកស្រីក៏អាចធ្វើការបង់ពន្ធបាននៅតាមបណ្តាធនាគារពាណិជ្ជដៃគូរបស់អគ្គនាយកដ្ឋានពន្ធដារ ឬបង់ពន្ធនៅអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្ត-ខណ្ឌទូទាំងប្រទេស៕

# អ្នកជាប់ពន្ធតូចកាន់តែងាយស្រួលក្នុងការបំពេញកាតព្វកិច្ចពន្ធ តាមរយៈកម្មវិធី ( GDT Tax Prefiling App)




ដើម្បីជួយសម្រួលដល់ការប្រកាសនិងបង់ប្រាក់ពន្ធរបស់អ្នកជាប់ពន្ធតូចអគ្គនាយកដ្ឋានពន្ធដារបានបង្កើតនិងដាក់ឱ្យប្រើប្រាស់កម្មវិធីទូរស័ព្ទដៃដែលមានឈ្មោះ កម្មវិធីប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច ( GDT Tax Prefiling App ) ដែលមានមុខងារកត់ត្រាទិន្នន័យទិញ-លក់ជួយគណនាប្រាក់ពន្ធដែលត្រូវបង់ក្នុងការប្រកាសពន្ធប្រចាំខែនិងប្រចាំឆ្នាំ ពិនិត្យមើលទិន្នន័យបំណុលពន្ធ និងបង់ប្រាក់ពន្ធ៕

សូមស្កេន ដើម្បីទាញយកកម្មវិធីប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច

(GDT Tax Prefiling App)

Download on the App Store

GET IT ON Google Play

YouTube

សូមស្កេន ដើម្បីទស្សនាវីដេអូណែនាំអំពីការប្រើប្រាស់

GDT Tax Prefiling App

# ប្រភពព័ត៌មានអំពីពន្ធដារ




## គេហទំព័រហ្វេសប៊ុកផ្លូវការរបស់ អគ្គនាយកដ្ឋានពន្ធដារ

សូមស្វាគមន៍ការមកកាន់ប្រព័ន្ធផ្សព្វផ្សាយរបស់អគ្គនាយកដ្ឋានពន្ធដារ
សម្រាប់ការផ្សព្វផ្សាយ និងចែកចាយព័ត៌មានថ្មីៗរាល់ថ្ងៃពីពន្ធដារ ។

សូមស្កេនដើម្បីទទួលបានព័ត៌មានថ្មីៗរាល់ថ្ងៃពីពន្ធដារ



## ឆាណែលតេឡេក្រាម ព័ត៌មានពន្ធដារកម្ពុជា

សូមស្វាគមន៍ការមកកាន់ប្រព័ន្ធផ្សព្វផ្សាយរបស់អគ្គនាយកដ្ឋានពន្ធដារ
សម្រាប់ការផ្សព្វផ្សាយ និងចែកចាយព័ត៌មានថ្មីៗរាល់ថ្ងៃពីពន្ធដារ ។

សូមស្កេនដើម្បីទទួលបានព័ត៌មានថ្មីៗរាល់ថ្ងៃពីពន្ធដារ




## តើលោកអ្នកនៅតែមានចម្ងល់ អំពី ពន្ធដារ មែនទេ?

ជួយសម្រួលដល់អ្នកជាប់ពន្ធ និងសាធារណជនដែលមានចម្ងល់ពាក់ព័ន្ធនឹងពន្ធដារ
បានជជែកផ្ទាល់ជាមួយមន្ត្រីជំនាញពន្ធដារតាមអនឡាញពីគ្រប់ទីកន្លែងរៀងរាល់ម៉ោងធ្វើការ

Download on the App Store

GET IT ON Google Play

សូមស្កេនដើម្បីទាញយកកម្មវិធី GDT LIVE CHAT

# កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ ( GDT e-Administration)

**ដាក់លិខិតរដ្ឋបាលនិងឯកសារនានាមករដ្ឋបាលសារពើពន្ធបានពីគ្រប់ទីកន្លែង ដោយគ្រាន់តែប្រើប្រាស់កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ ( GDT e-Administration ) តាមជំហានងាយៗដូចខាងក្រោម៖**

**ជំហានទី ១**

ចូលទៅកាន់គេហទំព័រផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ https://www.tax.gov.kh ជ្រើសរើសសេវាកម្មអេឡិចត្រូនិកពន្ធដារ និងទាញយក (**Download**) កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (**GDT e-Administration**) រួចដំឡើង (**Setup**) កម្មវិធីនេះនៅលើកុំព្យូទ័រជាការស្រេច។

**ជំហានទី ២**

ប្រើប្រាស់គណនីដែលមានស្រាប់ដូចធ្លាប់ចូលប្រើប្រាស់ប្រព័ន្ធ កម្មវិធីផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងករណីមិនទាន់មានគណនី សូមចុះឈ្មោះប្រើប្រាស់ដោយចុច "**បង្កើតគណនីថ្មី**"។

**ជំហានទី ៣**

ជ្រើសរើសប្រភេទអ្នកប្រើប្រាស់ជា អ្នកជាប់ពន្ធ ឬភ្នាក់ងារសេវាកម្មពន្ធដារ ឬអ្នកតំណាងសហគ្រាស រួចបញ្ចូលព័ត៌មាន និងឯកសារដែលកម្មវិធីតម្រូវ។

**ជំហានទី ៤**

ចុចម៉ឺនុយ "**បង្កើតលិខិតរដ្ឋបាលថ្មី**" បន្ទាប់មកបញ្ចូលព័ត៌មានអ្នកស្នើសុំ កម្មវត្ថុនៃលិខិត និងខ្លឹមសារសង្ខេប រួចជ្រើសរើសអង្គភាពដែលត្រូវទទួលលិខិត។

**ជំហានទី ៥**

ភ្ជាប់លិខិតរដ្ឋបាលនិងឯកសារយោងផ្សេងៗ (**Attachment**) ជាទម្រង់ **PDF** បន្ទាប់មកពិនិត្យផ្ទៀងផ្ទាត់ព័ត៌មានដែលបានបញ្ចូលព្រមទាំងឯកសារភ្ជាប់ឡើងវិញ រួចចុចបញ្ជូនជាការស្រេច។






www.tax.gov.kh/km/tax-bulletin

សូមស្កេន QR Code
ដើម្បីទទួលបានព្រឹត្តិបត្រពន្ធដារ
តាមរយៈទូរស័ព្ទដៃ




www.tax.gov.kh/km/tax-news-letter

សូមស្កេន QR Code
ដើម្បីទទួលបាន
ព្រឹត្តិបត្រព័ត៌មានប្រចាំសប្តាហ៍
តាមរយៈទូរស័ព្ទដៃ




**សម្រាប់ព័ត៌មានបន្ថែមលោក-លោកស្រីអាចទំនាក់ទំនងតាមរយៈ**

Website Facebook Instagram Youtube

អាសយដ្ឋាន ៖ អគារកែងមហាវិថីសហព័ន្ធរុស្សី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
មជ្ឈមណ្ឌលពិគ្រោះយោបល់ / **Call Center** ៖ ១២៧៧ (ដោយឥតគិតថ្លៃ) | គេហទំព័រ ៖ www.tax.gov.kh | សារអេឡិចត្រូនិក ៖ gdt@tax.gov.kh